Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

81787

# ភាពរឹងមាំក្នុងបរិយាកាសលំបាក

## របាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា




ធនាគារពិភពលោក

ខែកញ្ញា ឆ្នាំ ២០១៣

# ភាពវែងឆ្ងាយក្នុងបរិយាកាសលំបាក

## របាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែកញ្ញា ឆ្នាំ ២០១៣

រក្សាសិទ្ធិគ្រប់បែបយ៉ាង

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាជាវណ្ណកម្មមួយរបស់ធនាគារពិភពលោក។

របកគំហើញ ការបកស្រាយ និងសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍នេះជារបស់បុគ្គលិកធនាគារពិភពលោកនិងមិនប្រាកដជាឆ្លុះបញ្ចាំងទស្សនៈរបស់គណៈគ្រប់គ្រង ក្រុមប្រឹក្សាប្រតិបត្តិ ឬរដ្ឋាភិបាលដែលពួកគេតំណាងឡើយ។

ធនាគារពិភពលោកមិនធានាអំពីភាពត្រឹមត្រូវនៃទិន្នន័យដែលមាននៅក្នុងរបាយការណ៍នេះឡើយ។

# បុព្វកថា និងសេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា គឺជាវណ្ណកម្មរបស់បុគ្គលិកធនាគារពិភពលោក។ របាយការណ៍នេះ ត្រូវបានរៀបរៀងដោយ លោក លី សូដេត និង ពិនិត្យឡើងវិញ កែសម្រួលដោយ អេនរិកកេ អាល់ដាហ្ស ខារ៉ូល (Enrique Aldaz - Carroll) ផ្នែកកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងសេដ្ឋកិច្ចនៃការិយាល័យធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា។ ក្រុមភាពក្រីក្រដឹកនាំដោយ នាក់ សមសែន (Samsen Neak) បានរួមចំណែកក្នុងផ្នែកភាពក្រីក្រនៃរបាយការណ៍បច្ចុប្បន្នភាពនេះ។ ក្រុមនេះធ្វើការក្រោមការណែនាំរបស់ ម៉ាសូ អេ វើហ្គិស (Mathew A. Verghis) ប្រធានសេដ្ឋវិទូ និង ប្រធានគ្រប់គ្រងវិស័យ ផ្នែកកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងសេដ្ឋកិច្ច និង អាឡាសាន សូ (Alassane Sow) ប្រធានគ្រប់គ្រងប្រចាំប្រទេសកម្ពុជា។

របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានផលិតរៀងរាល់ឆមាស ដើម្បីផ្តល់ព័ត៌មានថ្មីៗ អំពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានបោះពុម្ពផ្សាយ និងចែកចាយយ៉ាងទូលំទូលាយទៅកាន់អាជ្ញាធរកម្ពុជា សហគមន៍ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមវិភាគនិងរៀបចំគោលនយោបាយ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសិក្សាស្រាវជ្រាវ ។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានកំណត់ពេលឱ្យស្របជាមួយនឹងការបោះពុម្ពផ្សាយប្រចាំឆមាស អំពីបច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា ដោយផ្នែកកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងសេដ្ឋកិច្ចអាស៊ីបូព៌ានៃធនាគារពិភពលោក។

យើងបានទទួលការផ្តល់យោបល់និងសំណើដ៏មានតម្លៃពីមិត្តរួមការងារស្តីពីការកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងសេដ្ឋកិច្ច រួមមាន អេម អាដីសសុន (Douglas M. Addison), សាបីស អាលី មូហីប (Shabih Ali Mohib) និង យុង វាន់ ឆា (Young Hwan Cha)។ យោបល់ និងសំណូមពរល្អៗក៏បានទទួលផងដែរពី រ៉ាហ្វ វ៉ាន់ ឌន (Ralph van Doorn) ផ្នែកគោលនយោបាយសេដ្ឋកិច្ច និងបំណុល។ យើងសូមសម្តែងនូវតញ្ញូតាធម៌ចំពោះយោបល់ និងសំណើប្រកបដោយបញ្ញាញាណ ដែលបានផ្តល់ដោយ លោក James Seward ផ្នែកវិស័យហិរញ្ញវត្ថុ និងឯកជន លោក ស៊ីមេត បេង (Simeth Beng) ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស ក៏បានរួមចំណែកផ្តល់យោបល់មួយចំនួនផងដែរ។ លីនណា គី (Linna) គី បានជួយរចនាទម្រង់របាយការណ៍បច្ចុប្បន្នភាពនេះ និងបានផ្តល់ការគាំទ្រផ្នែកផ្គត់ផ្គង់ និងរដ្ឋបាលដ៏ល្អក្នុងការរៀបចំ និង បោះពុម្ពផ្សាយរបាយការណ៍នេះ។

យើងសូមថ្លែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅដល់អាជ្ញាធរកម្ពុជាចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្រក្នុងការរៀបចំរបាយការណ៍បច្ចុប្បន្នភាពនេះ។

ចំពោះព័ត៌មានបន្ថែមអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមទស្សនាគេហទំព័រ www.worldbank.org / Kh។

ដើម្បីដាក់បញ្ចូលឈ្មោះទៅក្នុងបញ្ជីចែកចាយអ៊ីម៉ែលនៃរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា និងឯកសារពាក់ព័ន្ធ សូមទាក់ទង លីនណា គី (Linna Ky) (lky@worldbank.org)។ ប្រសិនបើមានសំណួរលើខ្លឹមសារនៃឯកសារនេះ សូមទាក់ទង លោក ប៊ូ សារឿន (Saroeun Bou) (sbou@worldbank.org)។

# មាតិកា


ក- ខ្លឹមសារសង្ខេប ..... 1

ខ- បរិយាកាសសកល ..... 4
កំណើនសេដ្ឋកិច្ចសកល ..... 4
ថ្លៃទំនិញពិភពលោក ..... 5

គ- សេដ្ឋកិច្ចកម្ពុជា ..... 6
វិស័យផលិត ..... 6
កសិកម្ម ..... 6
ផលិតកម្មស្រូវ ..... 7
វិស័យកាត់ដេរ ..... 8
សំណង់និងអចលនទ្រព្យ ..... 9
ទេសចរណ៍ ..... 9
ឱកាសការងារនិងថ្លៃពលកម្ម ..... 10
ជញ្ជីងពាណិជ្ជកម្ម ..... 11
អតិផរណា ..... 13
វិស័យរូបិយវត្ថុ ..... 15
ទុនបំរុងអន្តរជាតិដុល ..... 16
ទ្រព្យសកម្មបរទេសសុទ្ធ ..... 16
រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់ ..... 17
អត្រាប្តូរប្រាក់ ..... 18
វិស័យធនាគារ ..... 19
វិស័យសារពើពន្ធ ..... 21
តុល្យការចំណូលសារពើពន្ធ ..... 24
ចំណាយតាមវិស័យ ..... 25

ឃ- សេចក្តីសន្និដ្ឋាន ..... 26

ង- ប្រធានបទពិសេសសម្រាប់លេខនេះ៖ ស្ថានភាព ភាពក្រីក្រ ..... 27

ឧបសម្ព័ន្ធ 1 ..... 31
សូចនាករសេដ្ឋកិច្ចពិភពលោក ..... 31

ឧបសម្ព័ន្ធ 2 ..... 32
សូចនាករសំខាន់ៗនៅកម្ពុជា ..... 32

ឧបសម្ព័ន្ធ 3 ..... 33
កម្ពុជា៖ ចំណាយតាមវិស័យពីប្រភពហិរញ្ញប្បទានក្នុងស្រុក ..... 33

# ប្រអប់

ប្រអប់លេខ 1- ការនាំចូលក្រណាត់និងការនាំចេញសម្លៀកបំពាក់ ........ 8
ប្រអប់លេខ 2- ដុល្លារូបនីយកម្មពេញលេញ ........ 15
ប្រអប់លេខ 3- និរន្តរភាពបំណុល ........ 22

# ក- ខ្លឹមសារសង្ខេប

1- **រយៈពេលបួនឆ្នាំបន្ទាប់ពីចាប់ផ្តើមមានវិបត្តិហិរញ្ញវត្ថុសកល សេដ្ឋកិច្ចពិភពលោកនៅតែបន្តជួបការលំបាក។** យោងតាម Global Economic Prospects ខែមិថុនា ឆ្នាំ 2013 បរិយាកាស សេដ្ឋកិច្ចពិភពលោកនៅតែមានលក្ខណៈផុយស្រួយ ទោះបីជាតុល្យភាពនៃហានិភ័យបច្ចុប្បន្នមិនសូវមានសភាពធ្ងន់ធ្ងរដូច ដែលធ្លាប់មានកាលពីប៉ុន្មានឆ្នាំមុនក្តី។ សហរដ្ឋអាមេរិកបាននិងកំពុងបង្ហាញឱ្យឃើញសញ្ញាចាកចេញពីការប្រើគោលនយោបាយរូបិយវត្ថុពិសេស។ រូបិយវត្ថុប្រទេសកំពុងអភិវឌ្ឍន៍រងសម្ពាធ ហើយអត្រាការប្រាក់របស់ពួកគេបានកើនឡើងធ្វើឱ្យមានអតិផរណានិងកំណើនទាបជាងមុន។ *ការណ៍នេះ អាចធ្វើឱ្យស្មុគស្មាញដល់សេដ្ឋកិច្ចប្រទេសទាំងឡាយណាដែលបង្កើនឥណទានដ៏ច្រើន ក្នុងពេលដែលមានអត្រាការប្រាក់ទាប ឬនៅពេលដែលគណនីចរន្តនិងឱនភាពរបស់រដ្ឋាភិបាលមានកម្រិតខ្ពស់*។សេដ្ឋកិច្ចរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅតែជាកត្តាជំរុញចម្បងនៃកំណើនសេដ្ឋកិច្ចពិភពលោក ប៉ុន្តែលទ្ធផលនៃសេដ្ឋកិច្ចប្រទេសទាំងនោះបានធ្លាក់ចុះ ធៀបនឹងរយៈពេលមុនមានវិបត្តិ។

2- **សេដ្ឋកិច្ចកម្ពុជានៅតែរឹងមាំ ក្នុងពេលបរិយាកាសស្ថានសេដ្ឋកិច្ចពិភពលោកកំពុងប្រឈមនឹងបញ្ហា និងលទ្ធភាពអនុវត្តការព្យាករកំណើន 7 ភាគរយនៅឆ្នាំ 2013 ទំនងជាមានលក្ខណៈអំណោយផល។** នៅឆ្នាំ 2012 កំណើនផលិតផលក្នុងស្រុកសរុបពិតស្មើនឹង 7,3 ភាគរយ។ កំណើនផលិតផលក្នុងស្រុកសរុបត្រូវបានជំរុញ ដោយវិស័យកសិកម្មដែលមានកំណើនខ្ពស់និងមាននិរន្តរភាព ការនាំចេញដែលទើបងើបឡើងវិញ សកម្មភាពរីកចំរើនឡើងវិញនៃវិស័យសំណង់ និងការរីកចំរើនដ៏ខ្លាំងនៃវិស័យទេសចរណ៍។ ទោះជាយ៉ាងណាក្តី តទៅមុខ ការធ្លាក់ចុះកំណើននៅប្រទេសចិន និងការធ្លាក់ចុះកំណើនក្នុងរយៈពេលយូរនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប អាចប៉ះពាល់ដល់តម្រូវការផលិតផល និងសេវាកម្មរបស់កម្ពុជា និងជាហានិភ័យពីខាងក្រៅដែលប៉ះពាល់ដល់កម្ពុជា។

3- **ការនាំចេញសម្លៀកបំពាក់បានកើនឡើង 18 ភាគរយ ធៀបនឹងឆ្នាំមុនគិតត្រឹមខែមិថុនា ឆ្នាំ 2013។** វិស័យទេសចរណ៍បន្តមាននិន្នាការកំណើនខ្ពស់។ ការមកដល់នៃភ្ញៀវទេសចរបានកើនដល់ 19 ភាគរយធៀបនឹងឆ្នាំមុន។ ការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរនៅក្នុងទីផ្សារគោលដៅ ចំពោះសម្លៀកបំពាក់ ការពង្រីកផ្ទៃដីដាំដុះ និងពិពិធកម្មប្រភេទនៃវិស័យទេសចរណ៍ បានជួយដល់ក្បាលម៉ាស៊ីនសំខាន់បីរបស់កម្ពុជាឱ្យធានាបាននូវចលករ ជំរុញឱ្យមានកំណើន ផសស។

4- **ជាមួយនឹងការនាំចូលតិច និងការនាំចេញច្រើន ឱនភាពគណនីចរន្តត្រូវបានគេប៉ាន់ប្រមាណថា មានទំហំរួមតូច[1]។** ឱនភាពគណនីចរន្តឆ្នាំនេះ មិនរួមបញ្ចូលប្រាក់បង្វែរផ្លូវការត្រូវបានប៉ាន់ស្មានថាមានប្រហែល 9 ភាគរយនៃផលិតផលក្នុងស្រុកសរុបធៀបនឹង 10,1 ភាគរយនៃផលិតផលក្នុងស្រុកសរុបឆ្នាំ 2012។ អតិរេកគណនីមូលធននិងហិរញ្ញវត្ថុនៅមានជាបន្ត ត្បិតការវិនិយោគផ្ទាល់ពីបរទេសនៅតែមានទំហំច្រើនជាងឆមាសទីមួយនៃឆ្នាំ 2013 ហើយវិនិយោគិនទំនងជាមានការចាប់អារម្មណ៍ខ្លាំង ក្នុងអំឡុងពេលបោះឆ្នោតលើកនេះខុសពីការបោះឆ្នោតលើកមុនៗ។ គេនៅមិនទាន់ដឹងច្បាស់នៅឡើយទេ អំពីទំហំនៃផលប៉ះពាល់នៃភាពមិនប្រាកដប្រជាផ្នែកនយោបាយក្រោយពេលបោះឆ្នោត មកលើការវិនិយោគផ្ទាល់ពីបរទេស។ គិតត្រឹមខែមិថុនា ឆ្នាំ 2013 នេះ ទុនបម្រុងអន្តរជាតិដុលបានកើនដល់ 3,6 ពាន់លានដុល្លារអាមេរិក ធៀបនឹង 3,5 ពាន់លានដុល្លារអាមេរិកនៅចុងឆ្នាំ 2012។

5- **នៅក្នុងខែមិថុនាឆ្នាំ 2013 ឆ្នាំ អតិផរណាធៀបនឹងឆ្នាំមុនបានកើនឡើងដល់ 2,9 ភាគរយ ដោយសារតែការកើនឡើងបន្តិចនូវថ្លៃស្បៀងអាហារ។** អតិផរណាត្រូវបានគេប៉ាន់ស្មានថា មានកម្រិតទាបត្រឹមតួលេខមួយខ្ទង់ ក្នុងរយៈពេលខ្លី។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ( CPI ) បានធ្លាក់ចុះនៅឆ្នាំ 2012 ដោយធ្លាក់ចុះដល់ 2,5 ភាគរយនៅចុង ឆ្នាំ 2012 ធៀបនឹង 4,9 ភាគរយ នៅឆ្នាំ 2011 ដោយសារតែការធ្វើឱ្យមានស្ថេរភាពប្រភេទផលិតផលសំខាន់ៗ ពិសេស ថ្លៃស្បៀងអាហារ ដែលស្មើនឹង 43 ភាគរយ នៃកញ្ចប់អតិផរណា។

6- **ប្រាក់ដុល្លារបានឡើងថ្លៃ ចាប់តាំងពីត្រីមាសទីពីរក្នុងឆ្នាំនេះធ្វើឱ្យធនាគារកណ្តាល បង្ខំចិត្តធ្វើអន្តរាគមន៍។** គិតត្រឹមខែមិថុនា ឆ្នាំ2013 ធនាគារកណ្តាលបានខាតបង់ទុនបំរុង

1 *ឱនភាពគណនីចរន្តមិនគិតបញ្ចូលប្រាក់បង្វែរផ្លូវការឡើយ*

អន្តរជាតិចំនួន 150 លានដុល្លារអាមេរិក។ អត្រាប្តូរប្រាក់ធ្លាក់ថ្លៃហើយប្រាក់រៀលចុះថោកដល់ 4.062 រៀល ក្នុងមួយដុល្លារអាមេរិកក្នុងខែមិថុនា ឆ្នាំ 2013 [2] ។ ប្រាក់រៀលត្រូវបានភ្ជាប់ជាមួយប្រាក់ដុល្លារអាមេរិក ចំណែកអត្រាប្តូរប្រាក់វិញបាននឹងកំពុងនៅទ្រឹងជុំវិញ 4.000 រៀល ក្នុងមួយដុល្លារ។ ការអភិវឌ្ឍស៊ីជំរៅផ្នែកហិរញ្ញវត្ថុប្រព្រឹត្តទៅជាបន្ត ហើយមានចំនួនធនាគារកាន់តែច្រើន កំពុងចូលមកកាន់ទីផ្សារប្រទេសកម្ពុជា។ ការប្រកួតប្រជែងរវាងធនាគារបានរួមចំណែកដល់ការកាត់បន្ថយគម្លាតអត្រាការប្រាក់ដុល្លារអាមេរិក និងជំរុញឱ្យមានប្រសិទ្ធិភាពមួយចំនួន ចូលទៅក្នុងទីផ្សារ។ ទោះជាយ៉ាងណាក្តី ក៏មានហានិភ័យយ៉ាងច្រើនចំពោះការមានចំនួនធនាគារច្រើន ដោយសារតែមានបញ្ហាប្រឈមលើសមត្ថភាពត្រួតពិនិត្យផងដែរ។

7- **ក្នុងកំឡុងពេលប្រាំខែដំបូងនៃឆ្នាំ 2013 ចំណូលក្នុងស្រុកនៅតែកើនឡើងប៉ុន្តែមានកំណើនយឺតជាងមុន ពោលគឺកើនឡើងត្រឹមតែ 9,6 ភាគរយ ធៀបនឹងឆ្នាំមុន ធៀបនឹង 24,7 ភាគរយនៅឆ្នាំ 2012[3]។** ទោះជាយ៉ាងណាក្តី ចំណាយសាធារណៈហាក់មានល្បឿនយឺតជាងមុន។ ដូច្នេះឱនភាពថវិកា (មិនរួមបញ្ចូលជំនួយឥតសំណង) គួរតែអនុវត្តបានដូចការគ្រោងទុកជុំវិញ 5,4 ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ការគ្រប់គ្រងសារពើពន្ធនៅតែមានភាពសមស្រប និងគាំទ្រដល់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ប៉ុន្តែនៅមានលទ្ធភាពច្រើនសម្រាប់បង្កើនប្រាក់ចំណូលក្នុងស្រុក និងសម្រាប់បង្កើនប្រសិទ្ធភាពចំណាយ។ នៅឆ្នាំ 2012 ប្រទេសកម្ពុជាបានស្តារឡើងវិញនូវលំហសារពើពន្ធ (Fiscal space) ដែលត្រូវបានប៉ាន់ស្មានថានឹងឡើងដល់ 14,4 ភាគរយនៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ 2012 ធៀបទៅនឹង 13,1 ភាគរយនៅក្នុងឆ្នាំ 2011 ដោយសារមានកំណើនខ្ពស់។ ទោះជាយ៉ាងណាក្តី រដ្ឋាភិបាលបន្តពឹងផ្អែកយ៉ាងខ្លាំងលើម្ចាស់ជំនួយ ដែលផ្តល់មូលនិធិជិតស្មើនឹង 80 ភាគរយនៃការវិនិយោគ សាធារណៈសរុប ឬត្រូវជា 34 ភាគរយនៃចំណាយសាធារណៈសរុប។

8- **តាមន័យធៀប ការវិភាជន៍ថវិកាដល់វិស័យសង្គមកិច្ចសំខាន់ៗ ដូចជា សុខាភិបាលនិងវិស័យអប់រំ មាននិន្នាការធ្លាក់ចុះ[4]។** ភាគរយចំណាយលើវិស័យសុខាភិបាល និងវិស័យអប់រំ ក្នុងចំណាយដែលផ្តល់ហិរញ្ញប្បទានពីប្រភពក្នុងស្រុកសរុបបានថយចុះមកត្រឹម 8,7 ភាគរយ និង 10,3 ភាគរយ នៅឆ្នាំ 2011 ពី 9,8 ភាគរយ និង 14,2 ភាគរយ នៅក្នុងឆ្នាំ 2007។ ភាគរយសរុបនៃវិស័យរដ្ឋបាលទូទៅ វិស័យការពារជាតិ និងសន្តិសុខបានកើនឡើងយ៉ាងលឿនឡើងដល់ 60 ភាគរយនៃចំណាយសរុបក្នុងឆ្នាំ 2011 ពី 44,3 ភាគរយក្នុងឆ្នាំ 2007 ឆ្លុះឱ្យឃើញនូវការកើនឡើងនូវតម្រូវការសម្រាប់ការចំណាយដែលទាក់ទងនឹងសន្តិសុខ និងការការពារជាតិ។ គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប ការចំណាយដែលធ្វើហិរញ្ញប្បទានដល់វិស័យសុខាភិបាលក្នុងស្រុកមាននិន្នាការកើនឡើងបន្តិច គឺកើនឡើង 1,3 ភាគរយក្នុងឆ្នាំ 2011 ពី 1,0 ភាគរយក្នុងឆ្នាំ 2007 ខណៈពេលដែលការចំណាយលើវិស័យអប់រំនៅតែមានស្មើនឹង 1,6 ភាគរយនៃផលិតផលក្នុងស្រុកសរុបចាប់តាំងពីឆ្នាំ 2007 មក។ របាយការណ៍ថ្មីមួយបានរកឃើញថា ចំណាយសាធារណៈរបស់ប្រទេសកម្ពុជាលើវិស័យអប់រំគឺស្មើត្រឹមតែពាក់កណ្តាលធៀបនឹងបណ្តាក្រុមប្រទេសឯទៀតស្រដៀងនឹងកម្ពុជា ហើយចំណាយលើវិស័យសុខាភិបាលអប្រសិទ្ធភាព [5]។

9- **ទស្សនវិស័យ អំពីនិរន្តរភាពជារួមនៃបំណុលនៅតែមានលក្ខណៈអំណោយផល។** DSA ឆ្នាំ 2012 រួមគ្នារវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិបង្ហាញថា ចំណាត់ថ្នាក់លើភាពពិបាកសងបំណុលរបស់ប្រទេសកម្ពុជា នៅតែមានកម្រិតទាប។ គោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការជៀសវាងកម្ចីមិនមែនសម្បទាន គឺជាកត្តាសំខាន់ចំពោះការគ្រប់គ្រង បំណុលប្រកបដោយនិរន្តរភាព។ ទំហំបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា និង បំណុលធានាដោយវិស័យសាធារណៈមានប្រមាណជា 30,1 ភាគរយនៃផលិតផលក្នុងស្រុកសរុប គិតជាទំហំទឹកប្រាក់ជាក់ស្តែងនៅចុងឆ្នាំ 2012។

*2 អត្រាប្តូរប្រាក់ផ្លូវការមធ្យម*

*3 តួលេខសារពើពន្ធបឋមសម្រាប់ឆ្នាំ 2013*

*4 ទិន្នន័យចំណាយតាមវិស័យនៅឆ្នាំ 2013 នៅមិនទាន់មាននៅឡើយទេ*

*5 របាយការណ៍ការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញនូវចំណាយសាធារណៈឆ្នាំ 2011 (IFAPER),ធនាគារពិភពលោក*

10- **ជាលទ្ធផលនៃល្បឿន និងនិន្នាការនៃកំណើនឆាប់រហ័ស ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋមួយភាគធំ ភាពក្រីក្រនៅប្រទេសកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំង។** កំណើនសេដ្ឋកិច្ចមានទំហំធំ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅមួយផ្នែកធំដោយសារកំណើន ប្រកបដោយចីរភាពក្នុងវិស័យកសិកម្ម ដែលអំណោយផល ដោយកំណើនថ្លៃអង្ករនៅទីផ្សារសកលលោក។ភាគរយនៃចំនួនប្រជាពលរដ្ឋក្រីក្រត្រូវបានកាត់បន្ថយច្រើនជាងពាក់កណ្តាលក្នុងរយៈពេលប្រាំពីរឆ្នាំ ចុះមកត្រឹមប្រមាណជា 20 ភាគរយ នៅឆ្នាំ 2011។ បើទោះបីជាការកាត់បន្ថយភាពក្រីក្រមានទំហំធំក្តី គ្រួសារភាគច្រើនដែលបានចាកផុតពីភាពក្រីក្រ មិនបានចាកផុតទាំងស្រុងឡើយមានន័យថាគ្រួសារទាំងនោះបានប្តូរពីគ្រួសារក្រីក្រ ទៅជាគ្រួសារដែលមានជីវភាពមិនខុសពីគ្រួសារក្រីក្រប៉ុន្មានឡើយ។

11- **សរុបមកសារសំខាន់ៗគឺ៖ ( ក) ការទ្រទ្រង់កំណើនរឹងមាំដោយជំរុញពិពិធកម្ម និងការលើកកំពស់ភាពប្រកួតប្រជែង; (ខ) រក្សាស្ថិរភាពធនាគារ និងហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យដែលមានប្រសិទ្ធិភាព និង (គ) កែលម្អការគ្រប់គ្រងសារពើពន្ធដោយការបង្កើនចំណូលនិងប្រសិទ្ធភាពចំណាយបន្ថែមទៀត។** ឯកសារបច្ចុប្បន្នភាពនេះត្រូវបានរៀបចំជាប្រាំផ្នែក។ ផ្នែក ក ជាសេចក្តីសង្ខេប។ ផ្នែក ខ ណែនាំអំពីបរិយាកាសនិងទស្សនវិស័យសេដ្ឋកិច្ចពិភពលោក។ ផ្នែក គ ពិភាក្សា លម្អិតអំពីសេដ្ឋកិច្ចកម្ពុជា។ ផ្នែក ឃ ពិភាក្សាអំពីការផ្តល់យោបល់ផ្សេងៗ និងមាគ៌ាឆ្ពោះទៅមុខ។ ឯកសារបច្ចុប្បន្នភាពនេះបញ្ចប់ដោយផ្នែក ង ដែលបង្ហាញរបកគំហើញសំខាន់ៗនៃការវាយតម្លៃភាពក្រីក្រ កាលពីពេលកន្លងទៅថ្មីនៅកម្ពុជា។

# ខ- បរិយាកាសសកល [6]

## កំណើនសេដ្ឋកិច្ចសកល

1- **សេដ្ឋកិច្ចសកលកំពុងឆ្លងទៅកាន់រយៈពេលមួយកាន់កំណើនដែលកាន់តែមានស្ថិរភាព ប៉ុន្តែមានល្បឿនយឺតជាងមុន។** ស្ថានភាពហិរញ្ញវត្ថុ នៅក្នុងប្រទេសមានប្រាក់ចំណូលខ្ពស់មានលក្ខណៈប្រសើរឡើង និងមិនសូវមានហានិភ័យ។ ទោះជាយ៉ាងណាក្តីអត្រាកំណើនរបស់ពួកគេត្រូវបានរំពឹងថា នឹងកើនឡើងបន្តិចម្តងៗ ហើយផលិតផលក្នុងស្រុកសរុបកើនត្រឹមតែ 1,2 ភាគរយប៉ុណ្ណោះនៅឆ្នាំនេះ ប៉ុន្តែមុខជាឡើងដល់ 2,0 និង 2,3 ភាគរយនៅឆ្នាំ 2014 និងឆ្នាំ 2015 (ឧបសម្ព័ន្ធទី1)។ គេបានព្យាករណ៍ថាផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកំពុងអភិវឌ្ឍន៍នឹងកើនឡើងមិនតិចជាង 5,1ភាគរយនៅឆ្នាំនេះ និង 5,6 និង 5,8 ភាគរយ នៅឆ្នាំ 2014 និងឆ្នាំ 2015។

2- **ទោះជាយ៉ាងណាក្តីបញ្ហាប្រឈមមានច្រើនសណ្ឋាន។** បញ្ហាទាំងនោះ រួមមានសម្ពាធអតិផរណា និងកំណើនថ្លៃអចលនទ្រព្យមិនស្ថិតស្ថេរ និងអត្រាកំណើនទាបជាងមុនពេលមានវិបត្តិ បន្ថែមលើបញ្ហាប្រឈមនានាបណ្តាលមកពីការដកចេញនូវការអនុវត្តន៍គោលនយោបាយរូបិយវត្ថុពិសេស។

3- **សម្ពាធអតិផរណានៅតែមានកម្រិតទាប។** ទោះបីជាមានការជំរុញគោលនយោបាយរូបិយវត្ថុនិងការបង្កើនកំណើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងត្រីមាសចុងក្រោយនៃឆ្នាំ 2012 ក្តី សម្ពាធអតិផរណានៅតែមានកម្រិតទាប ថ្វីបើនៅតំបន់អាស៊ីបូព៌ា មជ្ឈឹមបូព៌ា អាហ្វ្រិកខាងជើង និងអាស៊ីខាងត្បូងបង្ហាញនូវសញ្ញានៃអតិផរណាកើនឡើងក្តី។

4- **លំហូរមូលធនទៅកាន់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ គិតជាបរិមាណលំហូរជាក់ស្តែងក៏បានកើនឡើងវិញផងដែរ។** លំហូរទាំងនោះសឹងតែស្មើកម្រិតខ្ពស់បំផុត និងការងើបឡើងវិញនៃលំហូរធនាគារ បង្ហាញផលប៉ះពាល់ដ៏អាក្រក់បំផុតនៃការកាត់បន្ថយបំណុលតំបន់អឺរ៉ុប មកលើប្រទេសកំពុងអភិវឌ្ឍន៍បានកន្លងផុត។ ស្ថានភាពទីផ្សារហិរញ្ញវត្ថុបន្តមានស្ថិរភាព និងការធ្វើឱ្យប្រសើរឡើងយ៉ាងច្រើន នូវស្ថានភាពហិរញ្ញវត្ថុពិភពលោកចាប់តាំងពីឆមាសទីពីរនៃឆ្នាំ 2012។ ការធ្វើឱ្យប្រសើរឡើងនេះឆ្លុះបញ្ចាំងវឌ្ឍនភាព ឆ្ពោះទៅរកនិរន្តរភាពសារពើពន្ធនៅក្នុងតំបន់អឺរ៉ុប។ ការណ៍នេះ ស្របជាមួយជំហានគោលនយោបាយរូបិយវត្ថុវិសាមញ្ញ ដែលអនុវត្តដោយធនាគារកណ្តាលសំខាន់ៗ ដែលបានបញ្ចេញសាច់ប្រាក់ងាយស្រួលពាសពេញទីផ្សារ។

5- **ប្រទេសកំពុងអភិវឌ្ឍន៍កំពុងដឹកនាំសកម្មភាពងើបឡើងវិញ ប៉ុន្តែកំណើនសេដ្ឋកិច្ចរបស់ពួកគេថយចុះ នៅក្នុងត្រីមាសទីមួយនៃឆ្នាំនេះ។** ការផ្លាស់ប្តូរនេះ ដំបូងឡើយបានចាប់ផ្តើមនៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានរីករាលដាលបន្ថែមទៀត។ ប្រទេសកំពុងអភិវឌ្ឍន៍បានទទួលប្រយោជន៍ពីគោលនយោបាយរូបិយវត្ថុពិសេស ដែលជំរុញផលិតផលក្នុងស្រុកសរុបរបស់ប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ធ្វើឱ្យថ្លៃនៃការខ្ចីប្រាក់ធ្លាក់ចុះ និងជៀសវាងវិបត្តិធ្ងន់ធ្ងរនៃវិស័យហិរញ្ញវត្ថុ។ លើសពីនេះទៅទៀត ការបង្កើនសាច់ប្រាក់ងាយស្រួលមិនបានបង្កើតឱ្យមានលំហូរមូលធនច្រើនលើសលុបឡើយ។

6- **សន្ទុះកំណើននៅត្រីមាសទីមួយនៃឆ្នាំ 2013 នេះបានចុះថយ។** ការណ៍នេះ ឆ្លុះបញ្ចាំងកិច្ចប្រឹងប្រែងរបស់ចិនក្នុងការធ្វើឱ្យមានតុល្យភាពឡើងវិញ ការធ្លាក់ថ្លៃប្រាក់យ៉េន ការធ្លាក់ថ្លៃទំនិញ ឧបសគ្គផ្នែកសមត្ថភាពនៅក្នុងប្រទេសជាច្រើនដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ និងការរឹតបន្តឹងជាបណ្តើរៗនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។ ជាលទ្ធផលធ្វើឱ្យសន្ទុះនៃការងើបឡើងវិញយ៉ាងខ្លាំងនៃវិស័យពាណិជ្ជកម្មហាក់ដូចជាបាត់បង់ទៅវិញ។ តម្រូវការនាំចូលរបស់ប្រទេសកំពុងអភិវឌ្ឍន៍បានធ្លាក់ចុះ ហើយតម្រូវការនាំចេញ និងតម្រូវការនាំចូលពីបណ្តាប្រទេសមានប្រាក់ចំណូលខ្ពស់ ក្លាយទៅជាអវិជ្ជមាន។ នៅពេលដែលបណ្តាប្រទេសមានប្រាក់ចំណូលខ្ពស់បន្ថយសកម្មភាពអនុវត្តគោលនយោបាយរូបិយវត្ថុពិសេស ឬចាប់ផ្តើមបន្ធូរបន្ថយមូលប័ត្ររយៈពេលវែង អត្រាការប្រាក់ទំនងជានឹងកើនឡើង។

6 *របាយការណ៍ Global Economic Prospect (GEP) ខែ មិថុនា ឆ្នាំ 2013, ធនាគារពិភពលោក*

7- **ថ្មីៗនេះសហរដ្ឋអាមេរិកបាន និងកំពុងបង្ហាញនូវការចាកចេញពីការប្រើគោលនយោបាយរូបិយវត្ថុពិសេស និងការទស្សន៍ទាយអំពីពេលវេលានៃការចាកចេញនេះ បាននិងកំពុងធ្វើឱ្យទីផ្សារហិរញ្ញវត្ថុរញ្ជួយ។** ផលវិនិយោគលើបណ្ណរតនាគារសហរដ្ឋអាមេរិកបានកើនឡើងរួចទៅហើយ ធ្វើឱ្យបណ្ណរតនាគារដែលមិនសូវមានហានិភ័យច្រើន កាន់តែមានលក្ខណៈទាក់ទាញជាងកាលពីពេលមុន។ ជាលទ្ធផលលុយបាននិងកំពុងហូរត្រឡប់ចូលទៅក្នុងប្រាក់ដុល្លារវិញ។ រូបិយប័ណ្ណប្រទេសកំពុងអភិវឌ្ឍន៍ស្ថិតនៅក្រោមសម្ពាធ ហើយអត្រាការប្រាក់របស់ពួកគេក៏បានកើនឡើងផងដែរ ធ្វើឱ្យមានអតិផរណា និងអត្រាកំណើនទាប។ ការវិនិយោគតិច និងកំណើនសេដ្ឋកិច្ចទាប តទៅមុខ អាចប៉ះពាល់ដល់បណ្ដាប្រទេសទាំងឡាយណាដែលមានកំណើនឥណទានក្នុងពេលដែលអត្រាការប្រាក់ទាប ឬប្រទេសទាំងឡាយណាដែលមានឱនភាពគណនីចរន្ត និងឱនភាពរដ្ឋាភិបាលខ្ពស់។

## ថ្លៃទំនិញពិភពលោក

8- **ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះតម្លៃថាមពល និងលោហធាតុបានធ្លាក់ចុះ ឆ្លើយតបទៅនឹងសមត្ថភាពថ្មី។** ស្ថានភាពនេះ ហាក់ដូចជាឆ្លើយតបទៅនឹងការជំនួសការផ្គត់ផ្គង់និងតម្រូវការ បណ្ដាលមកពីថ្លៃទំនិញខ្ពស់។ ចាប់តាំងពីឆ្នាំ 2000 មក ចំណាយមូលធនរបស់ក្រុមហ៊ុនធំៗក្នុងទីផ្សារប្រេងនិងលោហធាតុបានកើនឡើងប្រាំដង។ ជាមួយគ្នានេះក៏មានសម្ពាធលើតម្រូវការផងដែរ។ ការគួបផ្សំគ្នារវាងការកើនឡើងនូវការផ្គត់ផ្គង់ និងការធ្លាក់ចុះនូវតម្រូវការបានធ្វើឱ្យបរិមាណស្តុក(ទំនិញ)ទូទៅកើនឡើង។ ជាលទ្ធផល ទោះបីជាការពង្រឹងសេដ្ឋកិច្ចពិភពលោកក្តី ថ្លៃទំនិញឧស្សាហកម្មភាគច្រើនបាននិងកំពុងធ្លាក់ចុះ ដូចជា ថ្លៃលោហធាតុធ្លាក់ចុះ 30 ភាគរយចាប់តាំងពីខែកុម្ភៈ ឆ្នាំ 2011 ដែលថ្លៃលោហធាតុបានឡើងខ្ពស់បំផុត។

9- **ថ្លៃទំនិញត្រូវបានគេរំពឹងថា នឹងបន្តធ្លាក់ចុះក្នុងរយៈពេលមធ្យម។** ធនាគារពិភពលោកព្យាករថ្លៃប្រេងមួយធុងថាធ្លាក់ចុះពី 102 ដុល្លារអាមេរិកនៅឆ្នាំ 2013 ដល់ 101 ដុល្លារអាមេរិកនៅឆ្នាំ 2014។ ដូចគ្នាដែរថ្លៃលោហធាតុត្រូវបានរំពឹងថានឹងធ្លាក់ចុះក្នុងន័យពិត 3,7 និង 1,4 ភាគរយនៅក្នុងឆ្នាំ 2013 និង 2014។ ថ្លៃស្បៀងក៏ត្រូវបានព្យាករថាធ្លាក់ចុះផងដែរ (7,7, 6,0 និង 5,5 ភាគរយជាង 2013-15), សឱ្យឃើញពីភាពប្រសើរឡើងបន្តិចម្តងៗនៃស្ថានភាពផ្គត់ផ្គង់និងកាត់បន្ថយចំណាយផលិតកម្មដោយសារថាមពល និងជីមានតម្លៃថោក។

10- **ការធ្លាក់ចុះនៃថ្លៃទំនិញត្រូវបានគេចាត់ទុកថា ជាហានិភ័យថ្មី។** ខណៈដែលថ្លៃទំនិញធ្លាក់ចុះនាំមកនូវផលចំណេញដល់ផលិតផលក្នុងស្រុកសរុបជាសកលក្តី សភាពការណ៍នេះអាចធ្វើឱ្យភាពតានតឹងដល់គណនីចរន្ត និងតុល្យការសារពើពន្ធរបស់ក្រុមហ៊ុននាំទំនិញចេញ។ ការធ្លាក់ចុះថ្លៃទំនិញឧស្សាហកម្មកាលពីពេលថ្មីៗ អាចជាសញ្ញាបញ្ជាក់ថាជាចុងបញ្ចប់នៃដំណាក់កាលឡើងថ្លៃនៃវដ្តទំនិញ។ អ្នករៀបចំគោលនយោបាយ នៅក្នុងប្រទេសនាំទំនិញចេញចាំបាច់ត្រូវមើលឱ្យបានដិតដល់ចំពោះផលវិបាកដែលអាចកើតមាន អំពីនៃការធ្លាក់ថ្លៃទំនិញខ្លាំងជាងការរំពឹងទុកចំពោះកំណើនសេដ្ឋកិច្ច ហិរញ្ញវត្ថុរដ្ឋាភិបាល និងតម្រូវការហិរញ្ញប្បទានពីបរទេស។ ទោះជាយ៉ាងណាក្តីប្រសិនបើសហរដ្ឋអាមេរិកឈប់ប្រើគោលនយោបាយរូបិយវត្ថុពិសេស ស្ថានភាពផ្ទុយពីនេះអាចកើតឡើង។

# គ- សេដ្ឋកិច្ចកម្ពុជា

## វិស័យផលិត

11- **លទ្ធភាពឆ្លើយតបនឹងការព្យាករកំណើន 7 ភាគរយនៅឆ្នាំ 2013 ហាក់ដូចជាមានលក្ខណៈអំណោយផល។** សេដ្ឋកិច្ចកម្ពុជានៅតែរឹងមាំ ហើយទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចជារួមនៅតែជាវិជ្ជមាន ខណៈដែលកំណើនកសិកម្មមាននិរន្តរភាពជាតុអាកាសមានលក្ខណៈអំណោយផល វិស័យទេសចរណ៍បន្តអនុវត្តបានល្អប្រសើរ និងវិស័យកាត់ដេរដែលរឹងមាំ។ កំណើនកសិកម្ម ដែលមានចីរភាពបានជួយទប់វិបត្តិផ្សេងៗ ខណៈដែល ការនាំចេញសម្លៀកបំពាក់សម្របខ្លួនបានល្អ បានងើបឡើងវិញយ៉ាងឆាប់រហ័ស ហើយទីផ្សារទេសចរណ៍បានធ្វើពិពិធកម្ម ប្រកបដោយជោគជ័យគាំទ្រដល់កំណើនវិស័យទេសចរណ៍ដ៏រឹងមាំ៖ទាំងនេះគឺជាមូលហេតុដែលធ្វើឱ្យសេដ្ឋកិច្ចចាកចេញយ៉ាងឆាប់រហ័ស ពីវិបត្តិសេដ្ឋកិច្ចសកលនាឆ្នាំ 2008 - 2009។ ទោះជាយ៉ាងណាក្តី តទៅថ្ងៃមុខយ៉ាងណានោះ អាស្រ័យលើបរិយាកាសក្រៅស្រុកដែលនៅតែមានលក្ខណៈផុយស្រួយ បើទោះបីជាតុល្យការហានិភ័យមិនសូវមានរបាំងនាំទៅរកការធ្លាក់ចុះក្តី និងអាស្រ័យលើបរិយាកាសនយោបាយក្នុងស្រុក ដោយសារភាពមិនច្បាស់លាស់បន្ទាប់ពីការបោះឆ្នោតសកលនៅខែកក្កដា ឆ្នាំ 2013។ បើនិយាយអំពីការរួមចំណែកតាមវិស័យវិញ វិស័យកសិកម្មបានរួមចំណែកចំពោះកំណើន ផសស ពិត 15,0 ភាគរយនៅឆ្នាំ 2012 ធៀបនឹង 11,3 ភាគរយនៅឆ្នាំ 2011 និង 18,3 ភាគរយនៅឆ្នាំ 2010។ ការរួមចំណែករបស់វិស័យឧស្សាហកម្មចំពោះ ផសស ពិត 35,6 ភាគរយ នៅឆ្នាំ 2012 បានធ្លាក់ចុះពី 54,9 ភាគរយនៅឆ្នាំ 2011 និង 56,5 ភាគរយនៅឆ្នាំ 2010។ ការរួមចំណែករបស់វិស័យសេវាកម្មចំពោះកំណើន ផសស ពិត ស្មើនឹង 42,5 ភាគរយនៅក្នុងឆ្នាំ 2012 បានកើនឡើងពី 26,8 ភាគរយនៅឆ្នាំ 2011 និង 21,7 ភាគរយនៅឆ្នាំ 2010។

**កំណើនផសសពិត** ( % ធៀបនឹងឆ្នាំមុន )




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**ការរួមចំណែកចំពោះផសសពិត** (ជាភាគរយ)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

## កសិកម្ម

12- **កំណើនវិស័យកសិកម្មត្រូវបានគេប៉ាន់ប្រមាណថា នៅតែមាននិរន្តរភាពនៅឆ្នាំ 2013 ដោយសារតែស្ថានភាពអាកាសធាតុអំណោយផល។** នៅចុងខែសីហា ឆ្នាំ 2013 ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបានរាយការណ៍ថាផ្ទៃដីគ្រោងដាំស្រូវកើនឡើង 11 ភាគរយធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ កំណើនវិស័យកសិកម្មគិតតាមតំលៃថេរស្មើនឹង 4,3 ភាគរយនៅឆ្នាំ 2012 ធៀបនឹង 3,1 ភាគរយនិង 4,0 ភាគរយឆ្នាំ 2011 និងឆ្នាំ 2010។ ផលិតកម្មកសិកម្មចម្បងគឺដំណាំស្រូវដែលនៅតែបន្តរួមចំណែកប្រកបដោយចីរភាពប្រមាណជា 10 ភាគរយនៃកំណើនពិតសរុបក្នុងអំឡុងបីឆ្នាំចុងក្រោយ (2010-2012)។ *ដោយសារវិស័យកសិកម្មមានកំណើនប្រកបដោយចីរភាព បន្ទាប់ពីមានការវិនិយោគលើវិស័យកសិកម្ម និងប្រព័ន្ធធារាសាស្ត្រអស់រយៈពេលជាច្រើនឆ្នាំ បច្ចុប្បន្នកំណើនពិតមួយផ្នែកធំទទួលឥទ្ធិពលពីវិស័យកាត់ដេរ និងទេសចរណ៍។*

**ការមកដល់នៃភ្ញៀវទេសចរណ៍ ការនាំចេញសម្លៀកបំពាក់ និងកំណើនពិត** (គិតជាភាគរយ)




ប្រភព៖ អាជ្ញាធរកម្ពុជា

## ផលិតកម្មស្រូវ

13- **ការរួមចំណែកពីការពង្រីកផ្ទៃដីដាំស្រូវរហូតដល់ 80 ភាគរយនៃកំណើនផលិតកម្មស្រូវប្រចាំឆ្នាំ ក្នុងអំឡុងបួនឆ្នាំចុងក្រោយ។** ចំណែកឯ 20 ភាគរយទៀត កើនឡើងដោយសារទិន្នផល។ ការអភិវឌ្ឍដ៏សំខាន់មួយគឺការកើនឡើងនូវការរួមចំណែកនៃផលិតកម្មស្រូវប្រាំង (ដោយសារមានប្រព័ន្ធធារាសាស្ត្រប្រើប្រាស់នៅរដូវប្រាំង)ដែលបានកើនឡើងជាលំដាប់ដល់ 23,3 ភាគរយនៃផលិតកម្មស្រូវសរុបប្រចាំឆ្នាំនៅឆ្នាំ 2012 ពី 18,5 ភាគរយនៅក្នុងឆ្នាំ 2003។ ការដាំដំណាំស្រូវប្រាំងដែលមិនសូវពឹងផ្អែកលើធាតុអាកាស មានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យផលស្រូវប្រចាំឆ្នាំមានស្ថេរភាព។

**ផលិតកម្មស្រូវ**

(គិតជាលានតោន និង % ប្រែប្រួលនៃផលិតកម្មស្រូវសរុបធៀបនឹងឆ្នាំមុន)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

14- **ដោយសារតែសមត្ថភាពកិនស្រូវ និងការផ្តល់ហិរញ្ញប្បទានមានភាពទន់ខ្សោយ ភាគច្រើនប្រទេសកម្ពុជា នាំចេញស្រូវដែលលើសពីតម្រូវការក្នុងស្រុកទៅបរទេស (មិនបានកិនឱ្យទៅជាអង្ករ)។** ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានប៉ាន់ស្មានថាកម្ពុជាមានស្រូវលើសពីសេចក្តីត្រូវការប្រើប្រាស់ក្នុងស្រុកចំនួន 4,7 លានតោនក្នុងឆ្នាំ 2012 មិនគិតបញ្ចូលនូវការនាំចេញស្រូវនោះទេ។ ក្នុងអំឡុងឆមាសទីមួយនៃឆ្នាំ 2013 ការនាំចេញអង្ករបានកើនឡើងច្រើនជាងទ្វេដងធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនកើនដល់ 185 ពាន់តោន និងលក់បានប្រាក់ 136 លានដុល្លារ កើនឡើង 28 ភាគរយធៀបនឹងឆ្នាំមុន[7]។ ការនាំចេញអង្ករ ភាគច្រើនទៅកាន់ទ្វីបអឺរ៉ុប បានទទួលអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងស្តីពីអ្វីគ្រប់យ៉ាងលើកលែងតែអាវុធ ក្រោមកម្មវិធីអនុគ្រោះទូទៅរបស់សហភាពអឺរ៉ុប[8]។ នៅឆ្នាំ 2010 រដ្ឋាភិបាលបន្តគោលនយោបាយអង្កររបស់ខ្លួន ដោយកំណត់ការនាំចេញអង្កររហូតដល់ 1 លានតោនត្រឹមឆ្នាំ 2015។ ចាប់តាំងពីពេលនោះមកហិរញ្ញប្បទានទាំងផ្នែកសាធារណៈនិងឯកជនបានផ្តល់ទៅឱ្យវិស័យកសិកម្មនិងការកែច្នៃកសិកម្ម។ ឥណទានសរុបផ្តល់ដោយប្រព័ន្ធធនាគារដល់វិស័យកសិកម្មនិងការកែច្នៃកសិកម្មបានកើនឡើងច្រើនជាងពីរដង គឺកើនឡើងដល់ 573 លានដុល្លារអាមេរិកក្នុងឆ្នាំ 2012 ពី 221 លានដុល្លារអាមេរិកនៅឆ្នាំ 2010[9]។

---

7 *ទិន្នន័យនាំចេញស្រូវ ខែមិថុនា ឆ្នាំ2013-ក្រសួងពាណិជ្ជកម្ម*

8 *កិច្ចព្រមព្រៀងនេះផ្តល់"រង្វាន់" ប្រហែល175EURក្នុងការនាំចេញអង្ករមួយតោន*

9 *របាយការណ៍ប្រចាំឆ្នាំ2012 របស់ធនាគារជាតិនៃកម្ពុជា*

# វិស័យកាត់ដេរ

15- កំណើននៃការនាំចេញសម្លៀកបំពាក់កើនឡើងបន្ថែមទៀតនៅក្នុងឆមាសទីមួយនៃឆ្នាំ 2013 ឡើងដល់ 18 ភាគរយធៀបនឹងឆ្នាំមុន។ ឧស្សាហកម្មនាំចេញសម្លៀកបំពាក់បានសម្របទៅនឹងស្ថានភាពទីផ្សារនាំចេញ ដើម្បីបង្កើនការនាំចេញ។ *យុទ្ធសាស្ត្រនាំចេញដោយផ្តោតលើផលិតផលសម្លៀកបំពាក់ដែលមានតម្លៃថោក សម្រាប់ទីផ្សារសហរដ្ឋអាមេរិក និងផលិតផលដែលមានតម្លៃខ្ពស់សម្រាប់ទីផ្សារសហភាពអឺរ៉ុប ដោយមានឧត្តមភាពប្រៀបធៀបដោយសារកំលាំងពលកម្មមានតម្លៃថោកធ្វើឱ្យឧស្សាហកម្មនេះ រីកចម្រើន។* ការនាំចេញសម្លៀកបំពាក់បានកើនឡើង 7 ភាគរយនិង 31 ភាគរយធៀបនឹងឆ្នាំមុននៅឆ្នាំ 2012 និង 2011។

**ការនាំចេញសម្លៀកបំពាក់**

(ពីដើមឆ្នាំដល់បច្ចុប្បន្នគិតជាលានដុល្លារអាមេរិក(ឆ្វេង) និងបម្រែបម្រួល%មធ្យមភាគ12ខែធៀបនឹងឆ្នាំមុន(ស្តាំ))




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

16- **សហរដ្ឋអាមេរិក នៅតែជាគោលដៅទីផ្សារនាំចេញសម្លៀកបំពាក់ធំបំផុតរបស់ប្រទេសកម្ពុជា ប៉ុន្តែចំណែកភាគរយទៅកាន់ទីផ្សារនេះបន្តធ្លាក់ចុះ។** ទីផ្សារសហរដ្ឋអាមេរិកបានស្រូបយក 1.930,5 លានដុល្លារអាមេរិក (ឬ 45 ភាគរយ) នៃការនាំចេញសម្លៀកបំពាក់សរុបចំនួន 4.274 លានដុល្លារនៅឆ្នាំ 2012 (សូមមើលតួលេខខាងលើ)។ ទីផ្សារសហភាពអឺរ៉ុបគឺជាទីផ្សារលំដាប់ទីពីរ ស្រូបយក 1.409,8 លានដុល្លារអាមេរិក (ឬ 33 ភាគរយ)។ ដោយទទួលបានផលប្រយោជន៍ពីកិច្ចព្រមព្រៀងអ្វីៗទាំងអស់លើកលែងតែអាវុធ ក្រោមការអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុប ចំណែកភាគរយនៃការនាំចេញសម្លៀកបំពាក់របស់កម្ពុជា ទៅកាន់ទីផ្សារសហភាពអឺរ៉ុបបានកើនឡើងយ៉ាងឆាប់ គឺស្រូបយក 33 ភាគរយនៅឆ្នាំ 2012 កើនពី 29 ភាគរយនៅឆ្នាំ 2011 និង 23 ភាគរយនៅឆ្នាំ 2010 ខណៈពេលដែលចំណែកភាគរយនៃការនាំចេញសម្លៀកបំពាក់របស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកបានធ្លាក់ចុះពី 60 ភាគរយនៅឆ្នាំ 2010 ដល់ 51 ភាគរយនៅឆ្នាំ 2011 និង 45 ភាគរយនៅឆ្នាំ 2012។ ប្រទេសជប៉ុនបានក្លាយជាគោលដៅទីផ្សារនាំចេញសម្លៀកបំពាក់យ៉ាងឆាប់ហើស សម្រាប់ប្រទេសកម្ពុជា ហើយទីផ្សារជប៉ុនបានស្រូបយក 137 លានដុល្លារអាមេរិកក្នុងការនាំចេញសម្លៀកបំពាក់នៅឆ្នាំ 2012 ធៀបនឹងបរិមាណទឹកប្រាក់ត្រឹមតែ 24 លានដុល្លារអាមេរិកប៉ុណ្ណោះនៅឆ្នាំ 2010។ បើគិតជាបរិមាណ ចំណែកភាគរយនៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកក៏បានធ្លាក់ចុះពី 68 ភាគរយក្នុងឆ្នាំ 2010 ទៅ 60 ភាគរយក្នុងឆ្នាំ 2011 និង 53 ភាគរយក្នុងឆ្នាំ 2012 ផងដែរ។ ផ្ទុយមកវិញចំណែកភាគរយនៃ

## ប្រអប់លេខ 1- ការនាំចូលក្រណាត់និងការនាំចេញសម្លៀកបំពាក់

**ការនាំចូលនៃក្រណាត់ ដែលជាសូចនាករឈានមុខគេសម្រាប់ការផលិត និងការនាំចេញសម្លៀកបំពាក់បន្តកើនឡើងចាប់តាំងពីមានវិបត្តិសេដ្ឋកិច្ចសកលឆ្នាំ2008 - 2009។** នៅឆ្នាំ 2012 ការនាំចូលក្រណាត់គិតជាទឹកប្រាក់បានកើន 20 ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ ការគាំទ្រដល់កំណើននៃការនាំចេញសម្លៀកបំពាក់ប្រមាណជា 10 ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ និងភាគរយនៃការប្រែប្រួលការនាំចូលក្រណាត់ដើរទន្ទឹមគ្នា ជាមួយការនាំចេញសម្លៀកបំពាក់ (សូមមើលរូបខាងក្រោមនេះ) ។ ការណ៍នេះឆ្លុះបញ្ចាំងអវត្តមាននៃវត្ថុធាតុដើម ជំនួសការនាំចូលសម្រាប់វិស័យកាត់ដេរ ហេតុនេះហើយទើបបានជាផលប្រយោជន៍បន្ថែមពីខ្សែសង្វាក់តម្លៃនៃផលិតផលសម្លៀកបំពាក់ នៅតែមិនអាចអនុវត្តបាន។

**ការនាំចូលក្រណាត់ និងការនាំចេញសម្លៀកបំពាក់**

(គិតជាលានដុល្លារ)




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

ការនាំចេញសម្លៀកបំពាក់ទៅទីផ្សារអឺរ៉ុបបានកើនឡើងដល់ 26 ភាគរយនៅឆ្នាំ 2012 គឺកើនពី 24 ភាគរយនៅឆ្នាំ 2011 និង 18 ភាគរយនៅឆ្នាំ 2010 (សូមមើលរូបខាងក្រោម)។

**ការនាំចេញសម្លៀកបំពាក់**

(ពីដើមឆ្នាំដល់បច្ចុប្បន្នគិតជាឡាត់ (ឆ្វេង) និង បម្រែបម្រួល%មធ្យមភាគ12ខែធៀបនឹងឆ្នាំមុន(ស្តាំ))




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

# សំណង់ និងអចលនទ្រព្យ

17- **ការវិនិយោគដែលបានអនុម័តក្នុងវិស័យសំណង់បានកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងឆមាសទីមួយនៃឆ្នាំ 2013**[10]។ ការអនុម័តគម្រោងសំណង់ប្រចាំខែ បានកើនឡើងយ៉ាងខ្ពស់ក្នុងខែមិថុនា ឆ្នាំ 2013 ឡើងដល់ 1,4 ពាន់លានដុល្លារអាមេរិកគឺពី 126 លានដុល្លារអាមេរិកក្នុងខែមករាឆ្នាំ 2013 ធ្វើឱ្យការអនុម័តលើការវិនិយោគសរុបលើវិស័យសំណង់ក្នុងអំឡុងពេលប្រាំមួយខែដំបូងឡើងដល់ 1,93 ពាន់លានដុល្លារអាមេរិក។ ខណៈពេលដែលសកម្មភាពសំណង់ និងអចលនវត្ថុប្រមូលផ្តុំភាគច្រើននៅក្នុងតំបន់លំនៅដ្ឋាន និងតំបន់ពាណិជ្ជកម្មដែលមានទំហំតូចនិងរាយប៉ាយ ការអភិវឌ្ឍចុងក្រោយបំផុតបង្ហាញថានៅពាក់កណ្តាលឆ្នាំ 2013 គេឃើញមានសញ្ញាដំបូងនៃពពុះ(ភាពផុយស្រួយ)ក្នុងវិស័យអចលនវត្ថុនៅតំបន់ទីក្រុង ហើយឥណទានក្នុងស្រុកបានដើរតួនាទីកាន់តែសំខាន់ ក្នុងការផ្តល់ហិរញ្ញប្បទានដល់វិស័យនេះ។

**ការឯកភាពលើគម្រោងសាងសង់ប្រចាំខែ**




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ទេសចរណ៍

18- **ការមកដល់នៃភ្ញៀវទេសចរ ក្នុងអំឡុងពេលប្រាំខែដំបូងនៃឆ្នាំ 2013 បានឡើងដល់ 1,79 លាននាក់ឬកំណើន 19 ភាគរយធៀបនឹងឆ្នាំមុន។** ចំនួនភ្ញៀវទេសចរតំណាងឱ្យលទ្ធផលអនុវត្តនៃវិស័យ ទេសចរណ៍ បានបង្ហាញនូវការងើបឡើងវិញយ៉ាងឆាប់រហ័ស ហើយឥឡូវនេះ បន្តមានគន្លងកំណើនខ្ពស់។ ការមកដល់នៃភ្ញៀវទេសចរបានឡើងដល់ 3,58 លាននាក់ មានកំណើនធៀបនឹងឆ្នាំមុនចំនួន 24 ភាគរយនៅឆ្នាំ 2012 ធៀបនឹងកំណើន 15 ភាគរយក្នុងឆ្នាំ 2011។ ពិពិធកម្មជោគជ័យក្នុងទីផ្សារទេសចរណ៍ ទាក់ទាញការមកដល់នៃភ្ញៀវពីតំបន់អឺរ៉ុបខាងកើត អាស៊ីបូព៌ានិងតំបន់ប៉ាស៊ីហ្វិកធ្វើឱ្យវិស័យទេសចរណ៍បន្តមានកំណើនខ្ពស់។ ការបង្កើតជើងហោះហើរថ្មី ដោយផ្ទាល់ពីតំបន់ផ្សេងគ្នានៃពិភពលោក ក៏ធ្វើឱ្យការមកដល់នៃភ្ញៀវទេសចរតាមជើងអាកាសមានកំណើនកាន់តែខ្ពស់ធៀបនឹងឆ្នាំមុន (ដែលត្រូវបានគេមើលឃើញថាជា "កំណើនមានគុណភាព" នៃវិស័យទេសចរណ៍) ពី 13,5 ភាគរយក្នុងឆ្នាំ 2011 ដល់ 16,3 ភាគរយក្នុងឆ្នាំ 2012។ កំណើនខ្ពស់នៅក្នុងវិស័យទេសចរណ៍ធ្វើឱ្យអនុវិស័យផ្នែកពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋានរួមបញ្ចូលគ្នា រួមចំណែកច្រើនជាង 15 ភាគរយដល់កំណើនពិតសរុបក្នុងអំឡុងឆ្នាំ 2010 - 2012។

**ការមកដល់នៃភ្ញៀវទេសចរ**

(ពីដើមឆ្នាំដល់បច្ចុប្បន្នគិតជាលាននាក់ (ឆ្វេង) និង បម្រែបម្រួល % មធ្យមភាគ12ខែធៀបនឹងឆ្នាំមុន (ស្តាំ))




ប្រភព៖ ក្រសួងទេសចរណ៍

---

10 *គំរោងសាងសង់ដែលអនុម័តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់*

## ឱកាសការងារនិងថ្លៃពលកម្ម

19- **វិស័យកសិកម្មផ្តល់ការងាររហូតដល់ 55,8 ភាគរយនៃចំនួនប្រជាពលរដ្ឋសរុបដែលមានការងារធ្វើ (7,9 លាននាក់ក្នុងចំណោម 14,1 លាននាក់)**[11] **។** *ក្នុងចំនួនការងារសរុបនៅជនបទ វិស័យកសិកម្មផ្តល់ការងារ 66,7 ភាគរយ ចំណែកឯចំណែកផ្សេងពីនេះ ការងារត្រូវបានផ្តល់ស្មើតែស្មើគ្នាដោយវិស័យឧស្សាហកម្មនិងសេវាកម្ម។* សភាពការណ៍នេះរំលឹកអ្នករៀបចំគោលនយោបាយវិស័យកសិកម្មថា មិនគួរយកចិត្តទុកដាក់តែទៅលើវិស័យកសិកម្មឡើយ នៅពេលដែលនិយាយដល់ការលើកកំពស់ស្ថានភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។

20- **វិស័យឧស្សាហកម្មកំពុងស្រូបយកសមាមាត្រកម្លាំងពលកម្មកាន់តែច្រើនឡើងៗ។** វិស័យនេះផ្តល់ការងាររហូតដល់ 16,9 ភាគរយនៃការងារសរុបនៅក្នុងឆ្នាំ 2011 ធៀបទៅនឹង 13,3 ភាគរយប៉ុណ្ណោះនៅឆ្នាំ 2004។ *ចំណែកភាគរយនៃការងារដែលផ្តល់ដោយវិស័យឧស្សាហកម្ម នៅក្នុងរាជធានីភ្នំពេញបានកើនឡើងយ៉ាងឆាប់រហ័ស (កើនឡើងជិតមួយភាគរយក្នុងមួយឆ្នាំ) ពី 17,8 ភាគរយនៅក្នុងឆ្នាំ 2004 រហូតដល់ 24 ភាគរយនៅក្នុងឆ្នាំ 2011។* ប្រការនេះបង្ហាញបំលាស់ប្តូរមួយឆ្ពោះទៅកាន់ "ឧស្សាហូបនីយកម្ម" នៅក្នុងរាជធានីដែលគាំទ្រដោយចំណាកស្រុកដើម្បីរកការងារធ្វើ ពីជនបទមកកាន់រាជធានី។ នៅតាមជនបទចំណែកភាគរយនេះក៏កើនឡើងផងដែរ ប៉ុន្តែមានល្បឿនតិចជាងនេះឆ្ងាយណាស់ ពោលគឺឡើងដល់ 16 ភាគរយក្នុងឆ្នាំ 2011 ពី 13 ភាគរយនៅឆ្នាំ 2004 ដោយមានន័យថាដំណើរការឧស្សាហូបនីយកម្មនៅក្នុងតំបន់ជនបទមានល្បឿនយឺតជាងដំណើរការ ឧស្សាហូបនីយកម្មនៅក្នុងតំបន់រាជធានីយ៉ាងច្រើន។

**ការងារដែលផ្តល់ដោយវិស័យឧស្សាហកម្ម និងតាមតំបន់** (%នៃចំនួនការងារសរុប)




ប្រភព៖ អង្កេតសេដ្ឋកិច្ចសង្គមកិច្ច2011-វិទ្យាស្ថានជាតិស្ថិតិ

11 *អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច 2011 នៃវិទ្យាស្ថានជាតិ ស្ថិតិ*

21- **ចំណែក ភាគរយការងារនៃវិស័យសេវាកម្មបានប្រែប្រួលតែបន្តិចប៉ុណ្ណោះ ពោលគឺថយចុះដល់ 27,3 ភាគរយនៅឆ្នាំ** 2011 ពី 29,1 **ភាគរយនៅឆ្នាំ** 2004។ វិស័យសេវាកម្មបន្តផ្តល់ការងារប្រកបដោយចីរភាពប្រមាណជា 17 ភាគរយ ដល់តំបន់ជនបទ រីឯចំណែកភាគរយផ្តល់ការងារបានធ្លាក់ចុះជាបន្តបន្ទាប់នៅតំបន់ទីក្រុង ជាពិសេសរាជធានីភ្នំពេញ ធ្លាក់ដល់ 73,7 ភាគរយនៅឆ្នាំ 2011 ពី 80,9 ភាគរយនៅឆ្នាំ 2004។

22- **កាលពីពេលកន្លងទៅថ្មីៗនេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មកររោងចក្រកាត់ដេរបានកើនឡើង 31 ភាគរយ បន្ទាប់ពីបានកើនឡើង 22 ភាគរយនៅក្នុងឆ្នាំ 2010។** ចាប់ពីខែឧសភា ឆ្នាំ 2013 មក ប្រាក់ខែអប្បបរមាប្រចាំខែគឺ 80 ដុល្លារអាមេរិក ធៀបនឹង 61 ដុល្លារអាមេរិក នៅខែកក្កដា ឆ្នាំ 2010 និង 50 ដុល្លារអាមេរិក ដែលចាប់ផ្តើមពីឆ្នាំ 2008 [12]។ ស្ថានភាពនេះហាក់បីដូចជា ផ្ទុយទៅនឹងការថយចុះនៃថ្លៃពលកម្មដែលបានអង្កេតកញ្ចប់អតិផរណាប្រចាំខែ ដែលនៅតែមានកម្រិតទាប ចាប់តាំងពីមានវិបត្តិហិរញ្ញវត្ថុសកល (សូមមើលរូបខាងក្រោមនេះ)។

**ថ្លៃពលកម្មមួយចំនួន**

(%ប្រែប្រួលធៀបនឹងឆ្នាំមុន)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

12 *ខណៈដែលប្រាក់ឈ្នួលអប្បរមាមានកម្រិតទាប ផលិតភាពរបស់កម្ពុជា (លទ្ធផលការងាររបស់កម្មករម្នាក់ = តម្លៃបន្ថែមរបស់កម្មម្នាក់ដែលត្រូវបានផ្តល់ការងារ) មានកម្រិតទាបជាងយ៉ាងច្រើនធៀបនឹងប្រទេសជិតខាង។ លទ្ធផលការងាររបស់កម្មករម្នាក់ស្មើនឹងប្រមាណជាពាក់កណ្តាលធៀបនឹងប្រទេសវៀតណាម និងស្មើត្រឹមតែមួយភាគប្រាំធៀបនឹងប្រទេសថៃ។ សូមអានបន្ថែមឯកសារដែលមានចំណងជើងថា 2010 Labor and Social Trends in Cambodia របស់អង្គការពលកម្មអន្តរជាតិនិងវិទ្យាស្ថានជាតិស្ថិតិ។*

# ជញ្ជីងពាណិជ្ជកម្ម

## ការនាំចេញ

23- **ដោយសារការបង្កើនល្បឿនការនាំចេញសម្លៀកបំពាក់បន្ថែមទៀត ការនាំចេញសរុបត្រូវបានព្យាករថានឹងកើនឡើងនៅឆ្នាំ** 2013។ ការនាំចេញទំនិញត្រូវបានព្យាករថាកើនឡើង 15 ភាគរយ ធៀបនឹងឆ្នាំមុនក្នុងឆ្នាំ 2013 ធៀបនឹង 11,4 ភាគរយក្នុងឆ្នាំ 2012។ ការនាំចេញផលិតផលសម្លៀកបំពាក់ស្មើនឹង 75 ភាគរយនៃការនាំចេញក្នុងស្រុកសរុបនៅឆ្នាំ 2012។ ការនាំចេញស្បែកជើងនិងផលិតផលកសិកម្មដូចជាកៅស៊ូ និងអង្ករកំពុងកើនឡើង ប៉ុន្តែនៅមានទំហំតិច។ ការនាំចេញដែលបានធ្លាក់ចុះ 14 ភាគរយនៅឆ្នាំ 2008 បានកើនឡើងវិញយ៉ាងឆាប់រហ័សចាប់តាំងពីមានវិបត្តិសេដ្ឋកិច្ចសកល និងបានកើនឡើង 30 ភាគរយ និង 34,4 ភាគរយធៀបនឹងឆ្នាំមុននៅឆ្នាំ 2010 និងឆ្នាំ 2011។

**បរិមាណនាំចេញសរុប**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ការនាំចូល

24- **នៅឆ្នាំ 2013 កំណើននាំចូលត្រូវបានព្យាករណ៍ថាមានកម្រិតបង្គួរ។** ការនាំចូលទំនិញនៅឆ្នាំ 2013 ត្រូវបានព្យាករថានឹងកើនឡើង 13 ភាគរយធៀបនឹងឆ្នាំមុន ធៀបនឹង 18,7 ភាគរយនៅឆ្នាំ 2012 ដោយសារការនាំចូលទំនិញប្រើប្រាស់តិច។ ក្រណាត់សម្រាប់ផលិតសម្លៀកបំពាក់ ប្រេងឥន្ធនៈ យានយន្ត និងសម្ភារសំណង់នៅតែជាមុខទំនិញនាំចូលចំបង ស្មើនឹងប្រមាណជា 50 ភាគរយនៃការនាំចូលសរុប។ ការនាំចូលក្រណាត់មានចំនួនប្រហែល 30 ភាគរយនៃការនាំចូលសរុប ខណៈដែលការនាំចូលប្រេងឥន្ធនៈមានចំនួន 15 ភាគរយនៃបរិមាណនាំចូលសរុប។ ផលិតផលនាំចូលសំខាន់ៗផ្សេងទៀតរួមមានថ្នាំពេទ្យស្បៀងអាហារ បារី ដី ភេសជ្ជៈ គ្រឿងអេឡិចត្រូនិក និងប្រដាប់ប្រដារប្រើប្រាស់ក្នុងគ្រួសារ។

**បរិមាណនាំចូលសរុប** (គិតជាលានដុល្លារ)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ផលិតផលនាំចូលសំខាន់ៗ**

(គិតជាពាន់លានរៀលនិង%នៃតួលេខសរុបឆ្នាំ2012)




## ជញ្ជីងពាណិជ្ជកម្ម

25- **ជាមួយនឹងការនាំចូលសមល្មមនិងការនាំចេញដ៏ច្រើន ឱនភាពពាណិជ្ជកម្មនៅឆ្នាំនេះនឹងមានទំហំតូច (តាមន័យធៀប)។** ឱនភាពពាណិជ្ជកម្មនេះត្រូវបានព្យាករថា មានកម្រិតប្រមាណជា 13 ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ 2013 ធៀបនឹង 14 ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ 2012។ ការកើនឡើងនូវឱនភាពពាណិជ្ជកម្មក្នុងឆ្នាំ 2012 គឺដោយសារការកំណើននៃការនាំចូលខ្ពស់ស្មើនឹង 15 ភាគរយ ខណៈពេលដែលការនាំចេញបានកើនឡើងតែ 11,4 ភាគរយប៉ុណ្ណោះ។ កំណើនការនាំចូលត្រូវបាននាំមុខ ជាចម្បងដោយការនាំចូលប្រេងឥន្ធនៈកើនឡើង 15 ភាគរយ ការនាំចូលយានយន្តកើនឡើង 36 ភាគរយ និងការនាំចូលសម្ភារសំណង់កើនឡើង 35 ភាគរយ។

**ជញ្ជីងពាណិជ្ជកម្ម សេវាសុទ្ធ និងចំណូលសុទ្ធ**
(គិតជាភាគរយនៃផសស)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**តុល្យការរួម**
(គិតជាភាគរយនៃផសស)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## *គណនីចរន្ត និងតុល្យការមូលធន*

26- ឱនភាពគណនីចរន្តត្រូវបានគេព្យាករថា មានទំហំកាន់តែតូច។ ឱនភាពគណនីចរន្តឆ្នាំនេះ មិនរួមបញ្ចូលបង្វែរផ្លូវការ មានទំហំប្រហែល 9 ភាគរយនៃផលិតផលក្នុងស្រុកសរុប ធៀប 10,1 ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ 2012។ នៅមានអតិរេកគណនីមូលធន និងហិរញ្ញវត្ថុជាបន្ត ដោយសារវិនិយោគផ្ទាល់ពីបរទេស នៅតែមាននិរន្តរភាពក្នុងឆមាសទីមួយនៃឆ្នាំ 2013 ហើយជញ្ជីងទូទាត់ជារួមនៅតែវិជ្ជមាន អមដោយការកើនឡើងនូវទុនបម្រុងអន្តរជាតិ។ ត្រឹមខែមិថុនា ឆ្នាំ 2013 ទុនបម្រុងអន្តរជាតិបានកើនដល់ 3,6 ពាន់លានដុល្លារអាមេរិក ធៀបនឹង 3,5 ពាន់លានដុល្លារអាមេរិកនៅចុងឆ្នាំ 2012។ វិនិយោគផ្ទាល់ពីបរទេសបានបន្តកើនឡើងនៅឆមាសទីមួយនៃឆ្នាំ 2013 ហើយវិនិយោគិនទំនងជាមានការចាប់អារម្មណ៍ច្រើនក្នុងអំឡុងពេលការបោះឆ្នោតនេះ មិនដូចក្នុងការបោះឆ្នោតកាលពីលើកមុន។ គេនៅមិនដឹងច្បាស់នៅឡើយ អំពីទំហំនៃផលប៉ះពាល់នៃភាពមិនប្រាកដប្រជាផ្នែកនយោបាយក្រោយការបោះឆ្នោតមកលើការវិនិយោគដោយផ្ទាល់ពីបរទេសយ៉ាងណានោះទេ។

27- **បើប្រៀបធៀបជាមួយបណ្ដាប្រទេសដទៃទៀតនៅក្នុងតំបន់ កម្ពុជានៅតែមានឱនភាពធំលើគណនីចរន្ត គិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក។** ឱនភាពគណនីចរន្តដែលមានទំហំធំនេះជាការចាំបាច់ ដើម្បីជួយជម្រុញការវិនិយោគ និងកំណើន រហូតទាល់តែប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុកអាចរ៉ាប់រងបានកាន់តែពេញលេញ។ ទោះជាយ៉ាងណាក្ដី សភាពការណ៍នេះក៏បង្កើនភាពងាយរងគ្រោះរបស់កម្ពុជាហើយកម្ពុជាងាយនឹងរងគ្រោះពីវិបត្តិខាងក្រៅផងដែរ[13]។ ការកៀរគរប្រាក់កម្ចីផ្លូវការតាមវិស័យ និងការទាក់ទាញការវិនិយោគតាមវិស័យមិនផ្លូវការពិសេសការវិនិយោគពីបរទេស ជាវិធីដ៏មានប្រសិទ្ធិភាពនៃការរក្សាឱ្យបាននូវតុល្យភាពជារួមនៃជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាឱ្យមានលក្ខណៈវិជ្ជមាន។

---

*13 សេដ្ឋកិច្ចកម្ពុជាតូច បើកចំហ និងប្រើប្រាស់ប្រាក់ដុល្លារយ៉ាងច្រើន ជាសេដ្ឋកិច្ចដែលងាយមានភាពរងគ្រោះ និងងាយប្រឈមមុខនឹងវិបត្តិក្រៅប្រទេស។ ជាងនេះទៅទៀត នៅពេលមានឱនភាពគណនីចរន្តធំ សេដ្ឋកិច្ចនេះក៏ត្រូវមានអតិរេកគណនីមូលធនធំផងដែរដើម្បីធ្វើហិរញ្ញប្បទានលើឱនភាព។ ជាលទ្ធផល លំហូរចូលនូវមូលធន ពិសេសមូលធនដែលហូរចូលមកក្នុងវិនិយោគផ្ទាល់ពីបរទេស គឺជាការចាំបាច់ដើម្បីរក្សាអោយជញ្ជីងទូទាត់ជារួមមានលក្ខណៈវិជ្ជមាន។ កម្ពុជានាំចូលផលិតផលប្រេងឥន្ធនៈ100ភាគរយដែលត្រូវជា 15 ភាគរយនៃបរិមាណទឹកប្រាក់នាំចូលសរុប។*

**តុល្យការគណនីចរន្ត ការប្រៀបធៀបក្នុងតំបន់**

(គិតទាំងប្រាក់បង្វែរផ្លូវការ%នៃផសសឆ្នាំ 2011)




ប្រភព៖ សូចនាករអភិវឌ្ឍន៍ពិភពលោក ធនាគារពិភពលោក និងអាជ្ញាធរកម្ពុជា

## អតិផរណា

28- **នៅក្នុងខែមិថុនា ឆ្នាំ 2013 អតិផរណាធៀបនឹងឆ្នាំមុនបានកើនឡើងដល់ 2,9 ភាគរយដោយសារការកើនឡើងខ្លះៗនៃថ្លៃស្បៀងអាហារ**[14] ។ អតិផរណាត្រូវបានព្យាករថានៅតែមានកម្រិតទាបត្រឹមតួលេខមួយខ្ទង់ក្នុងរយៈពេលខ្លី។ បន្ទាប់ពីការឡើងថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ មុនពេលមានវិបត្តិហិរញ្ញវត្ថុសកល អតិផរណាបានធ្លាក់ចុះ និងបន្តធ្លាក់ចុះបន្ថែមទៀត។ នៅលើចុងឆ្នាំ 2012 អតិផរណាបានធ្លាក់ចុះ 2,5 ភាគរយ គឺធ្លាក់ពី 4,9 ភាគរយនៅឆ្នាំ 2011។ *ថ្លៃម្ហូបអាហារនិងថ្លៃប្រេងឥន្ធនៈបានកើនឡើង និងធ្លាក់ចុះច្រើនឬតិចស្របគ្នាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។* កសិកម្មទំនើបប្រើប្រាស់ផលិតផលប្រេង ដើម្បីចាក់ឱ្យគ្រឿងយន្តកសិកម្ម ដំណើរការដើម្បីផលិតជី និងដឹកជញ្ជូនឧបករណ៍ និងផលិតផលកសិកម្ម។ លើសពីនេះទៀតនៅពេលថ្លៃប្រេងកើនឡើង តម្រូវការជីវៈឥន្ធនៈដែលច្រើន តែផលិតចេញពីពោតនិងផលិតផលកសិកម្មដទៃទៀតកើនឡើង។

**អតិផរណា**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

29- **អត្រាអតិផរណា របស់បណ្តាប្រទេសនាំចូលចំបងៗរបស់ប្រទេសកម្ពុជារបស់នៅតែមានកម្រិតទាប។** *កម្ពុជាមានសេដ្ឋកិច្ចតូច និងបើកចំហ គឺជាប្រទេសទទួលយកថ្លៃដែលកំណត់ដោយទីផ្សារ អមជាមួយដុល្លូរូបនីយកម្មខ្ពស់ និងឱនភាពពាណិជ្ជកម្មធំ ធ្វើឱ្យអ្នករៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចស្ទើរតែគ្មានមូលដ្ឋានទប់ទល់នឹងអត្រាប្តូរប្រាក់ និងការនាំចូលអតិផរណា។* ហេតុនេះថ្លៃមានស្ថិរភាពនៅក្នុងប្រទេសដៃគូនាំចូលដ៏ចំបងៗរបស់កម្ពុជា នៅប៉ុន្មានឆ្នាំចុងក្រោយនេះ បានរួមចំណែក ធ្វើឱ្យមានអតិផរណាទាបនៅប្រទេសកម្ពុជា។

**អតិផរណាក្នុងតំបន់**

(%បម្រែបម្រួលធៀបនឹងឆ្នាំមុន)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

30- **សមាសភាគម្ហូបអាហារគឺជាកត្តាជំរុញចម្បងនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅប្រទេសកម្ពុជា។**សមាសភាគនេះតំណាង 43,3 ភាគរយ ក្នុងកញ្ចប់អតិផរណានៃទំនិញ និងសេវាកម្ម។ ការឡើងថ្លៃម្ហូបអាហារនៅក្នុងអំឡុងឆ្នាំ 2007 និងឆ្នាំ 2008 បានជំរុញដល់អតិផរណាខ្ពស់បំផុត ខ្ពស់ជាង 35 ភាគរយធៀបនឹងឆ្នាំមុន នៅខែឧសភា ឆ្នាំ 2008 (សូមមើលរូបខាងក្រោមនេះ)។ បន្ថែមលើថ្លៃស្បៀងអាហារ ការប្រែប្រួលថ្លៃទំនិញ និងសេវាមួយចំនួននៅក្នុងកញ្ចប់

---

14 *សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ខែមិថុនាឆ្នាំ2013 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ*

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ត្រូវបានពិភាក្សាខាងក្រោម ដើម្បីពិនិត្យមើលឥទ្ធិពលរបស់វាមកលើអតិផរណា។

**ការរួមចំណែកនៃស្បៀងអាហារចំពោះ អតិផរណារយៈពេល12ខែ** (CPI ភ្នំពេញ)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

31- ការប្រែប្រួលថ្លៃទំនិញមួយចំនួន ពោលគឺ គ្រឿងសង្ហារឹម បរិក្ខារប្រើប្រាស់ក្នុងគ្រួសារ សម្ភារៈសំណង់ និងថ្នាំពេទ្យនៅក្នុងកញ្ចប់សន្ទស្សន៍ទំនិញប្រើប្រាស់បានចុះថយ។ ថ្លៃទំនិញមានលំនឹងជាថ្មីឡើងវិញចាប់តាំងពីឆ្នាំ 2010 បន្ទាប់ពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកល និងវិបត្តិស្បៀងអាហារបានថមថយ សភាពការណ៍នេះបានធ្វើឱ្យអតិផរណាមានកម្រិតមធ្យម និងទាបក្នុងអំឡុងឆ្នាំ 2011 និងឆ្នាំ 2012។

**បម្រែបម្រួលថ្លៃទំនិញមួយចំនួន**

(%បម្រែបម្រួលធៀបនឹងឆ្នាំមុន)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

32- ដូចបានរំពឹងទុក ថ្លៃសេវាប្រើប្រាស់ឧបករណ៍ប្រើប្រាស់មួយចំនួន និងថ្លៃដឹកជញ្ជូនមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងថ្លៃប្រេងធ្វើឱ្យមានការប្រែប្រួលជាខ្លាំង។ ថ្លៃសេវាមួយចំនួនផ្សេងទៀត ដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងថ្លៃប្រេងរួមទាំងថ្លៃសេវាអប់រំ កំសាន្ត និងថ្លៃសេវាវប្បធម៌ និងថ្លៃសម្លៀងប្រែប្រួលតិចតួច (សូមមើលរូបខាងក្រោម)។

**បម្រែបម្រួលថ្លៃសេវាមួយចំនួន**

(%បម្រែបម្រួលធៀបនឹងឆ្នាំមុន)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

33- អតិផរណាដែលបានវាស់វែងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកមានលក្ខណៈស្រដៀងគ្នាជាខ្លាំង។ ដោយសារសេដ្ឋកិច្ចពឹងផ្អែកលើប្រាក់ដុល្លារជាខ្លាំង គប្បីពិនិត្យមើល "អតិផរណាគិតជាដុល្លារអាមេរិក" ផងដែរ [15]។ រូបខាងក្រោមនេះបង្ហាញថា ជាទូទៅ អតិផរណាដែលវាស់ជាប្រាក់រៀល និងប្រាក់ដុល្លារគឺមានភាពស្រដៀងគ្នា ដោយសារតែប្រាក់រៀលមានស្ថិរភាពធៀបនឹងអត្រាប្តូរប្រាក់ប្រាក់ដុល្លារ ដូច្នេះអនុញ្ញាតឱ្យអ្នកទាំងឡាយណាដែលទទួលបានប្រាក់ចំណូលជាដុល្លារ និងប្រាក់រៀល ស្ទើរតែមានអំណាចទិញដូចគ្នា។

**អតិផរណាគិតជាប្រាក់ដុល្លារ**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

15 *"អតិផរណាគិតជាដុល្លារអាមេរិក" លុបបំបាត់ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់នៃប្រាក់រៀលរបស់កម្ពុជា តបនឹងប្រាក់ដុល្លារអាមេរិកនៅក្នុងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់។ ដូច្នេះសន្ទស្សន៍នេះវាស់អតិផរណា ដូចករណីក្នុងសេដ្ឋកិច្ចចាយប្រាក់ដុល្លារពេញលេញដូច្នោះដែរ។*

## វិស័យរូបិយវត្ថុ

34- **វិស័យរូបិយវត្ថុដើរតួនាទីកាន់តែសំខាន់ខ្លាំងឡើងៗ ខណៈដែលបន្តមានការអភិវឌ្ឍជ្រាលជ្រៅផ្នែកហិរញ្ញវត្ថុ។** ធនាគារមានចំនួនកើនឡើង ( ការកើនពី 35 ធនាគារនៅខែធ្នូ ឆ្នាំ 2011 ទៅ 40 ធនាគារនៅខែមេសា ឆ្នាំ 2013 ) កំពុងចូលមកក្នុងទីផ្សារប្រទេសកម្ពុជា ទោះបីជាតម្រូវឱ្យបង្កើនដើមទុនបីដងចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2011 ក្ដី[16]។ ការកើនឡើងនូវទំនុកចិត្តក្នុងវិស័យធនាគារធ្វើឱ្យប្រាក់បញ្ញើកើនដល់ 6,6 ពាន់លានដុល្លារ ឬកំណើន 18,8 ភាគរយ នៅខែ មិថុនា ឆ្នាំ 2013 ធៀបនឹងឆ្នាំមុន ធៀបនឹង 5,9 ពាន់លានដុល្លារ ឬកំណើន 24 ភាគរយធៀបនឹងឆ្នាំមុន នៅចុងឆ្នាំ 2012។ នៅខែមិថុនា ឆ្នាំ 2013 ប្រាក់បញ្ញើឯកជនបានកើនឡើងយ៉ាងឆាប់រហ័សដល់ 6,6 ពាន់លានដុល្លារសហរដ្ឋអាមេរិក ឬ 19,6 ភាគរយក្នុងមួយឆ្នាំ ធៀបនឹង 6 ពាន់លានដុល្លារ ឬ 25 ភាគរយ ធៀបនឹងឆ្នាំមុន។ ប្រាក់បញ្ញើ វិស័យឯកជនក៏បានកើនឡើងយ៉ាងឆាប់រហ័ស ពោលគឺមានកំណើនធៀបនឹងឆ្នាំមុនៗលើស 30 ភាគរយ សម្រាប់ឆ្នាំទីបី ក្នុងទឹកប្រាក់ចំនួន 6,2 ពាន់លានដុល្លារអាមេរិក។ កំណើនឥណទានខ្ពស់ជំរុញឱ្យមានការបង្កើនប្រាក់បំរុងកាតព្វកិច្ចពី 12 ភាគរយ ដល់ 12,5 ភាគរយ នៅខែតុលា ឆ្នាំ 2012។ ខណៈដែលប្រព័ន្ធធនាគារនៅតែចរាចរសាច់ប្រាក់លួន និងមានទុនគ្រប់គ្រាន់ កំណើនឥណទានខ្ពស់នៃវិស័យឯកជន ពីមួយធនាំទៅមួយឆ្នាំ ប្រមាណជា 30 ភាគរយ ចាប់តាំងពីពាក់កណ្ដាលឆ្នាំ 2011 មក ធ្វើឱ្យមានកង្វល់អំពីហានិភ័យហិរញ្ញវត្ថុ ។ កំណើនឥណទានមិនទំនងជាប្រមូលផ្ដុំនៅក្នុងវិស័យតែមួយ ឬវិស័យមួយចំនួនតូចណានោះឡើយ ហើយក៏ដឹកនាំការផ្ដល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម ដែលសឱ្យឃើញតម្លៃបន្ថែមនៅក្នុងផលិតកម្មកសិកម្មនិងការនាំចេញផងដែរ។ ទោះជាយ៉ាងណាក្ដី វិស័យនេះត្រូវបានគេជឿថាបានធ្វើឱ្យវិស័យផលិតស្ទុះងើបយ៉ាងខ្លាំង និងមានសកម្មភាពរស់រវើក ហើយគេឃើញមានសញ្ញាដំបូងនៃសេដ្ឋកិច្ចពពុះ(ផុយស្រួយ)នៅឆមាសទីមួយនៃឆ្នាំ 2013។

16 *ទុនអប្បរមាស្មើនឹង១៥០ពាន់លានរៀល (សមមូលនឹង 36,5 លានដុល្លារអាមេរិក)*

### ប្រអប់លេខ 2- ដុល្លារូបនីយកម្មពេញលេញ

**តើចំណុចខ្សោយនៃដុល្លារូបនីយកម្មពេញលេញ មានទំហំច្រើនជាងផលប្រយោជន៍ឬ?** ធនាគារកណ្ដាលបានជំរុញការប្រើប្រាស់ប្រាក់រៀលជាយូរមកហើយដើម្បីកាត់បន្ថយជាបណ្ដើរៗនូវកម្រិតដុល្លារូបនីយកម្ម។ ទោះជាយ៉ាងនេះក្ដី ទោះបីជាមានការចាត់វិធានការផ្សេងៗក្នុងពេលកន្លងទៅដើម្បីធ្វើបដិដុល្លារូបនីយកម្មនៅកម្ពុជា និន្នាការនៅតែមានទិសដៅទៅរកដុល្លារូបនីយកម្មកាន់តែខ្លាំង។ កម្រិតដុល្លារូបនីយកម្មកាន់តែខ្លាំងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ។ ថ្លៃនៃដុល្លារូបនីយកម្មក៏រួមបញ្ចូលនូវការខាតបង់ចំណូល ការប្រាក់លើបរិមាណប្រាក់ជាដុល្លារដែលប្រជាពលរដ្ឋរក្សាទុក និងការខាតបង់សីណូរ៉ាហ្ស[a]។ការខាតបង់ស៊ីណូរ៉ាហ្សជាកំណើន រូបិយវត្ថុទូទៅដែលបានខាតបង់ប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថាមានចំនួន 100 លាន ដុល្លារអាមេរិក[b]។

*a. ស៊ីណូរ៉ាហ្សគឺជាផលដករវាងតម្លៃទឹកប្រាក់និងថ្លៃចំណាយផលិតនិងថ្លៃចែកចាយ*

*b. តួលេខប៉ាន់ស្មានរបស់បុគ្គលិកធនាគារ។ សូមអានឯកសារបដិដុល្លារូបនីយកម្ម ខែមីនា ឆ្នាំ 2007 ដែលរៀបរៀងដោយអ្នកស្រី តាល់ ណៃអ៊ីម*

35- **ដុល្លារូបនីយកម្មខ្ពស់បន្តធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ប្រទេសនេះ ក្នុងការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ។** គោលនយោបាយរូបិយវត្ថុជួបការលំបាកដោយដុល្លារូបនីយកម្មខ្ពស់ ខណៈពេលដែលការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកមានកំរិតតិចតួច។ ប្រាក់រៀលកម្ពុជាត្រូវបានកំណត់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក ហើយមានអត្រាគោលជុំវិញ 4.000 រៀលក្នុងមួយដុល្លារ។ *ដោយសារតែដុល្លារូបនីយកម្មខ្ពស់ អត្រាប្ដូរប្រាក់រវាងប្រាក់ដុល្លារ និងប្រាក់រៀលលែងរក្សាខ្លឹមសារដូចកាលពីដំបូងទៀតហើយ ព្រោះថាអត្រាប្ដូរប្រាក់នេះឆ្លុះបញ្ចាំងតែ ទំនិញ និងសេវាកម្មគិតជាប្រាក់រៀលដែលតំណាងសេដ្ឋកិច្ចមួយភាគតូចប៉ុណ្ណោះ។* ជាមួយនឹងសេដ្ឋកិច្ចដែលចរាចរប្រាក់ដុល្លារយ៉ាងច្រើនធនាគារកណ្ដាលមានឧបករណ៍គោលនយោបាយរូបិយវត្ថុតិចតួចបំផុត នៅសល់តែគោលនយោបាយ សារពើពន្ធមួយប៉ុណ្ណោះសម្រាប់ធ្វើជាឧបករណ៍ចំបងដើម្បីអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។ កាលពីពេលកន្លងទៅថ្មីៗគេឃើញមានការវិវឌ្ឍន៍ជាវិជ្ជមាន គឺការបង្កើតការិយាល័យផាត់ទាត់នៅថ្នាក់ជាតិ និងការដាក់ឱ្យប្រើប្រាស់មូលប័ត្រហិរញ្ញវត្ថុថ្មីមួយ និងវិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចជួញដូរបាន។ ទោះជាយ៉ាងណាក្ដី គេនៅតែត្រូវបង្កើតឡើងនូវទីផ្សារអន្តរធនាគារ។

## ទុនបំរុងអន្តរជាតិដុល

36- **ទុនបំរុងអន្តរជាតិដុលកើនដល់ 3,6 ពាន់លានដុល្លារនៅខែមិថុនា ឆ្នាំ 2013។** ទុនបម្រុងអន្តរជាតិបន្តកើនឡើងដោយសារមានលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ។ *ទោះជាយ៉ាងណាក្តី ទុនបំរុងនេះនៅតែមានកម្រិតទាបធៀបនឹងស្តង់ដារតំបន់ និងបន្ថែមទំហំហានិភ័យមួយផ្សេងទៀតមកលើសេដ្ឋកិច្ចដោយសារធនាគារកណ្តាល មិនអាចដើរតួនាទីជាស្ថាប័នឱ្យខ្ចីនៅនាទីចុងក្រោយ ដោយសារតែដុល្លារូបនីយកម្ម។* ទុនបំរុងនេះអាចរ៉ាប់រងការនាំចូលទំនិញ និងសេវាកម្មបានត្រឹមតែប្រមាណជា 3,6 ខែប៉ុណ្ណោះ [18] ។ ចំណែកឯភាគរយនៃប្រាក់បញ្ញើរបស់វិស័យឯកជនវិញ ទុនបម្រុងអន្តរជាតិដុលបានធ្លាក់ចុះជាបន្តបន្ទាប់ពី 86 ភាគរយនៅចុងឆ្នាំ 2006 មកត្រឹមតែ 54 ភាគរយនៅខែមិថុនាឆ្នាំ 2013 ដោយសារតែ ការកើនឡើងយ៉ាងឆាប់រហ័សនៃប្រាក់បញ្ញើនៃវិស័យឯកជន។

**ទំហំទុនបំរុងបរទេសដុល**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

## ទ្រព្យសកម្មបរទេសសុទ្ធ[19]

37- **ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារកណ្តាលបន្តកើនឡើងជាចម្បង គឺដោយសារការកើនឡើងនូវទុនបម្រុងអន្តរជាតិ។** ទោះជាយ៉ាងណាក្តី នៅខែមិថុនាឆ្នាំ 2013 ទុនបម្រុងអន្តរជាតិដុល បានធ្លាក់ចុះប្រហែល 150 លានដុល្លារអាមេរិក នៅសល់ត្រឹមតែ 3,6 ពាន់លានដុល្លារ អាមេរិកធៀបនឹងកម្រិតខ្ពស់បំផុតស្មើនឹង 3,75 ពាន់លានដុល្លារនៅខែមេសា ដែលឆ្លុះបញ្ចាំងមួយផ្នែកធំនូវការច្នៃប្រឌិត កាលពីពេលកន្លងទៅថ្មីៗដើម្បីទប់ស្កាត់ការធ្លាក់ថ្លៃនៃប្រាក់រៀលដោយសារថ្មីៗនេះប្រាក់ដុល្លារបានឡើងថ្លៃ។ ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារទទួលប្រាក់បញ្ញើ (DMBs) ក៏បានកើនឡើងផងដែរ។ ធនាគារទទួលប្រាក់បញ្ញើកន្លងមក បានឆ្លងកាត់អំឡុងពេលដែលទ្រព្យសកម្មបរទេសសុទ្ធអវិជ្ជមាននៅចុងឆ្នាំ 2008 រហូតដល់ដើមឆ្នាំ 2009 នៅពេលដែលទ្រព្យសកម្មបរទេសធ្លាក់ចុះយ៉ាងគំហុក ច្រើនជាងការកាត់កងបំណុលបរទេសជាមួយបរិមាណទុនបម្រុងរបស់ធនាគារនានា ក្នុងពេលមានវិបត្តិហិរញ្ញវត្ថុសកលទៅទៀត (សូមមើលរូបភាពខាងក្រោម)[20] ។

**ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា និងរបស់ធនាគារទទួលប្រាក់បញ្ញើ**




សំគាល់៖ FC: រូបិយបណ្ណបរទេស, GIR: ទុនបំរុងអន្តរជាតិដុល, NFA: ទ្រព្យសកម្មបរទេសសុទ្ធ, DMB: ធនាគារទទួលប្រាក់បញ្ញើ
ប្រភព៖ ធនាគារជាតិនៃកម្ពុជា

38- **ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារ កណ្តាលចុះថយ នៅពេលដែលប្រាក់បញ្ញើរបស់រដ្ឋាភិបាលកើនឡើង[21]។** ទិដ្ឋភាពនេះគូសបញ្ជាក់ដោយគោលការណ៍ចំបងអំពីតុល្យភាពថវិកានៃស្ថានភាពសារពើពន្ធ។ រដ្ឋាភិបាលមិនត្រឹមតែជៀសវាងការផ្តល់ហិរញ្ញប្បទានពីធនាគារក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែក៏បង្កើនប្រាក់

---

18 *ទុនបំរុងអន្តរជាតិដុលធៀបនឹងការនាំចូលទំនិញ និងសេវាកម្មក្នុងឆ្នាំបន្ទាប់*

19 *ទ្រព្យសកម្មបរទេសសុទ្ធគឺជាសមតុល្យនៃគណនីទ្រព្យសកម្មបរទេសដែលជាផលបូកនៃទ្រព្យសកម្មបរទេសរបស់អាជ្ញាធររូបិយវត្ថុ និង DMB ដកបំណុលបរទេស(ប្រសិនបើមាន)*

20 *ចំណុចនេះឆ្លុះឱ្យឃើញនូវការកាត់បន្ថយបំណុលក្នុងពេលមានវិបត្តិហិរញ្ញវត្ថុសកល*

21 *ទ្រព្យសកម្មក្នុងស្រុកសុទ្ធគឺជាផលបូកនៃឥណទានក្នុងស្រុកសុទ្ធ (បំណុលត្រូវទារពីរដ្ឋាភិបាល បំណុលត្រូវទារពី DMB និងបំណុលត្រូវទារពីវិស័យក្នុងស្រុក)និងផ្នែកផ្សេងទៀត(សុទ្ធ)*

បញ្ញើរបស់រដ្ឋាភិបាលផងដែរ នៅពេលដែលការប្រមូលចំណូលមានភាពប្រសើរឡើង[22]។ នៅក្នុងចុងទសវត្ស 80 ដល់ដើមទសវត្ស 90 វិនភាពសារពើពន្ធបាននាំទៅដល់ការពឹងផ្អែកលើការផ្តល់ហិរញ្ញប្បទានពីធនាគារកណ្តាល (បំណុលរដ្ឋាភិបាលត្រូវសងសុទ្ធស្មើនឹង 51 ភាគរយនៃឥណទានក្នុងស្រុកសរុបនៅឆ្នាំ 1993) ធ្វើឱ្យកើនឡើងនូវទ្រព្យសកម្មក្នុងស្រុករបស់ធនាគារកណ្តាល និងអតិផរណាធ្ងន់ធ្ងរ។

**ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើរដ្ឋាភិបាល ដែលពង្រឹងស្ថានភាពទុនបម្រុងរបស់ធនាគារកណ្តាល ដែលគេអាចប្រើជាសម្រាប់ទប់ទល់នឹងវិបត្តិខាងក្រៅណាមួយនាពេលអនាគតផងដែរ។ ចូរកត់សំគាល់ថានៅពេលមានប្រាក់សន្សំច្រើន រដ្ឋាភិបាលមានលទ្ធភាពក្នុងការដាក់ឱ្យប្រើគោលនយោបាយជំរុញសារពើពន្ធ ដែលមានទឹកប្រាក់ប្រហែល 2 ភាគរយនៃផលិតផលក្នុងស្រុកសរុបកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចសកលឆ្នាំ 2008-2009។ សម្រាប់ព័ត៌មានលំអិតសូមមើលផ្នែកទី3 ស្តីពីវិស័យសារពើពន្ធ។

**ឥណទានសុទ្ធដែលប្រព័ន្ធធនាគារផ្តល់ឲ្យរដ្ឋាភិបាល(NCG)**
(គិតជាពាន់លានរៀល)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

39- ឥណទានសុទ្ធផ្តល់ឱ្យរដ្ឋាភិបាលត្រូវបានកាត់បន្ថយសារជាថ្មីម្តងទៀត ហើយនៅខែមិថុនាឆ្នាំ 2013 តួលេខដាច់ខាតនៃឥណទានសុទ្ធ ដែលបានផ្តល់ឱ្យរដ្ឋាភិបាលបានឈានដល់កម្រិតមុនពេលមានវិបត្តិ[23]។*ស្ថានភាពនេះគឺដោយសារកំណើន*

## រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់

## រូបិយវត្ថុទូទៅ

40- ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ប្រាក់បញ្ញើចម្បងជាប្រាក់ដុល្លារអាមេរិកមានចំនួន 96 ភាគរយនៃរូបិយវត្ថុទូទៅ[24]។ *ស្ថានភាពនេះ ឆ្លុះបញ្ចាំងដុល្លារូបនីយកម្មខ្ពស់នៃសេដ្ឋកិច្ចកម្ពុជា។ ចំណែកភាគរយនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសនៅក្នុងប្រាក់បញ្ញើសរុប បានកើនដល់កម្រិតខ្ពស់បំផុតជាង 98 ភាគរយក្នុងអំឡុងចុងឆ្នាំ 2007 និងដើមឆ្នាំ 2008 ដោយសារលំហូរចូលមូលធនទ្រង់ទ្រាយធំនោះដែលបានកើតឡើង*

---

22 *ឱនភាពសារពើពន្ធមានផលប៉ះពាល់ចំពោះស្ថេរភាពសេដ្ឋកិច្ច។ ប្រភពនៃហិរញ្ញប្បទានឱនភាពសារពើពន្ធមានផលប៉ះពាល់ផ្សេងគ្នា។ ការខ្ចីប្រាក់ពីធនាគារកណ្តាលធ្វើឱ្យមានអតិផរណា ប៉ុន្តែបើខ្ចីប្រាក់ពីធនាគារទទួលប្រាក់បញ្ញើធ្វើឱ្យប៉ះពាល់ដល់ការវិនិយោគរបស់វិស័យឯកជន ហេតុនេះធ្វើឱ្យជះឥទ្ធិពលដល់ផលសេដ្ឋកិច្ច។ ការខ្ចីពីសាធារណជនដែលមិនមែនជាប្រព័ន្ធធនាគារតាមរយៈការបោះមូលបត្រ នឹងធ្វើឱ្យមានសម្ពាធលើអត្រាការប្រាក់ និងបង្កើនបំណុលសាធារណៈក្នុងស្រុក។ ការផ្តល់ហិរញ្ញប្បទានបរទេសនាំឱ្យមានបន្ទុកបំណុលបរទេស។ ឱនភាពសារពើពន្ធរបស់ប្រទេសកម្ពុជាត្រូវបានផ្តល់ហិរញ្ញប្បទានដោយហិរញ្ញប្បទានបរទេស។ ទោះជាយ៉ាងណាក្តី ការណ៍នេះមិនក្លាយទៅជាបន្ទុកបំណុលបរទេសធ្ងន់ធ្ងរឡើយដោយសារតែលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទានដែលមានលក្ខណៈសម្បទាន។*

23 *ឥណទានសុទ្ធផ្តល់ឱ្យរដ្ឋាភិបាលស្មើនឹងឥណទានផ្តល់ឱ្យរដ្ឋាភិបាលដកប្រាក់បញ្ញើរបស់រដ្ឋាភិបាល*

24 *រូបិយវត្ថុទូទៅ(M2)៖ ជាការវាស់ស្ទង់ការផ្គត់ផ្គង់រូបិយវត្ថុធំបំផុតដែលរួមមានរូបិយវត្ថុចង្អៀត(M1) (ជារូបិយវត្ថុស្ថិតក្នុងចរាចរណ៍និងប្រាក់បញ្ញើនៃគណនីចរន្ត) ប្រាក់សន្សំ(សញ្ច័យ)និងប្រាក់បញ្ញើមានកាលកំណត់។ ចូរកត់សំគាល់ថាដុល្លារអាមេរិកស្ថិតក្នុងចរាចរណ៍មិនត្រូវបានរាប់បញ្ចូលឡើយ ព្រោះមិនអាចវាស់បាន។*

*ជាច្រើនខែ មុនពេលដែលវឌ្ឍនភាពអចលនវត្ថុពពុះផ្ទុះបែក។* ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានធ្លាក់ចុះស្ទើរតែស្មើ 200 លានដុល្លារក្នុងខែវិច្ឆិកា ឆ្នាំ 2008 ដល់ 2,2 ពាន់លានដុល្លារអាមេរិកធ្លាក់ពី 2,4 ពាន់លានដុល្លារអាមេរិកក្នុងខែកញ្ញា ឆ្នាំ 2008 ដោយសារសេដ្ឋកិច្ចកម្ពុជារងគ្រោះ ជន់ធ្ងរពីវិបត្តិសេដ្ឋកិច្ចសកល។

**សមាសភាគនៃរូបិយវត្ថុទូទៅ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## *ការរួមចំណែកចំពោះកំណើនរូបិយវត្ថុទូទៅ*

41- **ភាគច្រើន កំណើនរូបិយវត្ថុត្រូវបានជំរុញដោយប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។** ត្រឹមខែមិថុនា ឆ្នាំ 2013 រូបិយវត្ថុទូទៅបានកើនឡើង 18,8 ភាគរយ ធៀបនឹងឆ្នាំមុនហើយការកើនឡើងនូវប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស រួមចំណែក 83 ភាគរយនៃកំណើននេះ។ ការកើនឡើងនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសយ៉ាងឆាប់រហ័ស ក្នុងរយៈពេលពីចុងឆ្នាំ 2007 និងដើមឆ្នាំ 2008 បានរួមចំណែករហូតដល់ 90 ភាគរយចំពោះកំណើនរូបិយវត្ថុទូទៅជាលទ្ធផលកំណើនរូបិយវត្ថុទូទៅបានកើនឡើងដល់កម្រិតខ្ពស់បំផុត គឺកើនឡើងខ្ពស់ជាង 60 ភាគរយធៀបនឹងឆ្នាំមុន។ ការកើនឡើងនិងការធ្លាក់ចុះនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសភាគច្រើន កំពុងឆ្លុះបញ្ចាំងលំហូរចូលមូលធនបរទេស និងលំហូរចេញមូលធនបរទេសមកកាន់ និងចេញពីសេដ្ឋកិច្ចកម្ពុជាដែលមានទំហំតូច បើកចំហ និងមានកម្រិតដុល្លាររូបនីយកម្មខ្ពស់។

**កត្តារួមចំណែកចំពោះកំណើនរូបិយវត្ថុទូទៅ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

# អត្រាប្តូរប្រាក់

## *អត្រាប្តូរប្រាក់នាម (ជាក់ស្តែង)*

42- **ប្រាក់ដុល្លារបានឡើងថ្លៃចាប់តាំងពីត្រីមាសទីពីរឆ្នាំនេះហើយសភាពការណ៍នេះបានបង្ខំឱ្យធនាគារកណ្តាលធ្វើអន្តរាគមន៍។** ធនាគារកណ្តាលបានខាតបង់ទុនបម្រុងអន្តរជាតិប្រហែល 150 លានដុល្លារអាមេរិក។ ប្រាក់រៀលបានធ្លាក់ថ្លៃ និងមានអត្រា 4.062 ក្នុងមួយដុល្លារក្នុងខែមិថុនា ឆ្នាំ 2013។ ដោយសារអន្តរាគមន៍របស់ធនាគារកណ្តាលអត្រាប្តូរប្រាក់រវាងប្រាក់រៀលកម្ពុជាធៀបនឹងប្រាក់ដុល្លារអាមេរិក នៅតែមានស្ថិរភាពជុំវិញ 4.000 រៀលក្នុងមួយដុល្លារអាមេរិក។ ខណៈពេលដែលរបបអត្រាប្តូរប្រាក់តាមច្បាប់ អាចចាត់ទុកថាជាអត្រាប្តូរប្រាក់ស្ថិតក្រោមការគ្រប់គ្រង ដោយមានការកែតម្រូវអត្រាផ្លូវការ (តាមរយៈការលក់ និងការទិញប្រាក់ដុល្លារអាមេរិក) ស្ថិតក្នុងអត្រាប្តូរប្រាក់ទីផ្សារប្រចាំថ្ងៃដែលមានកម្រិតប្រែប្រួលតិចតួច ក្នុងរង្វង់ត្រឹម 4.000 រៀលក្នុងមួយដុល្លារអាមេរិក អាចត្រូវបានគេមើលឃើញថា អត្រាប្តូរប្រាក់ត្រូវបានកំណត់តាមការប្រែប្រួលរបស់ប្រាក់ដុល្លារ[25]។ អត្រាប្តូរប្រាក់ផ្លូវការ (ចុងគ្រា) គឺ 3.995 រៀល និង 4.039 រៀលក្នុងមួយដុល្លារអាមេរិកក្នុង ឆ្នាំ 2012 និងឆ្នាំ 2011។ អន្តរាគមន៍លើអត្រាប្តូរប្រាក់ គឺជាឧបករណ៍រូបិយវត្ថុមួយដែលធនាគារកណ្តាលមាន សម្រាប់ធ្វើឱ្យថ្លៃទំនិញ និងសេវាកម្មគិតជាប្រាក់រៀលមានស្ថិរភាព ។

25 *រង្វង់នេះទំនងជា +/-1 ភាគរយនៃអត្រាទីផ្សារដែលបានអង្កេតប្រចាំថ្ងៃ។ ទោះជាយ៉ាងណាក្តី ធនាគារកណ្តាលមិនបានបញ្ជាក់ច្បាស់លាស់ឡើយ។*

អត្រាប្តូរប្រាក់ជាក់ស្តែង

( សន្ទស្សន៍ 2005 = 100 )




ប្រភព៖ ធនាគារកណ្តាល ( កម្ពុជានិងថៃ ) និងក្រសួងហិរញ្ញវត្ថុវៀតណាម

43- ទោះជាយ៉ាងណាក្តី ការធ្វើអន្តរាគមន៍លើអត្រាប្តូរប្រាក់ មិនគ្រប់គ្រាន់ឡើយ ក្នុងការសម្រេចបាននូវគោលបំណងបដិដុល្លារូបនីយកម្ម( ប្រសិនបើមាន )ខណៈដែលប្រាក់ដុល្លារមានមុខងារលើសលុប។ ប្រជាប្រិយភាពរបស់ប្រាក់ដុល្លារអាមេរិកដែលស្ទើរតែក្លាយទៅជារូបិយប័ណ្ណសកល ធៀបនឹងប្រាក់រៀល មានភាពច្បាស់លាស់ ទោះបីជាលទ្ធផលម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានស្ថិរភាពក្តី។ ប្រាក់ដុល្លារបានក្លាយទៅជាមធ្យោបាយ ដែលអាចជឿទុកចិត្តក្នុងការរក្សាតម្លៃ មានន័យថា ប្រាក់ដុល្លារជាមធ្យោបាយនៃការទូទាត់អន្តរជាតិ ដែលគេទទួលស្គាល់ជាទូទៅ និងជារូបិយប័ណ្ណដែលគេប្រើប្រាស់ច្រើននៅក្នុងទីផ្សារហិរញ្ញវត្ថុ។

## *អត្រាប្តូរប្រាក់ខ្មែរជាក់ស្តែង និង អត្រាប្តូរប្រាក់ខ្មែរពិត*

44- ការភ្ជាប់ប្រាក់រៀលជាមួយប្រាក់ដុល្លារធ្វើឱ្យអត្រាប្តូរប្រាក់ជាក់ស្តែងនៃប្រាក់រៀលធ្លាក់ថ្លៃជាខ្លាំង នៅពេលដែលប្រាក់ដុល្លារអាមេរិកធ្លាក់ថ្លៃ[26] ។ រូបិយវត្ថុខ្សោយក្នុងស្រុក (និងប្រាក់ដុល្លារអាមេរិក) គួរតែធ្វើឱ្យការនាំចេញរបស់ប្រទេសកម្ពុជាមានលក្ខណៈប្រកួតប្រជែងបន្ថែមទៀត ខណៈដែលប្រទេសនេះ បានធ្វើពិពិធកម្មការនាំចេញរបស់ខ្លួនយ៉ាងសម្បូរបែប ជាមួយនឹងគោលដៅនាំចេញ មិនត្រឹមតែទៅកាន់សហរដ្ឋអាមេរិកប៉ុណ្ណោះទេ ហើយមិនត្រឹមតែបាននាំចេញនូវផលិតផលសម្លៀកបំពាក់នោះទេ ប៉ុន្តែក៏បាននាំចេញស្បែកជើង និងផលិតផលកសិកម្មផងដែរ។ ទោះជាយ៉ាងណាក្តី អត្រាប្តូរប្រាក់ខ្មែរពិត បានឡើងថ្លៃបន្តិចចាប់តាំងពីឆ្នាំ 2006 មក។

អត្រាប្តូរប្រាក់ខ្មែរ

( សន្ទស្សន៍ 2005 = 100 )




ប្រភព៖ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

# វិស័យធនាគារ

## *ការផ្តល់ឥណទានទៅកាន់វិស័យឯកជន និង ប្រាក់បញ្ញើពីវិស័យឯកជន*

45- ប្រាក់បញ្ញើពីវិស័យឯកជនបានកើនឡើងចាប់តាំងពីដើមឆ្នាំ 2010 ដូចគ្នាដែរកំណើនឥណទាន ( ធៀបនឹងឆ្នាំមុន ) បន្តិចក្រោយមក ក៏បានកើនឡើងផងដែរ រួចកើនលើសកំណើនប្រាក់បញ្ញើចាប់តាំងពីដើមឆ្នាំ 2011។ រូបិយវត្ថុទូទៅគិតជាភាគរយនៃផលិតផលក្នុងស្រុកសរុបបានកើនឡើងដល់ 51 មួយភាគរយនៃផលិតផលសរុបក្នុងស្រុកក្នុងខែមិថុនា ឆ្នាំ 2013 គឺកើនឡើងពី 20 ភាគរយនៅចុងឆ្នាំ 2005។ *នៅពេលដែលមានការអភិវឌ្ឍស៊ីជំរៅជាបន្តនៃវិស័យហិរញ្ញវត្ថុ អនុបាតប្រាក់កម្ចីធៀបនឹងប្រាក់បញ្ញើបានកើនឡើងយ៉ាងច្រើន ឡើងដល់ជាង 80 ភាគរយនៅចុងឆ្នាំ 2012 ធៀបនឹងប្រមាណជា 60 ភាគរយប៉ុណ្ណោះនៅចុងឆ្នាំ 2005។* ក្នុងកំឡុងពេលដូចគ្នានេះអនុបាតនៃការផ្តល់ឥណទានធៀបនឹងមូលធន បានកើនឡើងទៅជិតដល់ 300 ភាគរយ ប្រហែល 200 ភាគរយ។

---

*26 អត្រាប្តូរប្រាក់ជាក់ស្តែងគឺជាតម្លៃមធ្យមភាគដែលបានគិតបញ្ចូលនូវទម្ងន់នៃរូបិយវត្ថុក្នុងស្រុកដោយគ្មានការកែតម្រូវ ( ខណៈដែលREERគឺជាអតិផរណាដែលបានកែតម្រូវ ) ធៀបនឹងរូបិយបណ្ណចំបង១ដែលត្រូវបានជួញដូរ។ ទម្ងន់ទាំងនេះកំណត់ដោយសារសំខាន់ដែលកម្ពុជាកំណត់ចំពោះរូបិយបណ្ណដទៃដែលបានជួញដូរ*

## ឥណទាននិងប្រាក់បញ្ញើរបស់វិស័យឯកជន




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឥណទានតាមប្រភេទអាជីវកម្ម

(គិតជាពាន់លានរៀលនៅចុងគ្រា)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឥណទានតាមប្រភេទអាជីវកម្ម

(គិតជាពាន់លានដុល្លារអាមេរិក ខែធ្នូ ឆ្នាំ2012)




### *ឥណទានតាមប្រភេទអាជីវកម្ម*

46- **គិតត្រឹមខែធ្នូឆ្នាំ 2012 ឥណទានកសិកម្មមានចំនួន 0,57 ពាន់លានដុល្លារអាមេរិក។** តួលេខនេះតំណាងឱ្យ 10 ភាគរយនៃឥណទានសរុបដល់វិស័យឯកជននៅជំណាច់ឆ្នាំ 2012 ធៀបនឹង 100 លានដុល្លារអាមេរិក ឬ 5 ភាគរយនៃឥណទានសរុបនៅចុងឆ្នាំ 2008។ ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្មរួមចំណែកខ្ពស់ដល់ 21 ភាគរយនៃកំណើនឥណទានក្នុងឆ្នាំ 2011 ជាលំដាប់ទីពីរនៃការហិរញ្ញប្បទានដល់អាជីវកម្មលក់រាយដែលត្រូវជា 25 ភាគរយនៃកំណើនឥណទាន។ នៅឆ្នាំ 2012 ការរួមចំណែកធ្វើឱ្យមានកំណើនឥណទានតាមរយៈការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម បានចុះថយ 14 ភាគរយ ផ្ទុយទៅវិញការរួមចំណែកពីការផ្តល់ហិរញ្ញប្បទានលក់ដុំ បានកើនឡើងដល់ 33 ភាគរយ។ គិតត្រឹមខែធ្នូ ឆ្នាំ 2012 ការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្មលក់ដុំមានចំណែកភាគរយធំបំផុត គឺមានចំនួន 1,05 ពាន់លានដុល្លារ (ឬ 18,4 ភាគរយ) និងការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្មលក់រាយមានបរិមាណទឹកប្រាក់ចំនួន 0,93 ពាន់លានដុល្លារ (ឬ 16,3 ភាគរយ) គឺជាលំដាប់បន្ទាប់។

47- **ការប្រកួតប្រជែងក្នុងចំណោមធនាគារ បានរួមចំណែកដល់ការបំប្រួញគម្លាតមធ្យមនៃអត្រា ការប្រាក់ដុល្លារអាមេរិកក្រោយពីបានគិតបញ្ចូលនូវទម្ងន់** [27]។ គម្លាតដែលជាផលដករវាងអត្រាការប្រាក់លើប្រាក់បញ្ញើ និងអត្រាចងការបានធ្លាក់ចុះដល់ 7,17 ភាគរយក្នុងខែធ្នូ ឆ្នាំ 2012 គឺធ្លាក់ពី 11,92 ភាគរយក្នុងខែមករា ឆ្នាំ 2007។ ទោះជាយ៉ាងណាក្តី គម្លាតនេះនៅតែមានទំហំធំធៀបនឹងបណ្តាប្រទេសដទៃទៀតនៅអាស៊ីអគ្នេយ៍។ អត្រាចងការប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះយ៉ាងខ្លាំង ដល់ 11,7 ភាគរយគឺធ្លាក់ពី 16,6 ភាគរយក្នុងរយៈពេលដូចគ្នា។ ក្នុងកំឡុងពេលនៃការឡើងថ្លៃស្បៀងអាហារ មុនពេលមានវិបត្តិហិរញ្ញវត្ថុសកល អត្រាពិតនៃប្រាក់បញ្ញើដុល្លារជាអត្រាអវិជ្ជមានយ៉ាងធំ ដោយសារអតិផរណាខ្ពស់។

*27 គម្លាតអត្រាការប្រាក់គឺជាអត្រាការប្រាក់ដែលធនាគារយក លើការផ្តល់ប្រាក់កម្ចីដល់អតិថិជនវិស័យឯកជនដកអត្រាការប្រាក់ ដែលទូទាត់ដោយធនាគារ។ គម្លាតដែលបានពិភាក្សាខាងលើនេះគឺមធ្យមភាគនៃប្រាក់បញ្ញើមានកាលកំណត់ក្នុងរយៈពេល 12 ខែ និងអត្រាចងការដុល្លារអាមេរិកក្នុងរយៈពេល 12 ខែ*

### អត្រាការប្រាក់ដុល្លារមធ្យម[1]




1 អត្រាការប្រាក់ដុល្លារអាមេរិករយៈពេល12ខែផ្តល់ឱ្យប្រាក់បញ្ញើ និងអត្រាចងការប្រាក់ដុល្លារអាមេរិករយៈពេល12ខែ

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

| | អត្រាការប្រាក់ចំពោះប្រាក់បញ្ញើ | អត្រាចងការ |
|---|---|---|
| កម្ពុជា | 1,33 | 13,13 |
| ឥណ្ឌូនេស៊ី | 1,97 | 4,08 |
| ម៉ាឡេស៊ី | 2,98 | 4,73 |
| មីយ៉ាន់ម៉ា | 8,0 | 13,0 |
| ហ្វីលីពីន | 0,943 | 5,485 |
| ថៃ | 3,35 | 7,13 |
| វៀតណាម | 9,0 | 12,47 |

*ចំណាំ៖ **អត្រាការប្រាក់ចំពោះប្រាក់បញ្ញើ** ជាមធ្យមភាគសាមញ្ញនៃអត្រាការប្រាក់បញ្ញើសន្សំជារូបិយវត្ថុក្នុងស្រុកដែលរាយការណ៍ដោយធនាគារចំនួន 10 ដែលមានប្រាក់បញ្ញើច្រើនជាងគេ។*

***អត្រាការប្រាក់ចងការ** ជាមធ្យមភាគសាមញ្ញនៃប្រាក់កម្ចីជារូបិយប័ណ្ណបរទេសដែលបានផ្តល់ឱ្យក្រុមហ៊ុនឯកជន និងដែលបានរាយការណ៍ដោយធនាគារចំនួន 10 ដែលមានប្រាក់បញ្ញើច្រើនជាងគេ។*

*ប្រភព៖ ស្ថិតិហិរញ្ញវត្ថុអន្តរជាតិ IMF*

# វិស័យសារពើពន្ធ ចំណូល និងសមាសភាគសំខាន់ៗនៃចំណូល

## *សមាសភាពសំខាន់ៗនៃពន្ធ*

48- ក្នុងកំឡុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ 2013 ចំណូលក្នុងស្រុកបន្តកើនឡើង តែមានល្បឿនយឺត ពោលគឺកើនឡើងត្រឹមតែ 9,6 ភាគរយ ធៀបនឹងឆ្នាំមុន ធៀបនឹង 24,7 ភាគរយ ក្នុងឆ្នាំ 2012 [28]។ គិតត្រឹមខែឧសភា ឆ្នាំ 2013 ទិន្នន័យសារពើពន្ធបឋមបានបង្ហាញថារដ្ឋាភិបាលកណ្តាល បានប្រមូលពន្ធ 3.389 ពាន់លានរៀល(ស្មើនឹង 847 លានដុល្លារអាមេរិក)។ នៅឆ្នាំ 2012 ទិន្នន័យសារពើពន្ធបណ្តោះអាសន្នបានកត់ត្រាចំណូលក្នុងស្រុករបស់រដ្ឋាភិបាលទូទៅចំនួន 8.402 ពាន់លានរៀល ស្មើនឹង (2,1 ពាន់លានដុល្លារអាមេរិក) [29]។ តួលេខនេះតំណាងឱ្យអនុបាតរវាងចំណូល ធៀបនឹងផលិតផលក្នុងស្រុកសរុបប្រមាណជា 14,4 ភាគរយ ដែលជាកម្រិតខ្ពស់បំផុតដែលបានអនុវត្តក្នុងពេលកន្លងមក។ សមិទ្ធិផលនេះមានទំហំលើសផែនការកំណើនប្រចាំឆ្នាំចំនួន 0,5 ភាគរយ ជាអនុបាតចំណូលធៀបនឹងផលិតផលក្នុងស្រុកសរុប ដែលកំណត់ដោយកម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទោះជាយ៉ាងណាក្តី អនុបាតប្រាក់ចំណូលធៀបនឹងផលិតផលក្នុងស្រុកសរុបនៅតែមានកំរិតទាប ធៀបនឹងលទ្ធផលអនុវត្តន៍ជាមធ្យមក្នុងតំបន់។ ប្រាក់ចំណូលរបស់រដ្ឋាភិបាលកណ្តាលមានចំនួន 91 ភាគរយ ឬ (13,2 ភាគរយនៃ GDP) នៃចំណូលសរុប ចំណែកឯ 9 ភាគរយទៀតជាចំណូលថ្នាក់ខេត្ត។ ក្នុងឆ្នាំ 2012 ពន្ធប្រយោល ពិសេសគឺពន្ធក្នុងស្រុក និងអាករលើតម្លៃបន្ថែម (VAT) និងអាករពិសេស រួមចំណែកធំបំផុតចំនួន 45 ភាគរយនៃចំណូលក្នុងស្រុកសរុប។ ពន្ធពាណិជ្ជកម្មភាគច្រើនគឺពន្ធគយជាចំណូលលំដាប់ទីពីរ មានចំណែក 16 ភាគរយនៃចំណូលពន្ធសរុប។ ពន្ធផ្ទាល់ ភាគច្រើនគឺពន្ធលើប្រាក់ចំណេញ (នៅមិនទាន់បានដាក់ឱ្យ ប្រើពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួននៅឡើយ) មានទំហំតូច ដោយសារតែមានការលើកលែងពន្ធតាមច្បាប់វិនិយោគដែលកំពុងស្ថិតនៅជាធរមាន។

### ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលទូទៅ
(គិតជាភាគរយនៃផសស)




សំគាល់៖ P=បណ្តោះអាសន្ន B=ថវិកា

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*28 ទិន្នន័យសារពើពន្ធបឋមសម្រាប់ឆ្នាំ2013ត្រូវធ្វើការកែសម្រួល*

*29 ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលបណ្តោះអាសន្នឆ្នាំ2012-ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលទូទៅរួមមានចំណូលរបស់រដ្ឋាភិបាលនៅថ្នាក់កណ្តាលនិងនៅថ្នាក់ខេត្ត*

49- **ការរួមចំណែកដោយពន្ធផ្ទាល់ (និងមិនមែនពន្ធ ដែលរួមមានការបែងចែកប្រាក់ចំណូល ប្រាក់បន្ទុក និងថ្លៃសេវា) ចាំបាច់ត្រូវពង្រឹងបន្ថែមទៀត យ៉ាងហោចណាស់ក៏យកទៅបំពេញពន្ធពាណិជ្ជកម្មដែលធ្លាក់ចុះដែរ។** ពន្ធពាណិជ្ជកម្ម ជាពិសេសពន្ធគយ (រួមទាំងរបាំងមិនមែនពន្ធ )ត្រូវបានរំពឹងថានឹងធ្លាក់ចុះជាបណ្តើរៗ ព្រោះថាពន្ធគយចាំបាច់ត្រូវតែធ្វើឱ្យមានសុខដុមនីយកម្ម និងត្រូវកាត់បន្ថយ ដោយសារសមាជិកភាពរបស់ប្រទេសកម្ពុជានៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក [30]។ ដើម្បីបំពេញការធ្លាក់ចុះមួយផ្នែកនៃពន្ធគយ មានកិច្ចប្រឹងប្រែងដើម្បីកែលម្អបន្ថែម ជាពិសេសអាករលើតម្លៃបន្ថែមពីការនាំចូល ដែលរួមចំណែកប្រហែល 18 ភាគរយនៃចំណូលក្នុងស្រុកសរុបក្នុងឆ្នាំ 2012 កើនឡើងពី 15 ភាគរយក្នុង ឆ្នាំ 2010។ ការប្រមូលពន្ធលើប្រាក់ចំណេញក៏កើនឡើងចំនួន 12 ភាគរយនៃតួលេខសរុបក្នុងឆ្នាំ 2012 ធៀបនឹងត្រឹមតែ 10 ភាគរយប៉ុណ្ណោះនៅឆ្នាំ 2010។ ជាមួយគ្នានេះផងដែរក៏មានការធ្វើឱ្យប្រសើរឡើងមួយចំនួនក្នុងការប្រមូលចំណូលមិនមែនពន្ធបន្ទាប់ពីការដាក់ឱ្យដំណើរការប្រព័ន្ធទទួល និងប្រមូលចំណូលមិនមែនពន្ធដែលមានលក្ខណៈស្តង់ដារ។ ទោះយ៉ាងណាក្តី នៅមានកន្លែងសម្រាប់កែលម្អបន្ថែមទៀត ពិសេសតាមរយៈការលើកកំពស់ការគ្រប់គ្រងប្រាក់ចំណូល។

### ប្រអប់លេខ 3- និរន្តរភាពបំណុល

**ការវិភាគនិរន្តរភាពបំណុល(DSA)ឆ្នាំ 2012 បង្ហាញថាការចាត់ថ្នាក់ភាពតានតឹងនៃបំណុលរបស់ប្រទេសកម្ពុជា នៅតែមានកម្រិតទាបក្រោមសេណារីយ៉ូគោល។** ចំណាត់ថ្នាក់នេះមានលក្ខណៈស្រដៀងគ្នាទៅនឹងចំណាត់ថ្នាក់ហានិភ័យកាលពីឆ្នាំមុន ដោយសារសូចនាករបន្ទុកបំណុលស្ថិត នៅក្រោមសេណារីយ៉ូគោល មិនបានបំពានកម្រិតកំណត់គោលពាក់ព័ន្ធនៃសូចនាករទាំងនោះឡើយ[c]។ ទោះជាយ៉ាងណាក្តីក្រោមសេណារីយ៉ូដែលវឌ្ឍនភាពកំណែទម្រង់មានកម្រិតតិចតួច សូចនាករនេះ នឹង "បំពាន" កម្រិតកំណត់គោល ដែលបង្ហាញលទ្ធភាពទាបក្នុងការស្រូបយកហានិភ័យ[d]។ សភាពការណ៍នេះ គូសបញ្ជាក់ភាពចាំបាច់ក្នុងការបន្តកំណែទំរង់នានា ដើម្បីឱ្យមានកំណើនប្រកបដោយនិរន្តរភាពរឹងមាំ ដូចជាបន្តពង្រឹងសារពើពន្ធ និងកៀរគរចំណូលព្រមទាំងការកែលម្អការគ្រប់គ្រងបំណុល និងការគ្រប់គ្រងបំណុលយថាហេតុ។

*c. កំរិតមូលដ្ឋាននេះសន្មត់ថាជាមធ្យមមានការទទួលបំណុល 500 លានដុល្លារអាមេរិករយៈពេលមធ្យម ការសន្មត់ម៉ាក្រូសេដ្ឋកិច្ចមួយដូចតទៅ៖ កំណើនមធ្យមផលិតផលក្នុងស្រុកសរុបពិត 7,2 ភាគរយ អតិផរណា 3,5 ភាគរយ ចំណូលក្នុងស្រុក 14,7 ភាគរយនៃផលិតផលក្នុងស្រុកសរុប ចំណាយ 19,0 ភាគរយ នៃផលិតផលក្នុងស្រុកសរុបនិងជញ្ជីងទូទាត់សរុប 2,4 ភាគរយនៃផលិតផលក្នុងស្រុកក្នុងរយៈពេលមធ្យមពី 2013-2017។ យោងរបាយការណ៍របស់បុគ្គលិកធនាគារពិភពលោកឆ្នាំ 2012 អត្ថបទលេខIVស្តីពីការពិគ្រោះយោបល់រួមគ្នារវាងធនាគារ និងមូលនិធិ DSA.*

*d. សេណារីយ៉ូនេះសន្មត់ថាវឌ្ឍនភាពកំណែទម្រង់ដែលមានកំរិតតិចតួច ការវិនិយោគមានកំរិតទាបកំណើនផលិតផលក្នុងស្រុកសរុបពិត 6,2 ភាគរយ ការនាំចូលនិងការនាំចេញតិច ជញ្ជីងទូទាត់មានសមតុល្យសរុប 1,9 ភាគរយនៃផលិតផលក្នុងស្រុកសរុបចំណូលសារពើពន្ធ 13,7 ភាគរយនៃផលិតផលក្នុងស្រុកសរុប និងទទួលបានទឹកប្រាក់កម្ចីពីបរទេសមានចំនួនកាន់តែច្រើន។*

**រដ្ឋាភិបាលកណ្តាល: ចំណូលតាមផ្នែកសំខាន់ៗ**

(ពីដើមឆ្នាំដល់បច្ចុប្បន្ន%នៃចំណូលសរុប)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស្ថាប័នប្រមូលចំណូល

50- **មានស្ថាប័នប្រមូលចំណូលដ៏សំខាន់ៗចំនួនពីរគឺអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDCE) និងអគ្គនាយកដ្ឋានពន្ធដារ (GDT)។** GDCE និងGDT ប្រមូលចំណូលបានប្រហែល 75 ភាគរយនៃប្រាក់ចំណូលក្នុងស្រុកសរុប។ ចំណែកផ្សេងទៀតគឺចំណូលមិនមែនសារពើពន្ធ និងចំណូលមូលធន ត្រូវបានប្រមូលដោយស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរខេត្ត។ GDCE ទទួលខុសត្រូវក្នុងការប្រមូលពន្ធពាណិជ្ជកម្មអន្តរជាតិ ដែលរួមមានពន្ធសំខាន់ៗពីការនាំចូល និងការនាំចេញ និងអាករលើតម្លៃបន្ថែម និងអាករពិសេសលើការនាំចូល។ GDCE នៅតែជាស្ថាប័នប្រមូលចំណូលធំបង្អស់

*30 សហគមន៍សេដ្ឋកិច្ចអាស៊ានមានសមាហរណកម្មសេដ្ឋកិច្ចនៅឆ្នាំ 2015។ សហគមន៍នេះនឹងប្រែក្លាយអាស៊ានទៅក្នុងតំបន់មួយដែលមានចរាចរទំនិញ សេវាការវិនិយោគពលកម្មជំនាញដោយសេរីនិងលំហូរមូលធនកាន់តែសេរី។*

ដែលប្រមូលបានច្រើនជាង 40 ភាគរយនៃប្រាក់ចំណូលក្នុងស្រុកសរុប។ GDT ទទួលខុសត្រូវជាចម្បងក្នុងការប្រមូលពន្ធក្នុងស្រុករួមមានពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែមក្នុងស្រុក អាករពិសេស និងពន្ធផ្សេងទៀត៖ ដូចជាពន្ធអចលនទ្រព្យ និងពន្ធយានយន្តជាដើម។

**រដ្ឋាភិបាលកណ្តាល: ចំណូលអនុវត្តដោយស្ថាប័នចំណូលសំខាន់ៗ**

(គិតជាភាគរយនៃផសសស-ពីដើមឆ្នាំដល់បច្ចុប្បន្ន)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ចំណាយ និងផ្នែកសំខាន់ៗ

51- **ការអនុវត្តន៍ចំណាយសាធារណៈហាក់ដូចជាមានល្បឿនយឺតក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ 2013 ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន[31]។** នៅក្នុងឆ្នាំ2012ចំណាយសាធារណៈសរុបមានចំនួន 11.448 ពាន់លានរៀល (ស្មើនឹង 2,7 ពាន់លានដុល្លារអាមេរិក) ហើយប្រទេសកម្ពុជាបន្តពឹងផ្អែក ជាខ្លាំងលើមូលនិធិម្ចាស់ជំនួយ ដើម្បីធ្វើហិរញ្ញប្បទាននិយោគសាធារណៈ។ ចំណាយសរុបស្មើនឹង 19,7 ភាគរយនៃផលិតផលក្នុងស្រុកសរុបដែលមានទំហំធំ ធៀបទៅនឹងកម្រិតជាមធ្យមក្នុងតំបន់[32]។ ដោយសារតែវិនិយោគសាធារណៈទទួលមូលនិធិច្រើនពីម្ចាស់ជំនួយ (ហិរញ្ញប្បទានដោយកម្ចីសម្បទាន និងជំនួយឥតសំណង) កម្ពុជាមានលទ្ធភាពរក្សាស្ទើរតែក្នុងកំរិត 50-50 រវាងចំណាយចរន្ត និងចំណាយមូលធននៃចំណាយរបស់រាជរដ្ឋាភិបាលទូទៅ[33]។ ចំណាយចរន្តត្រូវបានផ្តល់ហិរញ្ញប្បទានពេញលេញពីចំណូលក្នុងស្រុក ខណៈពេលដែលជិត 80 ភាគរយនៃចំណាយវិនិយោគសាធារណៈសរុបបានទទួលហិរញ្ញប្បទានពីមូលនិធិបរទេស (ម្ចាស់ជំនួយ)។

**រដ្ឋាភិបាលកណ្តាល: សមាសភាគចំណាយចរន្ត**

(ពីដើមឆ្នាំដល់បច្ចុប្ប គិតជាភាគរយនៃផសសស)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ចំណាយចរន្ត

52- **បញ្ជីប្រាក់ខែបន្តគ្របដណ្តប់មួយផ្នែកធំនៃការចំណាយចរន្តសរុប។** ក្នុងឆ្នាំ 2012 ក្នុងបរិមាណចំណាយចរន្តសរុបចំនួន 6.059 ពាន់លានរៀល (សមមូលនឹង 1,5 ពាន់លានដុល្លារអាមេរិក) ឬ 10,4 ភាគរយនៃផលិតផលក្នុងស្រុកសរុបបញ្ជីប្រាក់ខែគ្របដណ្តប់40ភាគរយ (ឬ4,2ភាគរយនៃផលិតផលក្នុងស្រុកសរុប)។ ជាលទ្ធផលការផ្តល់វិភាជន៍មូលនិធិមិនមែនប្រាក់ខែ ពិសេសមូលនិធិសម្រាប់ប្រតិបត្តិការនិងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (កសាងដោយមូលនិធិម្ចាស់ជំនួយ) បន្តជួបការលំបាក។ ចំណាយការពារជាតិនិងសន្តិសុខសរុបស្មើនឹង 22 ភាគរយនៃចំណាយចរន្តសរុប (ឬ 2,3 ភាគរយនៃផលិតផលក្នុងស្រុកសរុប) ខណៈដែលប្រាក់ខែវិស័យការពារជាតិនិងសន្តិសុខគ្របដណ្តប់ 40 ភាគរយនៃបញ្ជីប្រាក់ខែសរុប។ ការទូទាត់ការប្រាក់មានត្រឹមតែ 0,3 ភាគរយនៃផលិតផលក្នុងស្រុកសរុប ដោយសារច្បាប់ថវិកាបច្ចុប្បន្នអនុញ្ញាតឱ្យខ្ចីតែកម្ចីសម្បទានប៉ុណ្ណោះ។

31 *ការប្រៀបធៀបផ្តែកលើការចំណាយពីហិរញ្ញប្បទាន ក្នុងស្រុកតែប៉ុណ្ណោះ ដោយសារឆ្នាំ2013មានទិន្នន័យ មិនពេញលេញពោលគឺគ្មានទិន្នន័យទុនហិរញ្ញប្បទានពីពីបរទេសឡើយ។*

32 *ចំនួននេះមិនរាប់បញ្ចូលទឹកប្រាក់ចំណាយសាធារណៈ "ក្រៅថវិកា" ការ (សមាសភាគដ៏ធំបំផុតគឺ ហិរញ្ញប្បទានជំនួយបច្ចេកទេសពីម្ចាស់ជំនួយ) ត្រូវបានប៉ាន់ស្មានថាជាមធ្យមប្រហែល 3ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងមួយឆ្នាំ។*

33 *ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រាក់ចំណូលរបស់រដ្ឋាភិបាលទូទៅ (ឬចំណាយ) រួមមានប្រាក់ចំណូល (ឬចំណាយ) ដែលប្រមូលដោយរដ្ឋាភិបាលកណ្តាលនិងអាជ្ញាធរខេត្ត។ ចំណូលថ្នាក់ខេត្តគ្របដណ្តប់ពី 4-9 ភាគរយនៃប្រាក់ចំណូលក្នុងស្រុកសរុប។*

**រដ្ឋាភិបាលកណ្តាល: សមាសភាគចំណាយចរន្ត**

(ពីដើមឆ្នាំដល់បច្ចុប្បន្ន ភាគរយនៃផសស)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**រដ្ឋាភិបាលកណ្តាល: សមាសភាគចំណាយ**

(ពីដើមឆ្នាំដល់បច្ចុប្បន្ន ភាគរយនៃផសស)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ចំណាយមូលធន

53- **ដើម្បីធ្វើហិរញ្ញប្បទានលើកាតព្វកិច្ច វិនិយោគសាធារណៈ រដ្ឋាភិបាលកៀរគរជំនួយអភិវឌ្ឍន៍ពីបរទេស (ODA) យ៉ាងច្រើន។** ចំណូលក្នុងស្រុកទាប (ចំណូលរបស់ប្រទេសកម្ពុជាធៀបនឹងអនុបាតផលិតផលក្នុងស្រុកសរុបនៅតែមានកម្រិតទាប ធៀបនឹងស្តង់ដារក្នុងតំបន់) ធ្វើឱ្យរដ្ឋាភិបាលមានសមត្ថភាពតិចតួចក្នុងការប្រើប្រាស់ថវិការបស់ខ្លួន ក្នុងការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពប្រតិបត្តិការ និងសកម្មភាពនៃវិនិយោគមូលធន ដែលភាគច្រើនទទួលមូលនិធិពី ODA។ ចំណាយមូលធន ដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយមានចំនួនជិតស្មើនឹង80ភាគរយនៃវិនិយោគសាធារណៈសរុប ឬ 34 ភាគរយនៃចំណាយសាធារណៈសរុប [34]។

## តុល្យការចំណូលសារពើពន្ធ

54- **ការបន្តមានកំណើនប្រាក់ចំណូល និងចំណាយឃឹត គប្បីធ្វើឱ្យឱនភាពថវិកា (មិនរួមបញ្ចូលជំនួយឥតសំណង) មានកំរិតដូចបានគ្រោងទុកជុំវិញ 5,4 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2013។** ជាទូទៅខណៈពេលដែលការគ្រប់គ្រងសារពើពន្ធ ជារួមមានភាពសមស្រប និងអំណោយផលដល់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច គាំទ្រដោយគោលការណ៍គ្រឹះនៃតុល្យភាពថវិកា ត្រូវកែលំអបន្ថែមនូវការអនុវត្តន៍ចំណូលក្នុងស្រុក។ ការប្រមូលចំណូលបានច្រើន និងការបន្ថយចំណាយក្នុងឆ្នាំ 2012 ធ្វើឱ្យឱនភាពថវិកាឆ្នាំ 2012 រួមតូច។ ដោយមិនគិតដល់ជំនួយឥតសំណងនៅឆ្នាំ2012ឱនភាពសារពើពន្ធស្មើនឹង 5,2 ភាគរយនៃផលិតផលក្នុងស្រុកសរុប ធៀបនឹង 9,5 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2011។ ឱនភាពថវិកា រួមមាន ជំនួយឥតសំណងត្រូវបានកាត់បន្ថយមកត្រឹមតែ 0,1 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2012 ធៀបនឹង 4,6 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2011។

*34 ចំណាយដែលបានមកពីម្ចាស់ជំនួយខាងលើ មិនរាប់បញ្ចូលហិរញ្ញប្បទានជំនួយបច្ចេកទេសទេ*

55- ការបន្តទទួលមូលនិធិច្រើនពីបរទេស ដើម្បីធ្វើហិរញ្ញប្បទានលើវិនិយោគសាធារណៈ អនុញ្ញាតឱ្យកម្ពុជាបង្កើនប្រាក់សន្សំ។ ការបង្កើនប្រាក់បញ្ញើរបស់រដ្ឋាភិបាល ធ្វើឱ្យរដ្ឋាភិបាល អាចប្រើប្រាក់នោះក្នុងពេលមានវិបត្តិ។ ក្នុងពេលមាន មានវិបត្តិហិរញ្ញវត្ថុសាកលឆ្នាំ 2008 និង 2009 រដ្ឋាភិបាល បានដាក់ឱ្យប្រើនូវគោលនយោបាយបង្កើនចំណាយសារពើពន្ធ គាំទ្រកម្មវិធីបណ្តុះបណ្តាលសាជាថ្មីដល់កម្មករដែលត្រូវបាន បញ្ឈប់ពីការងារ កម្មវិធីស្វ័យផ្តល់ការងារ អាហារូបករណ៍ និងការផ្តល់ប្រាក់កម្ចីដល់ការអភិវឌ្ឍកសិកម្ម។ នៅឆ្នាំ 2012 រដ្ឋាភិបាល មានលទ្ធភាពបង្កើនប្រាក់បញ្ញើរបស់ខ្លួនជិតស្មើនឹង 650 លានដុល្លារអាមេរិកនៅដំណាច់ឆ្នាំ (ជិតស្មើនឹងកម្រិតមុនពេលមានវិបត្តិ )។

**ប្រតិបត្តិការរបស់រដ្ឋាភិបាលទូទៅ**
(គិតជាភាគរយនៃផសស)




សំគាល់៖ P= បណ្តោះអាសន្ន; B=ថវិកា
ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

56- ដូចដែលបានរៀបរាប់ពីខាងលើក្នុងផ្នែករូបិយវត្ថុ ប្រទេសកម្ពុជាត្រូវពឹងផ្អែកស្ទើរតែទាំងស្រុង លើគោលនយោបាយសារពើពន្ធរបស់ខ្លួនដើម្បីគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់។ ដូច្នេះជាការសំខាន់ណាស់ដែលថា គោលនយោបាយសារពើពន្ធត្រឹមត្រូវៗរក្សាបានយ៉ាងល្អ និងការបន្តគាំទ្រយ៉ាងទូលំទូលាយ និងដោយសប្បុរស (សូម្បីតែក្នុងពេលមានវិបត្តិហិរញ្ញវត្ថុសកល) ពីម្ចាស់ជំនួយបានជួយធ្វើឱ្យការងារនេះអាចប្រព្រឹត្តទៅបាន។

**រដ្ឋាភិបាលកណ្តាលហិរញ្ញប្បទានឱនភាពសរុប**
(គិតជាភាគរយនៃផសស)




សំគាល់៖ P= បណ្តោះអាសន្ន; B=ថវិកា
ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ចំណាយតាមវិស័យ

57- អត្រាភាគរយនៃវិស័យសុខាភិបាល និងវិស័យអប់រំក្នុងការចំណាយហិរញ្ញប្បទានក្នុងស្រុកបានធ្លាក់ចុះដល់ 8,7 ភាគរយ និង 10,3 ភាគរយនៅក្នុងឆ្នាំ 2011 ពី 9,1 ភាគរយ និង 15,6 ភាគរយក្នុងឆ្នាំ 2004។ ការណ៍នេះបង្ហាញថាវិស័យអប់រំ និងសុខភាពបានទំនងជាបាត់បង់អាទិភាពនៅក្នុងការបែងចែក និងការបម្រុងទុកថវិកាធៀបនឹងវិស័យប្រកួតប្រជែងផ្សេងៗទៀត។

**ចំណាយចរន្តផ្នែកសុខាភិបាលនិងអប់រំ**
(គិតជាភាគរយនៃថវិកាសរុប)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

58- អត្រាភាគរយរួមគ្នារវាងរដ្ឋបាលទូទៅ និងវិស័យការពារជាតិ និងសន្តិសុខ បានកើនឡើងយ៉ាងឆាប់រហ័សដល់ 60 ភាគរយ នៃការចំណាយសរុបក្នុងឆ្នាំ 2011 គឺកើនឡើងពី 44,3 ភាគរយក្នុងឆ្នាំ 2007។ ការណ៍នេះ ឆ្លុះបញ្ចាំងនូវការកើន

ឡើងនូវតម្រូវការចំណាយពាក់ព័ន្ធនឹងរដ្ឋបាលទូទៅ សន្តិសុខ និងការពារជាតិធ្វើឱ្យប៉ះពាល់ដល់ធនធានដែលនឹងត្រូវផ្តល់ឱ្យវិស័យផ្សេងទៀត ពិសេស គឺវិស័យសង្គមកិច្ច។

**ចំណាយតាមវិស័យ**

(គិតជាភាគរយនៃថវិកាសរុប)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

59- **គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប ចំណាយដែលហិរញ្ញប្បទានពីប្រភពក្នុងស្រុកលើ វិស័យសុខាភិបាលកំពុងមាននិន្នាការកើនឡើង គឺកើនឡើងដល់** 1,3 **ភាគរយនៅឆ្នាំ** 2011 **ពី** 1,0 **ភាគរយក្នុងឆ្នាំ** 2007 **ចំណែកឯចំណាយលើវិស័យអប់រំមិនបានកើនឡើងឡើយ ហើយនៅតែមានកម្រិតប្រមាណជា** 1,6 **ភាគរយនៃផលិតផលក្នុងស្រុកសរុបចាប់តាំងពីឆ្នាំ** 2007 **រហូតមក។** ចំណែកភាគរយនៃវិស័យសុខាភិបាល និងវិស័យអប់រំ នៅក្នុងការចំណាយដែលហិរញ្ញប្បទានពីប្រភពក្នុងស្រុកសរុបថយចុះដល់ 8,7 ភាគរយ និង 10,3 ភាគរយ នៅឆ្នាំ 2011 គឺចុះពី 9,8 ភាគរយ និង 14,2 ភាគរយក្នុងឆ្នាំ 2007។ របាយការណ៍ចុងក្រោយស្តីពីការវាយតំលៃចំរុះលើទំនុកចិត្តនិងការពិនិត្យសើរើឡើងវិញនូវចំណាយសាធារណៈ (IFAPER) ដែលបានបោះពុម្ពនៅឆ្នាំ 2011 បានរកឃើញថា ចំណាយសាធារណៈលើវិស័យអប់រំរបស់ប្រទេសកម្ពុជា (ហិរញ្ញប្បទានពីប្រភពក្នុងស្រុកនិងពីបរទេស) មានចំនួនត្រឹមតែពាក់កណ្តាលនៃបណ្តាប្រទេសដែលមានកម្រិតអភិវឌ្ឍដូចគ្នាតែប៉ុណ្ណោះ។ របាយការណ៍ IFAPER ក៏បានគូសបញ្ជាក់សក្តានុពលសន្សំ រហូតដល់មួយភាគបីនៃថវិកាសុខាភិបាលសរុប ហើយការសន្សំអាចអនុវត្តបានតាមរយៈការកែលម្អដំណើរការលទ្ធកម្មថ្នាំពេទ្យ។ ហេតុនេះ ចាំបាច់ត្រូវពិនិត្យឡើងវិញនូវអាទិភាពចំណាយ និងប្រសិទ្ធភាពតាមវិស័យ។

**ចំណាយតាមវិស័យដែលផ្តល់ហិរញ្ញប្បទានពីប្រភពក្នុងស្រុក**

(គិតជាភាគរយនៃផសស)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឃ- សេចក្តីសន្និដ្ឋាន

60- **កំណើនសេដ្ឋកិច្ចនៅមានមូលដ្ឋានតូចចង្អៀត ហើយការទ្រទ្រង់កំណើនសេដ្ឋកិច្ចដ៏រឹងមាំតាមរយៈ ការជំរុញពិពិធកម្ម និងការលើកកំពស់ភាពប្រកួតប្រជែង គឺជាការចាំបាច់។** ការបន្តវិនិយោគក្នុងវិស័យកសិកម្ម ធ្វើឱ្យមានកំណើនកសិកម្មខ្ពស់ប្រកបដោយនិរន្តរភាព បង្កើតបានជាមាគ៌ាឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ។ វិស័យកសិកម្មរឹងមាំក៏ជួយធ្វើជាទ្រនាប់ទប់ទល់នឹងវិបត្តិពីខាងក្រៅផងដែរ។ របបពាណិជ្ជកម្មនិងវិនិយោគសេរីនិងសំដៅនាំចេញ ដែលកំពុងអនុវត្តបច្ចុប្បន្នទំនងជាសមស្រប គឺដើម្បីដោះស្រាយបញ្ហាទីផ្សារក្នុងស្រុកនៅកម្ពុជាដែលមានទំហំតូច និងមិនសូវរីកចម្រើន។ ទោះជាយ៉ាងណាក្តី ពិពិធកម្មដើម្បីពង្រីកឧត្តមភាពប្រៀបធៀប និងភាពប្រកួតប្រជែងជាការចាំបាច់ ដើម្បីទទួលបានជោគជ័យនៅទូទាំងពិភពលោក។ ប្រទេសកម្ពុជា បានទទួលជោគជ័យជាបង្គួរ ក្នុងការបង្កើនទីផ្សារសម្រាប់វិស័យកាត់ដេរ និងវិស័យទេសចរណ៍។ ទោះជាយ៉ាងណាក្តី ការលើកកំពស់ភាពប្រកួតប្រជែងរបស់កម្ពុជាមានល្បឿនយឺត ហើយឧត្តមភាពប្រៀបធៀបតែមួយគត់របស់កម្ពុជាគឺ កំលាំងពលកម្មថោក កំពុងចុះខ្សោយជាបណ្តើរៗ ដោយសារតែកង្វះកម្លាំងពលកម្ម និងការកើនឡើងនូវថ្លៃពលកម្ម។ ដើម្បីច្បាមយកផលបន្ថែមទៀត និងដើម្បីចូលទៅកាន់ផ្នែកខាងលើនៃខ្សែសង្វាក់តម្លៃ វិស័យសាធារណៈទំនងជាត្រូវបោះជំហានចូល និងបំពេញតួនាទីកាន់តែធំផងដែរ។ ការធានាអត្ថិភាពនៃកម្លាំងពលកម្មសមស្របមានជំនាញ និងមានថ្លៃកត្តាផលិតកម្មដែលមានលក្ខណៈប្រកួតប្រជែង (ដូចជា ថ្លៃថាមពល ជាដើម ) សម្រាប់ទីផ្សារគឺជាវិធីនានាដែលវិស័យសាធារណៈអាចជួយថែបំប៉នវិស័យឯកជន។

61- **ត្រូវតែរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ។** ខណៈធនាគារពាណិជ្ជជាច្រើនចូលទៅក្នុងទីផ្សារប្រទេសកម្ពុជា ជួយធ្វើឱ្យប្រសើរឡើងនូវការប្រកួតប្រជែង និងប្រសិទ្ធភាព សភាពការណ៍នេះក៏បង្កហានិភ័យហិរញ្ញវត្ថុជាច្រើនផងដែរ ដោយសារតែមានបញ្ហាប្រឈមលើសមត្ថភាពត្រួតពិនិត្យ។ អស្ថេរភាពនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុណាមួយ ជាពិសេសនៅពេលដែលធនាគារកណ្តាលមិនអាចដើរតួជាស្ថាប័នឱ្យខ្ចីនៅនាទីចុងក្រោយ បណ្តាលមកពីដុល្លារូបនីយកម្ម អាចធ្វើឱ្យជំនឿទុកចិត្តរបស់សាធារណជនដែលពិបាកកសាង បាត់បង់ទៅវិញ។ ដុល្លារូបនីយកម្មកម្រិតខ្ពស់ធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយអត្រាប្តូរប្រាក់និងនាំទៅរកការខាតបង់ស៊ីញ៉ូរ៉ាហ្ស។ ចាំបាច់ត្រូវប្រកាន់យកជំហានច្បាស់លាស់ ក្នុងការធ្វើបដិដុល្លារូបនីយកម្មសេដ្ឋកិច្ចកម្ពុជា[35]។

62- **ការកែលម្អការគ្រប់គ្រងសារពើពន្ធដោយបង្កើនលំហសារពើពន្ធ និងចំណាយមានប្រសិទ្ធិភាពបន្ថែមទៀតគឺជាការចាំបាច់។** ការរឹតបន្តឹងការប្រមូលចំណូល និងការពិនិត្យមើលឡើងវិញនូវប្រសិទ្ធភាពនឹងជួយបង្កើតលទ្ធភាពសម្រាប់វិភាជបន្ថែម ដល់វិស័យអាទិភាព ដូចជា វិស័យកសិកម្ម និងវិស័យអប់រំដែលមានសារៈសំខាន់សម្រាប់ការទ្រទ្រង់កំណើនដ៏រឹងមាំ និងសម្រាប់ទាំងអស់គ្នា។ ការពិនិត្យមើលសាឡើងវិញនូវប្រសិទ្ធិភាពចំណាយចំពោះវិស័យសុខាភិបាល អាចជួយឱ្យអនុវត្តបាននូវប្រាក់សន្សំដែលមានសក្តានុពល ដូចបានផ្តល់អនុសាសន៍ដោយរបាយការណ៍ស្តីពីការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញនូវចំណាយសាធារណៈឆ្នាំ2011។

## ខ- ប្រធានបទពិសេសសម្រាប់លេខនេះ៖ ស្ថានភាព ភាពក្រីក្រ

### *កំណើនសេដ្ឋកិច្ចកាន់តែមានលក្ខណៈទូលាយជាងកាលពីពេលមុន*

63- **ក្នុងរយៈពេលប្រាំពីរឆ្នាំពី 2004 ដល់ឆ្នាំ 2011 ប្រទេសកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់។** ជាមធ្យមអត្រាកំណើនប្រចាំឆ្នាំរបស់ប្រទេសកម្ពុជាគឺ 8 ភាគរយហើយក្នុងអំឡុងពេលនេះអត្រាកំណើនឈានឡើងតួលេខពីរខ្ទង់ ក្នុងរយៈពេលបួនឆ្នាំជាប់គ្នាដោយសម្រេចបាននូវអត្រាមធ្យម 11,1 ភាគរយពីឆ្នាំ 2004 ដល់ឆ្នាំ 2007។ ឆ្នាំដែលកំណើនត្រូវបានបង្អាក់គឺឆ្នាំ 2009 នៅពេលដែលកត្តាចំបងដែលជំរុញសេដ្ឋកិច្ចកម្ពុជារងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកល។

64- **ក្រៅពីសម្រេចបានកំណើនជាបន្តបន្ទាប់ កម្ពុជាក៏បានពង្រីកមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួនដែរ ដោយបានពង្រាយអត្ថប្រយោជន៍ពីកំណើនដល់ប្រជាពលរដ្ឋទូទៅ។** ចាប់ពីឆ្នាំ 2004 ដល់ឆ្នាំ 2007 កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានដឹកនាំជាចម្បង ដោយវិស័យកាត់ដេរទេសចរណ៍ និងសំណង់។ វិស័យកសិកម្ម ដែលមានចំណែកប្រហែលមួយភាគបីនៃសេដ្ឋកិច្ច និងជាវិស័យដែលផ្តល់ការងារដល់ប្រជាពលរដ្ឋជុំវិញជាច្រើន មិនត្រូវចាត់ទុកថាវិស័យចម្បងឡើយដោយសារតែមានអត្រាកំណើនទាប។ ប៉ុន្តែចាប់តាំងពីឆ្នាំ 2008 មកកំណើនវិស័យកសិកម្ម បានក្លាយទៅជាកត្តាមួយដ៏សំខាន់នៃកំណើន សេដ្ឋកិច្ច (រូបភាព ក)។ កំណើនកសិកម្មមិនត្រឹមតែ រួមចំណែកជំរុញផលិតផលក្នុងស្រុកសរុបឱ្យខ្ពស់ជាបន្តបន្ទាប់ប៉ុណ្ណោះទេប៉ុន្តែក៏ជួយពង្រាយអត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ច ទៅកាន់ក្រុមប្រជាពលរដ្ឋក្រីក្របំផុតនៃប្រជាពលរដ្ឋទូទៅផងដែរ (រូប ភាព ខ) ប្រការនេះមានន័យថា កំណើនរបស់ប្រទេសកម្ពុជា សព្វថ្ងៃកាន់មានមូលដ្ឋានទូលំទូលាយ និងចែករំលែកផល បានដល់ពលរដ្ឋក្រីក្រច្រើនជាងកាលពីពេលមុន។

---

*35 មានឯកសារជាច្រើនស្តីពីបដិដុល្លារូបនីយកម្មដែលផ្តល់យោបល់ឱ្យកម្ពុជាធ្វើបដិដុល្លារូបនីយកម្មជាបណ្តើរៗ*

**ក- អត្រាកំណើនតាមវិស័យពីឆ្នាំ 2004-2011**

(ថ្លៃថេរឆ្នាំ 2000)




ប្រភព៖ គណនីជាតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

**ខ- ការប្រើប្រាស់ប្រចាំថ្ងៃរបស់ពលរដ្ឋម្នាក់ៗតាមក្រុមបញ្ចភាគ**

(ថ្លៃថេរឆ្នាំ 2000 នៅភ្នំពេញ)




ប្រភព៖ ការគណនារបស់បុគ្គលិកធនាគារពិភពលោកដោយយោងតាម អ.ស.ស.ក




ប្រភព៖ ការគណនារបស់បុគ្គលិកធនាគារពិភពលោកដោយយោងតាម អ.ស.ស.ក

65- **ជាលទ្ធផលនៃល្បឿនដ៏ឆាប់រហ័សនៃកំណើន និងលំនាំនៃកំណើន ដែលបានចែករំលែកអត្ថប្រយោជន៍ដល់ចំណោមប្រជាពលរដ្ឋមួយចំនួនធំរបស់កម្ពុជា ភាពក្រីក្របានធ្លាក់ចុះយ៉ាងខ្លាំង។** អត្រាភាពក្រីក្របានធ្លាក់ចុះជាងពាក់កណ្តាលក្នុងរយៈពេលប្រាំពីរឆ្នាំពី 53,0 ភាគរយនៅក្នុងឆ្នាំ 2004 ដល់ 20,5 ភាគរយនៅក្នុងឆ្នាំ 2011 លើសការរំពឹងទុកទាំងឡាយ និងលើសពីចំណុចដៅ កាត់បន្ថយភាពក្រីក្រនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាយ៉ាងច្រើន។ តួលេខចុងក្រោយបំផុតបង្ហាញថា ចំនួនប្រជាពលរដ្ឋក្រីក្រសរុបបានធ្លាក់ចុះពី 7 លាននាក់នៅក្នុងឆ្នាំ 2004 ដល់ 3 លាននាក់ក្នុងឆ្នាំ 2011។ម្យ៉ាងវិញទៀត គេអាចនិយាយបានថាក្នុងចំណោម 10 នាក់ មានប្រជាពលរដ្ឋតែ 2 នាក់ប៉ុណ្ណោះ ជាប្រជាពលរដ្ឋក្រីក្រនៅឆ្នាំ 2011 ធៀបនឹង 5 នាក់ នៅឆ្នាំ 2004។ ក្នុងចំណោមបណ្តាប្រទេសចំនួន 69 ដែលមានទិន្នន័យអាចប្រៀបធៀបជាមួយកម្ពុជាបានពីឆ្នាំ 2004 ដល់ឆ្នាំ 2008 កម្ពុជាទទួលបានចំណាត់ថ្នាក់ទីបួនលើការកាត់បន្ថយ ភាពក្រីក្របន្ទាប់ពីតំបន់វេសប៊ែង និងហ្គាហ្សា ប៊ូតង់ និងប្រទេស ហ្វីជី។ នេះមានន័យថា ប្រទេសកម្ពុជា គឺជាប្រទេសដែលកាត់បន្ថយភាពក្រីក្របានលឿនបំផុតនៅអាស៊ីបូព៌ា។

66- **ការធ្លាក់ចុះយ៉ាងខ្លាំងនៃភាពក្រីក្រ ក៏បានឆ្លុះបញ្ចាំងផងដែរតាមរយៈសូចនាករសុខុមាលភាព ដូចជាការកែលម្អលំនៅដ្ឋាន និងកម្មសិទ្ធិភាពនៃទ្រព្យសម្បត្តិ។** ឧទាហរណ៍ពីឆ្នាំ 2004 ដល់ឆ្នាំ 2011 ចំនួនគ្រួសារ ដែលមានអគ្គិសនីប្រើប្រាស់ (កើនឡើងបីដង) មានប្រព័ន្ធប្រព័ន្ធលូបង្ហូរ ឬអាងសំអាតទឹកសំអុយ (កើនឡើងពីរដង) និងទឹកស្អាតនៅរដូវប្រាំង (កើនឡើង 25 ភាគរយ) កម្មសិទ្ធិភាពលើរបស់របរប្រើប្រាស់ក្នុងផ្ទះ ដូចជាទូរទស្សន៍កើនឡើង (37 ភាគរយ) ម៉ូតូ (កើនឡើងពីរដង) និងទូរស័ព្ទចល័ត (កើនឡើងបួនដង) ដែលទាំងអស់នេះ គូសបញ្ជាក់អំពីកំណើននៃការប្រើប្រាស់។

### គ- អត្រាភាពក្រីក្រ




ប្រភព៖ ការវាយតម្លៃភាពក្រីក្រកម្ពុជាឆ្នាំ 2013 ដោយធនាគារពិភពលោក

### ឃ- របាយការណ៍នៃការចំណាយរបស់ក្រុមប្រជាពលរដ្ឋ




ប្រភព៖ ការវាយតម្លៃភាពក្រីក្រកម្ពុជាឆ្នាំ 2013 ដោយធនាគារពិភពលោក

### ង- កត្តាចម្បងៗក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាពីឆ្នាំ 2004-2011




ប្រភព៖ ការវាយតំលៃភាពក្រីក្រកម្ពុជាឆ្នាំ 2013 ដោយធនាគារពិភពលោក

67- **របាយការណ៍វាយតម្លៃភាពក្រីក្រនៃប្រទេសកម្ពុជាចុងក្រោយរបស់ធនាគារពិភពលោកបានរកឃើញថា ការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃភាពក្រីក្រដោយសារកត្តាចម្បងៗ ចំនួនប្រាំ៖** (i) ថ្លៃអង្ករខ្ពស់; (ii) ផលិតកម្មស្រូវកើនឡើងច្រើន (iii) ចំណូលខ្ពស់បានមកពីអាជីវកម្មក្រៅពីកសិកម្ម (iv) អត្រាប្រាក់ឈ្នួលខ្ពស់របស់កម្មករនៅតាមជនបទនិង (v) កំណើនការងារផ្តល់ប្រាក់ខែនៅតំបន់ទីប្រជុំជន (រូប ង)។ ទោះជាយ៉ាងណាក្តី កត្តាជំរុញទាំងនេះមិនមែនកើតឡើងព្រមគ្នាក្នុងពេលតែមួយនោះទេ។ តម្លៃអង្ករខ្ពស់ កំណើនផលិតកម្មស្រូវ ប្រាក់ចំណូលកើនខ្ពស់ពីអាជីវកម្មមិនមែនកសិកម្ម និងអត្រាប្រាក់ឈ្នួលកម្មករខ្ពស់នៅតាមជនបទ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងឆ្នាំ 2008 និងឆ្នាំ 2009 នៅពេលដែលវិបត្តិតម្លៃស្បៀងអាហារសកលបានកើតឡើង ចំណែកឯកំណើនការងារផ្តល់ប្រាក់ខែនៅតំបន់ទីប្រជុំជនបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងអំឡុងពេល មុនឆ្នាំ 2008។

68- **ប៉ុន្តែតើប្រជាពលរដ្ឋទាំងអស់ ដែលពីមុនជាប្រជាពលរដ្ឋក្រីក្រ ទៅណាហើយ? ជាអកុសលពួកគេបានមិនបានទៅណាឆ្ងាយណាស់ណានោះទេ។** គ្រួសារពលរដ្ឋភាគច្រើនមានជីវភាពរស់នៅក្បែរបន្ទាត់ភាពក្រីក្រប៉ុណ្ណោះ។ ពួកគេនៅតែប្រឈមមុខនឹងហានិភ័យខ្ពស់ ហើយអាចធ្លាក់ចូលក្នុងភាពក្រីក្រវិញ នៅពេលមានវិបត្តិប្រាក់ចំណូល តែបន្តិចបន្តួចប៉ុណ្ណោះ។ ឧទាហរណ៍ប្រសិនបើមានហេតុការណ៍ណាមួយដែលធ្វើឱ្យបាត់បង់ប្រាក់ចំណូលត្រឹមតែ 1200 រៀល / ថ្ងៃ (ស្មើនឹង0,30ដុល្លារអាមេរិក)នោះពលរដ្ឋកម្ពុជាប្រមាណជា 3 លាននាក់នឹងធ្លាក់ក្នុងភាពក្រីក្រសាជាថ្មី។ ការណ៍នេះនឹងបង្កើនអត្រាភាពក្រីក្ររបស់កម្ពុជាទ្វេដង ដល់ 40 ភាគរយ។

69- **កម្ពុជាមិនត្រឹមតែមានបញ្ហា គ្រួសារពលរដ្ឋភាគច្រើនប្រឈមមុខនឹងហានិភ័យនៃការធ្លាក់ចុះក្នុងភាពក្រីក្រជាថ្មីនោះទេ ប៉ុន្តែ ប៉ុន្តែគម្លាតយ៉ាងធំរវាងគ្រួសារក្រីក្រនិងគ្រួសារធូរធារទាក់ទងស្ថានភាពសុខភាពនៅតែមាន។** ចំណុចនេះ មិនត្រឹមតែឆ្លុះបញ្ចាំងភាពខុសគ្នា លើវិសាលភាពអន្តរាគមន៍សង្គ្រោះជីវិតប៉ុណ្ណោះទេ ប៉ុន្តែគេក៏សង្កេតឃើញគម្លាតលើគុណភាពនៃការថែទាំសុខភាពផងដែរ។ បញ្ហាប្រឈមមួយទៀតដែលគេបានសម្គាល់ឃើញ លើស្ថានភាពសុខភាពគឺកង្វះវឌ្ឍនភាពពាក់ព័ន្ធនឹងកង្វះអាហារូបត្ថម្ភរបស់កុមារ។ ចាប់ពីឆ្នាំ 2005

ដល់ឆ្នាំ 2010 ភាគរយនៃកុមារក្រិន អាយុក្រោមប្រាំឆ្នាំបានថយចុះពី 42 ទៅ 40 ភាគរយប៉ុណ្ណោះ ខណៈពេលដែលកុមារមានទម្ងន់មិនគ្រប់នៅទ្រឹងត្រឹម 38 ភាគរយហើយផ្ទុយទៅវិញកុមារស្គមស្គាំងបានកើនឡើងពី 8 ទៅ 11 ភាគរយ។

70- **ក្នុងវិស័យអប់រំ ការចូលរៀននៅថ្នាក់ទីមួយយឺតនៅបឋមសិក្សា និងការចុះឈ្មោះកម្រិតទាបយ៉ាងខ្លាំងរបស់កុមារក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះនៅតែជាបញ្ហាប្រឈមចម្បងមួយ។** សភាពការណ៍នេះបណ្តាលឱ្យមានបញ្ហាលើលទ្ធផលមធ្យមសិក្សា ដូចជាការចុះឈ្មោះចូលរៀនមានចំនួនតិច ការរៀនត្រួតថ្នាក់ច្រើន និងអត្រាបោះបង់ការសិក្សាខ្ពស់។ ទោះបីជាមានការកែលម្អយ៉ាងឆាប់រហ័ស ក្នុងកម្រិត 1,7 ភាគរយក្នុងមួយឆ្នាំពីឆ្នាំ 2004 ដល់ឆ្នាំ 2011 ក្តី អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅមធ្យមសិក្សាទុតិយភូមិនៅឆ្នាំ 2011 នៅតែមានកម្រិតទាប គឺត្រឹមតែ 20 ភាគរយប៉ុណ្ណោះ។ បើទោះជាការធ្វើឱ្យប្រសើរឡើង នូវគុណភាពនៃការអប់រំជាអាទិភាពមួយក្តី គោលនយោបាយនានាដែលកំពុងស្ថិតនៅជាធរមានមិនបានឆ្លើយតបឱ្យមានប្រសិទ្ធិភាពទៅតាមតម្រូវការទីផ្សារការងារឡើយ នៅមានកង្វះគ្រូបង្រៀន កង្វះសៀវភៅសិក្សា មន្ទីរពិសោធន៍វិទ្យាសាស្ត្រ កង្វះឯកសារបង្រៀននិងកង្វះសម្ភារៈសិក្សានៅឡើយ។ កម្ពុជាគួរកែលម្អការសិក្សានិងជំនាញ លើការរិះគិតល្អិតល្អន់ និងមុខវិជ្ជាសំខាន់ៗដូចជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈនិងគណិតវិទ្យា។

71- **បេសកកម្មក្នុងការកាត់បន្ថយ ភាពក្រីក្រនៅប្រទេសកម្ពុជានៅមិនទាន់ចប់នៅឡើយទេដោយសារនៅមានបញ្ហាប្រឈមចំបងៗក្នុងការកាត់បន្ថយ ភាពក្រីក្រ និងក្នុងការកែលំអការអភិវឌ្ឍមនុស្សនៅឡើយ។** មិនត្រឹមតែមានប្រជាពលរដ្ឋជាច្រើននាក់ ប្រឈមមុខនឹងការធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញនោះទេ ប៉ុន្តែការរក្សាឱ្យបាននូវការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័សបែបនេះ កាន់តែពិបាកបន្ថែមទៀតព្រោះថា កត្តាចំបងនៃការកាត់បន្ថយភាពក្រីក្របានមកពីឥទ្ធិពលនៃថ្លៃអង្ករដែលមិនទំនងជាបន្តកើនឡើងឡើយ ហើយបើទោះជាកើនឡើងក៏ប្រហែលជាមិនមានល្បឿនដូចមុនទេ។ ថ្លៃអង្ករអន្តរជាតិ ថ្លៃអង្ករក្នុងស្រុក ឬប្រាក់ឈ្នួលមិនទំនងជាកើនឡើងខ្ពស់ដូចក្នុងអំឡុងឆ្នាំ 2004-09 ដែលកើនឡើង 134 ភាគរយ 119 ភាគរយនិង 200 ភាគរយនោះទេ។

72- **តទៅអនាគត យកល្អប្រទេសកម្ពុជាគួររៀបចំគោលនយោបាយដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ជួយប្រជាពលរដ្ឋក្រីក្រ 20 ភាគរយទៀតឱ្យចាកផុតពីភាពក្រីក្រ និងបង្ការប្រជាពលរដ្ឋ 20 ភាគរយដែលមានជីវភាពស្ទើរក្រីក្រកុំឱ្យធ្លាក់ចូលក្នុងភាពក្រីក្រសាជាថ្មី។** គោលនយោបាយគន្លឹះ ក្នុងការរំដោះប្រជាពលរដ្ឋកំពុងស្ថិតក្នុង ភាពក្រីក្ររួមមាន៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ ការបន្តវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងកំណើនកសិកម្ម។ គោលនយោបាយដើម្បីបង្ការប្រជាពលរដ្ឋស្ទើរក្រីក្រកុំឱ្យធ្លាក់ចូលក្នុងភាពក្រីក្រសាជាថ្មី រួមមាន៖ ការលើកកំពស់ពិពិធកម្មនៃវិស័យកសិកម្ម និងការអនុវត្តន៍យុទ្ធសាស្ត្រគាំពារសង្គម។

# ឧបសម្ព័ន្ធ 1

# សូចនាករសេដ្ឋកិច្ចពិភពលោក

**ខ្លឹមសារសង្ខេបនៃទស្សនវិស័យសកល**

**(ភាគរយប្រែប្រួលពីឆ្នាំមុន លើកលែងអត្រាការប្រាក់ និងថ្លៃប្រេង**

| | 2011 | 2012 | 2013e | 2014f | 2015f |
|---|---|---|---|---|---|
| *ស្ថានភាពសកល* | | | | | |
| បរិមាណពាណិជ្ជកម្មពិភពលោក (GNFS) | 6,2 | 2,7 | 4,0 | 5,0 | 5,4 |
| ថ្លៃទំនិញប្រើប្រាស់ | | | | | |
| ប្រទេស G-7[1,2] | 5,3 | -0,6 | -0,1 | 0,9 | 1,0 |
| សហរដ្ឋអាមេរិក | 2,4 | 2,1 | 2,4 | 2,5 | 2,5 |
| ថ្លៃទំនិញ (ជាដុល្លារអាមេរិក) | | | | | |
| ទំនិញមិនមែនប្រេង | 20,7 | -9,5 | -4,7 | -1,1 | -1,5 |
| ថ្លៃប្រេង (ដុល្លារអាមេរិកក្នុងមួយធុង)[3] | 104,0 | 105,0 | 102,4 | 101,0 | 101,0 |
| ថ្លៃប្រេង (ប្រែប្រួលជាភាគរយ) | 31,6 | 1,0 | -2,5 | -1,3 | -0,1 |
| តម្លៃនាំចេញមួយឯកតានៃក្រុមហ៊ុនកម្មន្តសាល[4] | 8,5 | -2,1 | 2,4 | 2,2 | 1,9 |
| ការប្រាក់ | | | | | |
| ដុល្លារ រយៈពេល 6 ខែ (ភាគរយ) | 0,8 | 0,5 | 0,7 | 1,1 | 1,4 |
| អឺរ៉ូ រយៈពេល 6 ខែ (ភាគរយ) | 1,6 | 0,2 | 0,5 | 1,2 | 1,5 |
| **លំហូរមូលធនអន្តរជាតិទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ (%នៃផសស)** | | | | | |
| ប្រទេសកំពុងអភិវឌ្ឍន៍ | | | | | |
| លំហូរចូលមូលធនឯកជននិងផ្លូវការសុទ្ធ | 5,2 | 5,0 | 4,7 | 4,4 | 4,3 |
| លំហូរចូលមូលធនឯកជនសុទ្ធ (ទុនផ្ទាល់+បំណុល) | 5,0 | 4,9 | 4,7 | 4,4 | 4,3 |
| អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក | 5,7 | 4,6 | 4,2 | 3,9 | 3,8 |
| អឺរ៉ុបនិងអាស៊ីកណ្ដាល | 5,5 | 5,7 | 6,5 | 6,1 | 6,0 |
| អាមេរិកឡាទីននិងតំបន់ការ៉ាអ៊ីប | 5,4 | 6,4 | 5,9 | 5,5 | 5,3 |
| មជ្ឈឹមបូព៌ានិងអាហ្វ្រិកខាងជើង | 1,3 | 1,4 | 1,1 | 1,4 | 1,7 |
| អាស៊ីខាងត្បូង | 3,3 | 4,0 | 3,6 | 3,4 | 3,3 |
| អាហ្វ្រិកក្រោមសាហារ៉ា | 4,2 | 3,5 | 3,8 | 3,9 | 4,2 |
| *កំណើនផសសពិត*[5] | | | | | |
| **ពិភពលោក** | **2,8** | **2,3** | **2,2** | **3,0** | **3,3** |
| យថាប្រភេទអនុស្សរណៈ ពិភពលោក (ទម្ងន់PPP) | 3,8 | 2,9 | 3,1 | 3,8 | 4,1 |
| **ចំណូលខ្ពស់** | **1,7** | **1,3** | **1,2** | **2,0** | **2,3** |
| ប្រទេសOECD | 1,5 | 1,2 | 1,1 | 1,9 | 2,2 |
| តំបន់អឺរ៉ូ | 1,5 | -0,5 | -0,6 | 0,9 | 1,5 |
| ជប៉ុន | -0,5 | 2,0 | 1,4 | 1,4 | 1,3 |
| សហរដ្ឋអាមេរិក | 1,8 | 2,2 | 2,0 | 2,8 | 3,0 |
| ប្រទេសមិនមែន OECD | 4,9 | 2,8 | 3,1 | 3,7 | 3,9 |
| **ប្រទេសកំពុងអភិវឌ្ឍន៍** | **6,0** | **5,0** | **5,1** | **5,6** | **5,7** |
| អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក | 8,3 | 7,5 | 7,3 | 7,5 | 7,5 |
| ចិន | 9,3 | 7,8 | 7,7 | 8,0 | 7,9 |
| ឥណ្ឌូនេស៊ី | 6,5 | 6,2 | 6,2 | 6,5 | 6,2 |
| ថៃ | 0,1 | 6,5 | 5,0 | 5,0 | 5,5 |
| អឺរ៉ុបនិងអាស៊ីកណ្ដាល | 5,7 | 2,7 | 2,8 | 3,8 | 4,2 |
| រុស្ស៊ី | 4,3 | 3,4 | 2,3 | 3,5 | 3,9 |
| តួកគី | 8,8 | 2,2 | 3,6 | 4,5 | 4,7 |
| រ៉ូម៉ានី | 2,5 | 0,7 | 1,7 | 2,2 | 2,7 |
| អាមេរិកឡាទីននិងតំបន់ការ៉ាអ៊ីប | 4,4 | 3,0 | 3,3 | 3,9 | 3,8 |
| ប្រេស៊ីល | 2,7 | 0,9 | 2,9 | 4,0 | 3,8 |
| ម៉ិចស៊ិក | 3,9 | 3,9 | 3,3 | 3,9 | 3,8 |
| អាហ្សង់ទីន | 8,9 | 1,9 | 3,1 | 3,0 | 3,0 |
| មជ្ឈឹមបូព៌ានិងអាហ្វ្រិកខាងជើង | -2,2 | 3,5 | 2,5 | 3,5 | 4,2 |
| អេហ្ស៊ីប[6] | 1,8 | 2,2 | 1,6 | 3,0 | 4,8 |
| អ៊ីរ៉ង់ | 1,7 | -1,9 | -1,1 | 0,7 | 1,9 |
| អាល់ហ្សេរី | 2,4 | 2,5 | 2,8 | 3,2 | 3,5 |
| អាស៊ីខាងត្បូង | 7,3 | 4,8 | 5,2 | 6,0 | 6,4 |
| ឥណ្ឌា[6,7] | 6,2 | 5,0 | 5,7 | 6,5 | 6,7 |
| ប៉ាគីស្ថាន[6,7] | 3,0 | 3,7 | 3,4 | 3,5 | 3,7 |
| បង់ក្លាដែស[6] | 6,7 | 6,2 | 5,8 | 6,1 | 6,3 |
| អាហ្វ្រិកក្រោមសាហារ៉ា | 4,7 | 4,4 | 4,9 | 5,2 | 5,4 |
| អាហ្វ្រិកខាងត្បូង | 3,1 | 2,5 | 2,5 | 3,2 | 3,3 |
| នីហ្សេរីយ៉ា | 7,4 | 6,5 | 6,7 | 6,7 | 7,0 |
| អង់ហ្គោឡា | 3,4 | 8,1 | 7,2 | 7,5 | 7,8 |
| *យថាប្រភេទអនុស្សរណៈ:* | | | | | |
| ប្រទេសកំពុងអភិវឌ្ឍន៍ | | | | | |
| លើកលែងប្រទេសប្រតិបត្តិការ | 6,5 | 5,0 | 5,3 | 5,8 | 5,9 |
| លើកលែងចិននិងឥណ្ឌា | 4,5 | 3,3 | 3,5 | 4,2 | 4,4 |

ប្រភព៖ Global Economic Outlook ខែ មិថុនា ឆ្នាំ 2013 ធនាគារពិភពលោក

ចំណាំ៖ PPP = គម្លាតអំណាចទិញ e = ប៉ាន់ស្មាន f = ព្យាករណ៍

1- កាណាដា បារាំង អាល្លឺម៉ង់ អ៊ីតាលី ជប៉ុន អង់គ្លេស និងសហរដ្ឋអាមេរិក

2- ជារូបិយវត្ថុក្នុងស្រុក បូកសរុប ដោយប្រើទម្ងន់ផសសឆ្នាំ2005

3- មធ្យមភាគសាមញ្ញតាមលំនាំ Dubai, Brent និង West Texas

4- សន្ទស្សន៍តម្លៃឯកតានៃការនាំចេញទំនិញកម្មន្តសាលពីប្រទេសដែលមានសេដ្ឋកិច្ចចំបងៗ គិតជាដុល្លារអាមេរិក

5- អត្រាកំណើនសរុបត្រូវបានគណនាដោយប្រើទម្ងន់ផសសតាមថ្លៃដុល្លារថេរឆ្នាំ2005

6- ក្នុងន័យរក្សាកិច្ចប្រតិបត្តិរបស់ជាតិ ទិន្នន័យបង់ក្លាដែស អេហ្ស៊ីប ឥណ្ឌា និងប៉ាគីស្ថានត្រូវបានរាយការណ៍លើមូលដ្ឋានឆ្នាំហិរញ្ញកិច្ចក្នុងតារាង 1.1។ តួលេខសរុបដែលអាស្រ័យលើប្រទេសទាំងនេះត្រូវបានគណនាដោយប្រើទិន្នន័យដែលបានប្រមូលតាមឆ្នាំប្រតិទិន។

7- ផសសពិតគិតតាមថ្លៃចំណាយ មានលក្ខណៈស្របគ្នាជាមួយទម្លាប់នៃការរាយការណ៍នៅប៉ាគីស្ថាននិងឥណ្ឌា។ សម្រាប់ព័ត៌មានបន្ថែម សូមមើលតារាង SAR.2, South Asia Regional Annex

# ឧបសម្ព័ន្ធ 2

# សូចនាករសំខាន់ៗនៅកម្ពុជា

សូចនាករសំខាន់ៗរបស់កម្ពុជា

| | ឆ្នាំ 2012 | ឆ្នាំ 2013p | ឆ្នាំ 2014f | ឆ្នាំ 2015f |
|---|---|---|---|---|
| **លទ្ធផល ការងារ និងថ្លៃ** | | | | |
| ផសស ពិត (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7,3 | 7,0 | 6,8 | 7,0 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 11,9 | 9,0 | 8,3 | 8,7 |
| សន្ទស្សន៍ផលិតកម្មឧស្សាហកម្ម (ឆ្នាំ2000=100) | 315,9 | 341,1 | 363,3 | 388,7 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 5,0 | 8,0 | 6,5 | 7,0 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 2,5 | 5,0 | 6,0 | 5,0 |
| **វិស័យសាធារណៈ** | | | | |
| ចំណូលរដ្ឋាភិបាល (% នៃផសស) | 14,4 | 14,2 | 14,5 | 14,8 |
| ចំណាយរដ្ឋាភិបាល (% នៃផសស) | 19,7 | 19,6 | 20,0 | 19,0 |
| តុល្យការរដ្ឋាភិបាល (% នៃផសស) | -5,3 | -5,4 | -5,5 | -4,2 |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងពាណិជ្ជកម្ម និងបំណុលបរទេស** | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -1.949,2 | -2.082,3 | -2.636,8 | -2.956,1 |
| នាំចេញទំនិញ (លានដុល្លារអាមេរិក) | 6.015,7 | 6.918,1 | 7.713,6 | 9.102,1 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 11,4 | 15,0 | 11,5 | 18,0 |
| ការនាំចេញសំខាន់ៗ (% នៃផសស)1/ | 7,0 | 18,0 | 15,5 | 20,0 |
| ការនាំចូលទំនិញ (លានដុល្លារអាមេរិក) | 7.964,9 | 9.000,3 | 10.350,4 | 12.058,2 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 18,7 | 13,0 | 15,0 | 16,5 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1.436,6 | -1.499,2 | -2.065,7 | -2.217,1 |
| (% នៃផសស) | -10,1 | -9,6 | -12,0 | -11,8 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក)3/ | 1.410,2 | 1.452,5 | 1.626,8 | 1.748,8 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 4.281,0 | 4.726,0 | 5.229,5 | 5.634,1 |
| (% នៃផសស) | 30,2 | 30,2 | 30,4 | 29,9 |
| បំណុលរយៈពេលខ្លី (លានដុល្លារអាមេរិក) | 67,0 | 66,9 | 66,7 | 66,5 |
| អនុបាតសេវាបំណុល (% ការនាំចេញទំនិញនិងសេវា) | 1,2 | 1,3 | 1,5 | 1,5 |
| ទុនបំរុងជារូបិយបណ្ណបរទេសដុល (លានដុល្លារអាមេរិក) | 3.463,0 | 3.843,9 | 4.151,4 | 4.525,1 |
| (ចំនួនខែនៃការនាំចូលទំនិញនិងសេវា) | 3,3 | 3,2 | 3,1 | 3,0 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 34,0 | 28,0 | 25,0 | 25,0 |
| អត្រាការប្រាក់រយៈពេលខ្លី (%ក្នុងមួយឆ្នាំ) | 13,7 | 13,0 | 13,5 | 13,5 |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាមេរិក ចុងគ្រា) | 3.995,0 | 4.000,0 | 4.063,6 | 4.076,0 |
| អត្រាប្តូរប្រាក់ខ្ទេងពិត (ឆ្នាំ2000=100) | 128,6 | ... | ... | ... |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 3,0 | ... | ... | ... |
| អនុស្សារណៈ ផសសជាក់ស្តែង (លានដុល្លារអាមេរិក) | 14.195,6 | 15.649,0 | 17.213,9 | 18.844,5 |

ប្រភព៖ ប្រភពនានានៃទិន្នន័យជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

e = ប៉ាន់ស្មាន f = ព្យាករណ៍ p = ចំណោល

1/ សម្លៀកបំពាក់

2/ មិនគិតប្រាក់បង្វែរផ្លូវការ

3/ ចាប់តាំងពីឆ្នាំ2011មក រួមបញ្ចូលវិនិយោគផ្ទាល់ពីបរទេសដែលទាក់ទងនឹងគម្រោងថាមពលរវាងរដ្ឋ និងវិស័យឯកជន

# ឧបសម្ព័ន្ធ 3

# កម្ពុជា៖ ចំណាយតាមវិស័យពីប្រភពហិរញ្ញប្បទានក្នុងស្រុក

## ចំណាយចរន្តតាមក្រសួងដែលទទួលហិរញ្ញប្បទានពីប្រភពក្នុងស្រុក

( 2005-2013 )

| (ពាន់លានរៀល) | 2005 | | | 2006 | | | 2007 | | | 2008 | | | 2009 | | | 2010 | | | 2011 | | | 2012 BUDGET | | | 2013 BUDGET | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស | សរុប | % នៃ ចំណាយថវិកា | % នៃ ផសស |
| **ចំណាយសរុបរបស់ក្រសួង/ស្ថាប័ន** | **1.254,6** | **42,8** | **4,9** | **1.572,8** | **53,7** | **5,3** | **1.900,0** | **53,3** | **5,4** | **2.565,3** | **53,2** | **6,1** | **3.308,7** | **54,3** | **7,7** | **3.518,5** | **54,6** | **7,5** | **4.348,0** | **56,1** | **8,4** | **3.906,3** | **48,3** | **6,8** | **4.440,5** | **47,9** | **7,0** |
| **I- រដ្ឋបាលទូទៅ** | **346,8** | **11,8** | **1,3** | **437,1** | **14,9** | **1,5** | **568,9** | **15,9** | **1,6** | **801,7** | **16,6** | **1,9** | **1.323,7** | **21,7** | **3,1** | **1.410,8** | **21,9** | **3,0** | **1.917,0** | **24,7** | **3,7** | **932,2** | **11,5** | **1.6** | **1.100,1** | **11,9** | **1,7** |
| 01- ព្រះបរមរាជវាំង | 36,2 | 1,2 | 0,1 | 39,4 | 1,3 | 0,1 | 41,1 | 1,2 | 0,1 | 43,8 | 0,9 | 0,1 | 48,0 | 0,8 | 0,1 | 47,4 | 0,7 | 0,1 | 49,2 | 0,6 | 0,1 | 53,5 | 0,7 | 0,1 | 58,3 | 0,6 | 0,1 |
| 02- រដ្ឋសភាជាតិ | 40,0 | 1,4 | 0,2 | 49,9 | 1,7 | 0,2 | 68,2 | 1,9 | 0,2 | 86,0 | 1,8 | 0,2 | 100,0 | 1,6 | 0,2 | 113,3 | 1,8 | 0,2 | 109,1 | 1,4 | 0,2 | 108,3 | 1,3 | 0,2 | 114,7 | 1,2 | 0,2 |
| 03- ព្រឹទ្ធសភា | 18,6 | 0,6 | 0,1 | 20,7 | 0,7 | 0,1 | 25,6 | 0,7 | 0,1 | 30,1 | 0,6 | 0,1 | 30,8 | 0,5 | 0,1 | 32,7 | 0,5 | 0,1 | 34,9 | 0,5 | 0,1 | 38,3 | 0,5 | 0,1 | 46,9 | 0,5 | 0,1 |
| 04- ក្រុមប្រឹក្សាធម្មនុញ្ញ | 3,3 | 0,1 | 0,0 | 3,4 | 0,1 | 0,0 | 3,5 | 0,1 | 0,0 | 5,1 | 0,1 | 0,0 | 6,3 | 0,1 | 0,0 | 6,8 | 0,1 | 0,0 | 6,6 | 0,1 | 0,0 | 7,3 | 0,1 | 0,0 | 7,9 | 0,1 | 0,0 |
| 05-1 ក្រុមប្រឹក្សារដ្ឋមន្ត្រី | 94,0 | 3,2 | 0,4 | 110,1 | 3,8 | 0,4 | 162,2 | 4,5 | 0,5 | 314,5 | 6,5 | 0,7 | 341,9 | 5,6 | 0,8 | 286,4 | 4,4 | 0,6 | 505,8 | 6,5 | 1,0 | 235,4 | 2,9 | 0,4 | 249,3 | 2,7 | 0,4 |
| 05-2 រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | 2,1 | 0,1 | 0,0 | 2,2 | 0,1 | 0,0 | 2,0 | 0,1 | 0,0 | 2,5 | 0,1 | 0,0 | 2,9 | 0,0 | 0,0 | 2,4 | 0,0 | 0,0 | 2,7 | 0,0 | 0,0 | 3,5 | 0,0 | 0,0 | 3,9 | 0,0 | 0,0 |
| 05-4 ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 3,3 | 0,1 | 0,0 | 3,9 | 0,1 | 0,0 | 3,6 | 0,1 | 0,0 | 4,3 | 0,1 | 0,0 | 5,0 | 0,1 | 0,0 | 4,2 | 0,1 | 0,0 | 5,2 | 0,1 | 0,0 | 5,8 | 0,1 | 0,0 | 6,4 | 0,1 | 0,0 |
| 07-2 មហាផ្ទៃរដ្ឋបាល | 20,4 | 0,7 | 0,1 | 38,0 | 1,3 | 0,1 | 42,5 | 1,2 | 0,1 | 47,5 | 1,0 | 0,1 | 47,0 | 0,8 | 0,1 | 50,7 | 0,8 | 0,1 | 56,1 | 0,7 | 0,1 | 65,3 | 0,8 | 0,1 | 72,1 | 0,8 | 0,1 |
| 08- ទំនាក់ទំនងសភានិងអធិការកិច្ច | 3,7 | 0,1 | 0,0 | 5,5 | 0,2 | 0,0 | 7,3 | 0,2 | 0,0 | 9,6 | 0,2 | 0,0 | 10,7 | 0,2 | 0,0 | 14,5 | 0,2 | 0,0 | 14,9 | 0,2 | 0,0 | 17,4 | 0,2 | 0,0 | 19,6 | 0,2 | 0,0 |
| 09- ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 57,1 | 1,9 | 0,2 | 59,7 | 2,0 | 0,2 | 65,6 | 1,8 | 0,2 | 77,9 | 1,6 | 0,2 | 72,7 | 1,2 | 0,2 | 64,6 | 1,0 | 0,1 | 75,9 | 1,0 | 0,1 | 99,2 | 1,2 | 0,2 | 81,4 | 0,9 | 0,1 |
| 10- សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 40,4 | 1,4 | 0,2 | 71,9 | 2,5 | 0,2 | 76,9 | 2,2 | 0,2 | 107,5 | 2,2 | 0,3 | 600,6 | 9,9 | 1,4 | 722,0 | 11,2 | 1,5 | 976,2 | 12,6 | 1,9 | 124,7 | 1,5 | 0,2 | 236,2 | 2,5 | 0,4 |
| 14- ផែនការ | 6,3 | 0,2 | 0,0 | 7,8 | 0,3 | 0,0 | 9,5 | 0,3 | 0,0 | 12,4 | 0,3 | 0,0 | 15,2 | 0,3 | 0,0 | 21,8 | 0,3 | 0,0 | 22,8 | 0,3 | 0,0 | 31,3 | 0,4 | 0,1 | 37,5 | 0,4 | 0,1 |
| 26- យុត្តិធម៌ | 11,7 | 0,4 | 0,0 | 13,2 | 0,5 | 0,0 | 15,6 | 0,4 | 0,0 | 19,1 | 0,4 | 0,0 | 23,3 | 0,4 | 0,1 | 30,4 | 0,5 | 0,1 | 32,8 | 0,4 | 0,1 | 45,4 | 0,6 | 0,1 | 51,0 | 0,5 | 0,1 |
| 30- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 6,0 | 0,2 | 0,0 | 6,2 | 0,2 | 0,0 | 40,0 | 1,1 | 0,1 | 35,9 | 0,7 | 0,1 | 13,9 | 0,2 | 0,0 | 7,6 | 0,1 | 0,0 | 18,9 | 0,2 | 0,0 | 67,8 | 0,8 | 0,1 | 79,2 | 0,9 | 0,1 |
| 31- អាជ្ញាធរជាតិសវនកម្ម | 3,7 | 0,1 | 0,0 | 5,0 | 0,2 | 0,0 | 5,4 | 0,2 | 0,0 | 5,5 | 0,1 | 0,0 | 5,5 | 0,1 | 0,0 | 5,9 | 0,1 | 0,0 | 5,9 | 0,1 | 0,0 | 6,9 | 0,1 | 0,0 | 8,3 | 0,1 | 0,0 |
| 31-1 អង្គភាពប្រឆាំងអំពើពុករលួយ | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 22,1 | 0,3 | 0,0 | 27,5 | 0,3 | 0,0 |
| **II- ការពារនិងសន្តិសុខ** | **451,2** | **15,4** | **1,8** | **520,2** | **17,8** | **1,7** | **615,9** | **17,3** | **1,8** | **813,8** | **16,9** | **1,9** | **1.427,4** | **23,4** | **3,3** | **1.153,1** | **17,9** | **2,5** | **1.303,3** | **16,8** | **2,5** | **1.398,4** | **17,3** | **2,4** | **1.600,6** | **17,3** | **2,5** |
| 06- ការពារជាតិ | 289,4 | 9,9 | 1,1 | 328,1 | 11,2 | 1,1 | 372,6 | 10,4 | 1,1 | 501,1 | 10,4 | 1,2 | 972,4 | 16,0 | 2,3 | 735,8 | 11,4 | 1,6 | 826,1 | 10,7 | 1,6 | 876,4 | 10,8 | 1,5 | 980,5 | 10,6 | 1,6 |
| 07-1 មហាផ្ទៃ សន្តិសុខ | 161,8 | 5,5 | 0,6 | 192,0 | 6,6 | 0,6 | 243,3 | 6,8 | 0,7 | 312,7 | 6,5 | 0,7 | 455,0 | 7,5 | 1,1 | 417,3 | 6,5 | 0,9 | 477,2 | 6,2 | 0,9 | 522,0 | 6,5 | 0,9 | 620,1 | 6,7 | 1,0 |
| **III- សង្គមកិច្ច** | **729,8** | **24,9** | **2,8** | **895,5** | **30,6** | **3,0** | **1.064,0** | **29,8** | **3,0** | **1.322,9** | **27,4** | **3,2** | **1.636,5** | **26,9** | **3,8** | **1.725,4** | **26,8** | **3,7** | **1.967,8** | **25,4** | **3,8** | **2.434,4** | **30,1** | **4,2** | **2.746,5** | **29,6** | **4,3** |
| 11- ព័ត៌មាន | 13,2 | 0,4 | 0,1 | 17,2 | 0,6 | 0,1 | 18,5 | 0,5 | 0,1 | 23,0 | 0,5 | 0,1 | 40,4 | 0,7 | 0,1 | 39,9 | 0,6 | 0,1 | 50,2 | 0,6 | 0,1 | 58,6 | 0,7 | 0,1 | 74,5 | 0,8 | 0,1 |
| 12- សុខាភិបាលសាធារណៈ | 224,6 | 7,7 | 0,9 | 260,8 | 8,9 | 0,9 | 343,3 | 9,6 | 1,0 | 426,8 | 8,9 | 1,0 | 524,5 | 8,6 | 1,2 | 593,2 | 9,2 | 1,3 | 667,3 | 8,6 | 1,3 | 794,2 | 9,8 | 1,4 | 901,5 | 9,7 | 1,4 |
| 16- អប់រំ យុវជន និងកីឡា | 350,8 | 12,0 | 1,4 | 445,6 | 15,2 | 1,5 | 493,7 | 13,8 | 1,4 | 606,5 | 12,6 | 1,4 | 708,2 | 11,6 | 1,6 | 712,5 | 11,1 | 1,5 | 799,6 | 10,3 | 1,5 | 1.007,6 | 12,5 | 1,8 | 1.119,6 | 12,1 | 1,8 |
| 18- វប្បធម៌ និងវិចិត្រសិល្បៈ | 14,3 | 0,5 | 0,1 | 15,5 | 0,5 | 0,1 | 17,8 | 0,5 | 0,1 | 22,2 | 0,5 | 0,1 | 25,3 | 0,4 | 0,1 | 25,8 | 0,4 | 0,1 | 28,8 | 0,4 | 0,1 | 39,6 | 0,5 | 0,1 | 43,2 | 0,5 | 0,1 |
| 19- បរិស្ថាន | 8,2 | 0,3 | 0,0 | 9,5 | 0,3 | 0,0 | 11,2 | 0,3 | 0,0 | 16,1 | 0,3 | 0,0 | 18,1 | 0,3 | 0,0 | 18,9 | 0,3 | 0,0 | 24,1 | 0,3 | 0,0 | 25,7 | 0,3 | 0,0 | 28,0 | 0,3 | 0,0 |
| 21- សង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា | 95,4 | 3,3 | 0,4 | 108,0 | 3,7 | 0,4 | 129,1 | 3,6 | 0,4 | 159,0 | 3,3 | 0,4 | 196,5 | 3,2 | 0,5 | 236,9 | 3,7 | 0,5 | 281,7 | 3,6 | 0,5 | 353,2 | 4,4 | 0,6 | 411,0 | 4,4 | 0,6 |
| 23- ធម្មការនិងសាសនា | 4,1 | 0,1 | 0,0 | 5,5 | 0,2 | 0,0 | 7,6 | 0,2 | 0,0 | 9,6 | 0,2 | 0,0 | 12,1 | 0,2 | 0,0 | 20,2 | 0,3 | 0,0 | 21,9 | 0,3 | 0,0 | 26,5 | 0,3 | 0,0 | 30,5 | 0,3 | 0,0 |
| 24- កិច្ចការនារី | 10,3 | 0,4 | 0,0 | 13,1 | 0,4 | 0,0 | 14,9 | 0,4 | 0,0 | 19,9 | 0,4 | 0,0 | 23,7 | 0,4 | 0,1 | 24,7 | 0,4 | 0,1 | 24,6 | 0,3 | 0,0 | 29,6 | 0,4 | 0,1 | 30,9 | 0,3 | 0,0 |
| 32- ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | 8,9 | 0,3 | 0,0 | 20,2 | 0,7 | 0,1 | 28,0 | 0,8 | 0,1 | 39,8 | 0,8 | 0,1 | 87,5 | 1,4 | 0,2 | 53,2 | 0,8 | 0,1 | 69,6 | 0,9 | 0,1 | 99,4 | 1,2 | 0,2 | 107,4 | 1,2 | 0,2 |
| **IV- សេដ្ឋកិច្ច** | **178,1** | **6,1** | **0,7** | **240,3** | **8,2** | **0,8** | **267,1** | **7,5** | **0,8** | **440,7** | **9,1** | **1,1** | **348,5** | **5,7** | **0,8** | **382,3** | **5,9** | **0,8** | **463,1** | **6,0** | **0,9** | **539,7** | **6,7** | **0,9** | **593,9** | **6,4** | **0,9** |
| 05-3 រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 7,2 | 0,2 | 0,0 | 8,2 | 0,3 | 0,0 | 9,8 | 0,3 | 0,0 | 10,5 | 0,2 | 0,0 | 11,3 | 0,2 | 0,0 | 12,2 | 0,2 | 0,0 | 13,1 | 0,2 | 0,0 | 15,0 | 0,2 | 0,0 | 18,3 | 0,2 | 0,0 |
| 13- ឧស្សាហកម្ម រ៉ែ និងថាមពល | 7,4 | 0,3 | 0,0 | 31,0 | 1,1 | 0,1 | 38,3 | 1,1 | 0,1 | 163,2 | 3,4 | 0,4 | 15,0 | 0,2 | 0,0 | 16,1 | 0,2 | 0,0 | 27,2 | 0,4 | 0,1 | 20,5 | 0,3 | 0,0 | 22,1 | 0,2 | 0,0 |
| 15- ពាណិជ្ជកម្ម | 14,6 | 0,5 | 0,1 | 17,3 | 0,6 | 0,1 | 20,4 | 0,6 | 0,1 | 29,9 | 0,6 | 0,1 | 35,3 | 0,6 | 0,1 | 49,4 | 0,8 | 0,1 | 44,1 | 0,6 | 0,1 | 66,7 | 0,8 | 0,1 | 76,3 | 0,8 | 0,1 |
| 17- កសិកម្ម រុក្ខាប្រមាញ់និងនេសាទ | 47,1 | 1,6 | 0,2 | 55,9 | 1,9 | 0,2 | 57,7 | 1,6 | 0,2 | 65,8 | 1,4 | 0,2 | 79,9 | 1,3 | 0,2 | 81,3 | 1,3 | 0,2 | 91,0 | 1,2 | 0,2 | 109,7 | 1,4 | 0,2 | 121,2 | 1,3 | 0,2 |
| 20- អភិវឌ្ឍន៍ជនបទ | 22,1 | 0,8 | 0,1 | 30,0 | 1,0 | 0,1 | 34,8 | 1,0 | 0,1 | 45,2 | 0,9 | 0,1 | 60,7 | 1,0 | 0,1 | 73,7 | 1,1 | 0,2 | 85,2 | 1,1 | 0,2 | 95,9 | 1,2 | 0,2 | 109,3 | 1,2 | 0,2 |
| 22- ប្រៃសណីយ៍និងទូរគមនាគមន៍ | 30,9 | 1,1 | 0,1 | 31,7 | 1,1 | 0,1 | 30,5 | 0,9 | 0,1 | 34,5 | 0,7 | 0,1 | 37,0 | 0,6 | 0,1 | 36,7 | 0,6 | 0,1 | 24,7 | 0,3 | 0,0 | 27,6 | 0,3 | 0,0 | 22,2 | 0,2 | 0,0 |
| 25- សាធារណការនិងដឹកជញ្ជូន | 13,0 | 0,4 | 0,1 | 17,3 | 0,6 | 0,1 | 19,8 | 0,6 | 0,1 | 25,3 | 0,5 | 0,1 | 29,9 | 0,5 | 0,1 | 29,5 | 0,5 | 0,1 | 40,0 | 0,5 | 0,1 | 42,5 | 0,5 | 0,1 | 47,9 | 0,5 | 0,1 |
| 27- ទេសចរណ៍ | 14,3 | 0,5 | 0,1 | 17,2 | 0,6 | 0,1 | 20,3 | 0,6 | 0,1 | 21,4 | 0,4 | 0,1 | 27,4 | 0,5 | 0,1 | 27,9 | 0,4 | 0,1 | 40,3 | 0,5 | 0,1 | 34,3 | 0,4 | 0,1 | 38,8 | 0,4 | 0,1 |
| 28- រៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | 7,9 | 0,3 | 0,0 | 12,7 | 0,4 | 0,0 | 15,3 | 0,4 | 0,0 | 19,0 | 0,4 | 0,0 | 22,5 | 0,4 | 0,1 | 25,2 | 0,4 | 0,1 | 55,1 | 0,7 | 0,1 | 76,1 | 0,9 | 0,1 | 79,9 | 0,9 | 0,1 |
| 29- ធនធានទឹកនិងឧតុនិយម | 13,7 | 0,5 | 0,1 | 18,8 | 0,6 | 0,1 | 20,4 | 0,6 | 0,1 | 25,8 | 0,5 | 0,1 | 29,5 | 0,5 | 0,1 | 30,5 | 0,5 | 0,1 | 42,4 | 0,5 | 0,1 | 51,4 | 0,6 | 0,1 | 57,9 | 0,6 | 0,1 |

ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ធនាគារពិភពលោក

**ការិយាល័យប្រទេសកម្ពុជា**
ផ្ទះលេខ113 ផ្លូវព្រះនរោត្តម ភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (855-23) 861 300
ទូរសារ : (855-23) 861 301/302

គេហទំព័រ: www.worldbank.org